# ការអប់រំសន្តិភាព និង ដកហូតអាវុធ

## សម្រាប់មធ្យមសិក្សាទុតិយភូមិនៅកម្ពុជា

ផ្តល់ជូនក្រសួងអប់រំយុវជន និងកីឡា ជាឯកសារបន្ថែមសម្រាប់ការសិក្សាសង្គមលើមុខវិជ្ជា
សីលធម៌_ពលរដ្ឋវិជ្ជា ថ្នាក់ទី ១០, ១១ និង ១២




និពន្ធ និងរៀបចំចងក្រងដោយ៖ **អង្គការកាត់បន្ថយអាវុធ (WGWR)**



ឧបត្ថម្ភដោយ៖ Hague Appeal for Peace and United Nations Department for Disarmament Affairs

**ផលិតដោយ:**
លោកស្រី ហ្វូត ថាវីរ
លោក លឹម មិញ
កញ្ញា លឹម សុខជា
លោក ម៉ារកូស ស្មីត
លោកស្រី អេមា៉ លេស្លី

**ដើម្បី:**
**អង្គការកាត់បន្ថយអាវុធ** ( WGWR )

**ឧបត្ថម្ភថវិកាដោយ:**
Hague Appeal for Peace **(HAP)**
United Nations Department for Disarmament Affairs **(UNDDA)**

**រចនាសៀវភៅដោយ:**
លោក ប៊ុនរឿង សុងង៉ម

**គូររូបភាពដោយ:**
លោក គាំ សារ៉ែន

**អង្គការកាត់បន្ថយអាវុធ** ( WGWR )
ផ្ទះលេខ ៩៥ មហាវិថីព្រះសុធារស សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា។
E-mail: wgwr@online.com.kh
ទូរស័ព្ទ : (៨៥៥) ២៣ ២២២ ៤៦២
អ៊ីនធឺណែត: www.wgwr.org

## កម្មវិធីសិក្សាស្តីពី

# ការអប់រំសន្តិភាព និង ដកហូតអាវុធ
# សម្រាប់មធ្យមសិក្សាទុតិយភូមិនៅកម្ពុជា

ផ្តល់ជូនក្រសួងអប់រំយុវជន និងកីឡា ជាឯកសារបន្ថែមសម្រាប់ការសិក្សាសង្គម

លើមុខវិជ្ជាសីលធម៌ -ពលរដ្ឋវិជ្ជា ថ្នាក់ទី ១០, ១១ និង ១២

និពន្ធ និងរៀបចំចងក្រងដោយ **អង្គការកាត់បន្ថយអាវុធ** ( **WGWR** )

ឧបត្ថម្ភដោយ **HAP / UNDDA**

**“យើងត្រូវការបង្រៀនយុវជននូវការគោរពជីវិត និងការគោរពច្បាប់ និងនាំយកមកឱ្យយុវជននូវវប្បធម៌សន្តិភាព និងវប្បធម៌អហិង្សា”**

ឯកឧត្តមបណ្ឌិត **កុល ផេង** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

# មាតិការឿង


លិខិតផ្តល់ការគាំទ្រ ..... ៥

បុព្វកថា ..... ៦

សេចក្តីថ្លែងអំណរគុណ ..... ៨

របៀបប្រើប្រាស់សៀវភៅ ..... ១០

ប្រាំនាទីដើម្បីសន្តិភាព ..... ១២


## ផ្នែកទី១: ប្រធានបទនៃមេរៀន


**ជំពូក១ ការប្រាស្រ័យទាក់ទងនិងការទំនាក់ទំនងជាមួយអ្នកដទៃ ..... ១៧**

សញ្ញាក្ខន្ធខុសៗគ្នារបស់យើង ..... ១៩

ដំណោះស្រាយអំពីបុរេនិច្ឆ័យ ..... ២២

ការធ្វើឱ្យអ្នកដទៃឈឺចាប់បណ្តាលមកពីការភ័យខ្លាច ..... ២៦

ការកោតសរសើរពីភាពខុសគ្នារបស់អ្នកដទៃ ..... ២៨

ការស្តាប់គ្នាទៅវិញទៅមក ..... ៣១

ការប្រាស្រ័យទាក់ទងល្អ ..... ៣៤

**ជំពូក២ ទំនាស់ ..... ៣៧**

បទពិសោធន៍របស់យើងអំពីទំនាស់ ..... ៣៩

ទំនាស់ និងអំពើហិង្សា ..... ៤១

ការគ្រប់គ្រងពាក្យចចាមអារ៉ាម ..... ៤៤

សុភាសិតស្តីពីទំនាស់នៅក្នុងពិភពលោក ..... ៤៦

ទូរទស្សន៍ និងអំពើហិង្សា ..... ៤៩

ផលវិបាកនៃការប្រើប្រាស់អាវុធ ..... ៥១

គោលការណ៍សម្រាប់សហគមន៍របស់យើង ..... ៥៥

សន្តិសុខនៅក្នុងជីវិតរបស់ខ្ញុំ ..... ៥៧

សិទ្ធិនិងតម្រូវការ ..... ៥៩

អាវុធ និងច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ..... ៦២

ជំពូក៣ ការសម្រេចចិត្ត ........ ៦៥

តើយើងធ្វើការសម្រេចចិត្តយ៉ាងដូចម្តេច? ........ ៦៧

ការសម្រេចចិត្តរួមគ្នា ........ ៦៩

ការធ្វើការសម្រេចចិត្តដោយកុងសង់ស៊ុស ........ ៧១

ការផ្តល់អទិភាព និងការសម្រេចចិត្ត ........ ៧៤

ជំពូក៤ ការសហការគ្នា ........ ៧៧

ការសហការជាមួយអ្នកដទៃ ........ ៧៩

ការធ្វើការរួមគ្នា ........ ៨១

ការសម្រុះសម្រួល ........ ៨៣

ជំពូក៥ ការកសាងសន្តិភាព និងការបង្កើតទស្សនវិស័យ ........ ៨៧

តើនរណាជាអ្នកកសាងសន្តិភាពក្នុងសហគមន៍យើង? ........ ៨៩

ទស្សនវិស័យរបស់ខ្ញុំសម្រាប់អនាគតរបស់ខ្ញុំ ........ ៩២

ការកសាងទស្សនវិស័យសម្រាប់សង្គមរបស់យើង ........ ៩៤

ទស្សនវិស័យនៃសន្តិភាពសម្រាប់ពិភពលោកយើង ........ ៩៧

ជំពូក៦ មេរៀនដែលមានរូបភាពផ្ទាំងធំរបស់អង្គការកាត់បន្ថយអាវុធជាមូលដ្ឋាន ........ ១០១

មេរៀនរូបភាពផ្ទាំងធំរបស់អង្គការកាត់បន្ថយអាវុធ ........ ១០៣

ការអប់រំសហគមន៍ ........ ១០៤

កងកម្លាំងប្រដាប់អាវុធ ........ ១០៦

សាធារណៈជន ........ ១០៨

ការអប់រំយុវជន ........ ១១០

ផ្នែកទី២ : ឯកសារណែនាំវិធីបញ្ជ្រាបខ្លឹមសារការអប់រំសន្តិភាព និងដកហូតអាវុធ

កំណត់យុទ្ធវិធីបង្រៀន (បញ្ជ្រាបការអប់រំសន្តិភាព និងដកហូតអាវុធ) ........ ១១៥

ការប្រើប្រាស់ឯកសារ ការអប់រំសន្តិភាព និងដកហូតអាវុធ ........ ១១៧

លំណែនាំកិច្ចតែងការបង្រៀន ........ ១២០

មេរៀនគំរូ "ការយល់ឃើញខុសៗគ្នារបស់យើង" ........ ១២២

ឯកសារយោង ........ ១២៤

# លិខិតផ្ដល់ការគាំទ្រ

ក្នុងនាម **ក្រសួងអប់រំយុវជន និងកីឡា** ខ្ញុំមានសេចក្ដីសោមនស្សក្រៃលែងដែល **អង្គការកាត់បន្ថយអាវុធ** (WGWR) បានផ្ដួចផ្ដើមគំនិតណែនាំបង្ហាញកម្មវិធីសិក្សាស្ដីពី ***"ការអប់រំសន្តិភាព និងដកហូតអាវុធ"*** នេះដល់ប្រពន្ធ័អប់រំកំរិតមធ្យមសិក្សានៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងប្រទេសកម្ពុជា យើងទាំងអស់គ្នាបានប្រឈមមុខនិងទំនាស់បង្ហូរឈាមអស់រយៈពេលជាច្រើនទសវត្សរ៍។ ដោយសារបទពិសោធន៍នេះហើយ បានធ្វើឱ្យកម្មវិធីសិក្សានេះមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យុវជនជំនាន់ក្រោយ រៀនសូត្រនូវវិធីដោះស្រាយបញ្ហាដោយអហិង្សាប្រកបដោយសន្តិភាព និងធ្វើការអភិវឌ្ឍន៍ប្រទេសជាតិរបស់យើង។ អាស្រ័យហេតុនេះហើយបានជា **ក្រសួងអប់រំយុវជន និងកីឡា** រីករាយនឹងផ្ដល់នូវការគាំទ្រលើការបោះពុម្ពនេះ នឹងជំរុញឱ្យលោក លោកស្រី ជានាយក នាយិកាសាលា គ្រូឧទ្ទេសសាលាគរុកោសល្យ គ្រូមុខវិជ្ជាសីលធម៌-ពលរដ្ឋ ព្រមទាំងគ្រូមុខវិជ្ជាផ្សេងៗទៀត ដើម្បីបញ្ជ្រាបកម្មវិធីសិក្សានេះទៅក្នុងកិច្ចតែងការបង្រៀនប្រចាំថ្ងៃរបស់ខ្លួន ក៏ដូចជានៅក្នុងសកម្មភាពផ្សេងៗរបស់សាលារៀន។

កំណត់សំគាល់អំពីដំណើរការនៃកិច្ចសហប្រតិបត្តិការរបស់ **អង្គការកាត់បន្ថយអាវុធ** ដែលបានប្រើប្រាស់ពេលវេលាដើម្បីធ្វើឱ្យមានការបោះពុម្ពផ្សាយនេះឡើងជាកិច្ចការសំខាន់ ដោយហេតុថា ចាប់តាំងពីពេលចាប់ផ្ដើមរហូតដល់ទីបញ្ចប់ លោកគ្រូ-អ្នកគ្រូ គ្រូឧទ្ទេសសាលាគរុកោសល្យ និងគរុសិស្សផ្ទាល់ ត្រូវបានអញ្ជើញឱ្យមកចូលរួមពិភាក្សាដើម្បីសុំមតិយោបល់សំខាន់ៗក្នុងគោលបំណងផលិតចេញនូវកម្មវិធីសិក្សានេះ។ ទំនាក់ទំនងដ៏ល្អរបស់អង្គការកាត់បន្ថយអាវុធ ជាមួយ រាជរដ្ឋាភិបាល គឺជាសម្ព័ន្ធភាពដៃគូជាវិជ្ជមានមួយសម្រាប់យើងទាំងអស់គ្នា ហើយក្រសួងអប់រំយុវជន និងកីឡា នឹងរង់ចាំបន្តកិច្ចសហការជាបន្តបន្ទាប់ទៀតជាមួយអង្គការកាត់បន្ថយអាវុធ។

ជាថ្មីម្ដងទៀត ក្រសួងអប់រំយុវជន និងកីឡា សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិកអង្គការ ក៏ដូចជាម្ចាស់ជំនួយរបស់អង្គការកាត់បន្ថយអាវុធ ហើយក៏សូមផ្ដល់នូវការគាំទ្រលើការបោះពុម្ពផ្សាយនេះ ជូនដល់ផ្នែកអប់រំនៅក្នុងប្រទេសកម្ពុជា។

ធ្វើនៅភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៧

រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

# បុព្វកថា

ឯកសារនេះជាកម្មវិធីសិក្សារួមនៃការអប់រំសន្តិភាព និងដកហូតអាវុធ ។ កម្មវិធីសិក្សាស្តីពី **សន្តិភាព** ផ្តល់ដល់សិស្សមធ្យមសិក្សាទុតិយភូមិ នូវ **ចំណេះដឹង បំណិន និងឥរិយាបថ** សម្រាប់ដោះស្រាយទំនាស់រវាងបុគ្គល និងបុគ្គល និងទំនាស់ក្នុងសហគមន៍របស់ពួកគេ ។ ជំនាញសំខាន់៧មាន **ការប្រាស្រ័យទាក់ទង ការស្តាប់ ការដោះស្រាយបញ្ហា ការចរចា និងការសម្រេចចិត្ត** ផ្តល់ដល់សិស្សានុសិស្សនូវសមត្ថភាពសម្រាប់ធ្វើឱ្យទំនាក់ទំនងជាមួយអ្នកដទៃកាន់តែប្រសើរឡើង ហើយអាចឱ្យពួកគេការពារ ធ្វើអន្តរាគមន៍ ឬដោះស្រាយទំនាស់ប្រកបដោយប្រសិទ្ធភាព ។ មេរៀនស្តីពីបុរេនិច្ឆ័យ ការនិយមទម្លាប់ និងពាក្យចចាមអារ៉ាមជួយទប់ស្កាត់រាល់ឥរិយាបថដែលអាចបង្កាត់ជាភ្លើងទំនាស់ ឬឥរិយាបថដែលអាចធ្វើឱ្យទំនាស់ដែលមានស្រាប់ឱ្យមានភាពធូរស្រាល ។ ការកសាងទស្សនវិស័យធ្វើឱ្យមានសន្តិភាព និងការសហការចូលរួមចំណែកដល់ការអភិវឌ្ឍន៍វប្បធម៌សន្តិភាពក្នុងសាលារៀន និងសហគមន៍ខ្មែរក៏ដូចជាជាតិខ្មែរទាំងមូលផងដែរ ។

វត្ថុបំណងទូទៅសម្រាប់ការអប់រំស្តីពី **ការដកហូតអាវុធ** ផ្តោតការចាប់អារម្មណ៍លើតម្រូវការកាត់បន្ថយអាវុធ ដោយឈរលើទស្សនៈថា ការកាត់បន្ថយអាវុធធុនតូច មានន័យថាជាការកាត់បន្ថយភាពអាចកើតមានឡើងនៃទំនាស់ប្រដាប់អាវុធ និងភាពធ្ងន់ធ្ងរនៃទំនាស់ប្រដាប់អាវុធ ។ កម្មវិធីសិក្សាស្តីពី **ការដកហូតអាវុធ** ធ្វើឱ្យសិស្សយកចិត្តទុកដាក់អំពីផលវិបាកទាំងឡាយរបស់អាវុធព្រមទាំងការអនុវត្តន៍ច្បាប់សម្រាប់អ្នកកាន់អាវុធធុនតូចខុសច្បាប់ផងដែរ ។ យោងតាមការស្ទាបស្ទង់មតិជាមូលដ្ឋានបានបង្ហាញឱ្យឃើញថា សិស្សានុសិស្សបានកត់សំគាល់ថា ការប្រើប្រាស់អាវុធក្នុងសាលារៀនជាការគំរាមកំហែងចំពោះសន្តិសុខ និងសុខមាលភាពរបស់ពួកគេ ។

ធាតុសំខាន់មួយនៃកម្មវិធីសិក្សានេះផ្តល់នូវគំនិតដល់សិស្សមធ្យមសិក្សា នូវអំណាចធ្វើជាអ្នកកសាងសន្តិភាពក្នុងសហគមន៍ ។ ពួកគេជាអ្នកទទួលខុសត្រូវមួយចំណែកសម្រាប់សន្តិសុខក្នុងសាលារៀនរបស់ពួកគេ ព្រមទាំងបង្កើតទំនាក់ទំនងដ៏ល្អប្រសើររវាងសិស្ស និងសិស្ស ហើយនិងការទទួលខុសត្រូវក្នុងការធ្វើអន្តរាគមន៍នៅពេលស្ថានការណ៍តឹងតែង ហើយអាចក្លាយជាហិង្សា ។ ទោះបីជាការធ្វើដូច្នេះមិនមែនជាវីរភាពក្តីក៏វាអាចជួយឱ្យសិស្សមានអារម្មណ៍ទទួលខុសត្រូវ ហើយលែងមានអារម្មណ៍ថា ខ្លួនគ្មានអំណាច និងភ័យខ្លាចនោះទេ ។

កម្មវិធីសិក្សានេះ ត្រូវបានចងក្រងឡើងដោយយកថ្នាក់រៀននៅប្រទេសកម្ពុជាជាបរិបទ ។ ក្នុងខណៈដែលកម្មវិធីសិក្សានេះត្រូវបានរៀបចំតាក់តែងឡើង ធនធានដែលត្រូវបានប្រើប្រាស់នៅក្នុងសាលារៀននៅមានកំរិតនៅឡើយ ។ គឺមានន័យថាលោកគ្រូ-អ្នកគ្រូបង្រៀនដោយគ្មានឧបករណ៍ទំនើបដូចជា ម៉ាស៊ីនបញ្ចាំងស្លាយស៍ ម៉ាស៊ីនកុំព្យូទ័រ ក្រដាសផ្ទាំងធំ-តូចគ្រប់ពណ៌ និងហ្វឺតសរសេរឡើយ ។ ស្ថានភាពសាលារៀននៅប្រទេសកម្ពុជា មានភាពប្លែកគ្នាតិចតួចពីសាលាមួយទៅសាលាមួយទៀត ។ សាលារៀនខ្លះមានការពិបាកក្នុងការចល័តតុកៅអី ដែលនាំឱ្យប៉ះពាល់ដល់ការសិក្សារបស់សិស្សសម្រាប់សកម្មភាពចូលរួមនៃវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ។ ដូច្នេះសកម្មភាពទាំងអស់ដែលបានរៀបចំនៅក្នុងកម្មវិធីសិក្សានេះទាមទារឱ្យមានការចូលរួម ការច្នៃប្រឌិត លទ្ធភាពដែលសិស្សអាចរកបាន និងអាចធ្វើបាន ។ នៅក្នុងបរិបទនេះ អាចធានាបាន

នូវនិរន្តភាព និងភាពសមស្របសម្រាប់កិច្ចតែងការបង្រៀននីមួយៗ និងវាអាចជួយធ្វើឱ្យប្រសើរឡើងដល់ការអនុវត្តមេរៀន នៅក្នុងកម្មវិធីនោះថែមទៀតផង ។

ជាការពិតណាស់ កម្មវិធីសិក្សានេះត្រូវពឹងផ្អែកលើលោកគ្រូ-អ្នកគ្រូដែលជាអ្នកអនុវត្ត ។ ឈរលើហេតុផលនេះ **អង្គការកាត់បន្ថយអាវុធ** បានវិនិយោគការបណ្តុះបណ្តាលគ្រូសីលធម៌-ពលរដ្ឋវិជ្ជា ហើយនិងកំពុងបន្តសហការជាមួយ **ក្រសួងអប់រំ យុវជន និងកីឡា** ដោយផ្តល់ការគាំទ្រជាអតិបរមា ដល់អ្នកដែលធ្វើការដោយផ្ទាល់ជាមួយសិស្សមធ្យមសិក្សាទុតិយភូមិ ។

ភ្នំពេញ ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០៤

**នាយកប្រតិបត្តិ**

WORKING GROUP FOR WEAPONS REDUCTION

**ណែប ស៊ីនថៃ**

# សេចក្ដីថ្លែងអំណរគុណ

**ក្រុមការងារកាត់បន្ថយអាវុធ** សូមថ្លែងអំណរគុណចំពោះការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ **ក្រសួងអប់រំយុវជន និងកីឡា** ក្នុងការធ្វើឱ្យការផលិត និងចែកចាយកម្មវិធីសន្តិភាព និងដកហូតអាវុធនេះ និងសូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត និងការគោរពយ៉ាងខ្ពង់ខ្ពស់ចំពោះ **ឯកឧត្តម អ៊ឹម សិទ្ធី** រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា ។

គម្រោងនេះត្រូវបានឧបត្ថម្ភដោយអង្គការ Hague Appeal for Peace (HAP) ដៃគូនៃ United Nations Department for Disarmament Affairs (UNDDA) ដើម្បីគាំទ្រឱ្យមានគម្រោងកម្មវិធី ស្ដីពី "**ការអប់រំសន្តិភាព និងដកហូតអាវុធ**" នេះឡើង ។ គម្រោងកម្មវិធី គឺជាកម្មវិធីសាកល្បងមួយដែលផ្ដល់ឱ្យយុវជននូវជម្រើសផ្សេងៗក្រៅពីការប្រើប្រាស់អាវុធ និងឥរិយាបថហិង្សាសម្រាប់ការដោះស្រាយបញ្ហា ។ គម្រោងកម្មវិធីនេះមានគោលបំណងធ្វើឱ្យមាននិរន្តភាពនៃការដកហូតអាវុធធុនតូចតាមរយៈកម្មវិធី ការអប់រំសន្តិភាព និងដកហូតអាវុធ និងជួយប្រែក្លាយសង្គមពីវប្បធម៌ហិង្សាទៅជាវប្បធម៌សន្តិភាព ។ គម្រោងនេះមិនមែនអនុវត្តតែក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែបានអនុវត្តក្នុងប្រទេសមួយចំនួនទៀតដូចជា អាល់បានី (អឺរ៉ុប) នីហ្សេរ (អាហ្វ្រិក) និងប៉េរូ (អាមេរិកខាងត្បូង) ។

គម្រោងកម្មវិធីនេះត្រូវបានឧបត្ថម្ភដោយសេវាអភិវឌ្ឍន៍របស់អាឡឺម៉ង់ (German Development Service) និងគម្រោងគ្រប់គ្រងអាវុធធុនតូចរបស់កិច្ចសហប្រតិបត្តិការបច្ចេកទេសអាឡឺម៉ង់ផងដែរ (GTZ) ។

យើងសូមថ្លែងអំណរគុណចំពោះ Hague Appeal for Peace ជាពិសេស លោកស្រី Cora Weiss និងលោកស្រី Betty Burkes សម្រាប់ការផ្ដល់គំនិត និងយោបល់ដ៏មានតម្លៃបំផុតសម្រាប់គម្រោងកម្មវិធីទាំងមូល ។ ការងាររបស់បុគ្គលិកអង្គការកាត់បន្ថយអាវុធ (PE team) កាន់តែមានគុណភាពប្រសើរឡើង ដោយដំណើរទស្សនកិច្ចរបស់លោកស្រី Yamane Kazuyo ជំនាញការអប់រំសន្តិភាពនៃ Grass Roots House និងជាសាស្ត្រាចារ្យនៃសកលវិទ្យាល័យ Kochi University ប្រទេសជប៉ុន ។

សូមអរគុណលោក Michael Cassandra ប្រធានគ្រប់គ្រងព័ត៌មាន និងទិន្នន័យសាខារបស់នាយកដ្ឋាននៃកិច្ចការដកហូតអាវុធរបស់អង្គការសហប្រជាជាតិ (UNDDA) ចំពោះចំណាប់អារម្មណ៍ផ្ទាល់របស់លោក និងការគាំទ្រកមូលនិធិសម្រាប់ការងារនេះ ។

នៅថ្នាក់ជាតិ យើងសូមកោតសរសើរចំពោះការចូលរួមរបស់លោកស្រី **តី សំបូរ** (Tey Sambo) មកពី Culture of Peace Focal Point, UNESCO ចំពោះការចែករំលែកមេរៀនដែលបានទទួលពីគម្រោង Living Values Project និងកិច្ចការស្ដីពីការអប់រំសន្តិភាពក្នុងអតីតតំបន់ខ្មែរក្រហម ។

ការងារនៅខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំង មិនអាចសម្រេចបានទេ បើគ្មានការគាំទ្រពីលោក **ស៊ូ តីមទ្រី** ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ និងលោកស្រី **ផាត់ ធនី** ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ឆ្នាំង ។

លោក **សំ សុវណ្ណតារា** និងលោក **ម៉ៅ វាសនា** មន្ត្រីនៃនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ និងលោក **លី ប៊ុនហៃ** លោក **អៀ ពៅ** គ្រូសីលធម៌-ពលរដ្ឋវិជ្ជាមកពីខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំង ក៏ដូចជា លោកគ្រូ-អ្នកគ្រូ សីលធម៌-ពលរដ្ឋវិជ្ជា ជាសមាជិកនៃការប្រជុំផ្តល់ព័ត៌មានត្រលប់ បានផ្តល់យោបល់ដ៏មានសារៈសំខាន់សម្រាប់កែលំអកម្មវិធីសិក្សានេះ ។ យើងសូមវាយតម្លៃខ្ពស់ចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកគ្រូ-អ្នកគ្រូ ដែលបានរៀបរាប់ខាងលើដែលបានមកចូលរួមក្នុងការប្រជុំរបស់យើង ។

គម្រោងកម្មវិធីការអប់រំសន្តិភាព និងដកហូតអាវុធ ត្រូវបានអនុវត្តដោយៈ

- លោក **ណែប ស៊ីនថៃ** នាយកប្រតិបត្តិ
- លោកស្រី **ហួត ថាវីរ៉ី** មន្ត្រីកម្មវិធីអប់រំផ្សព្វផ្សាយ
- លោក **លឹម មិញ** ជំនួយការកម្មវិធីអប់រំផ្សព្វផ្សាយ
- លោក **មាស ស៊ិត** អ្នកសម្របសម្រួលកម្មវិធីប្រចាំ ខេត្តកំពង់ឆ្នាំង
- លោក **សំរិទ្ធ រស់** អ្នកសម្របសម្រួលកម្មវិធីប្រចាំ ខេត្តកំពង់ធំ
- កញ្ញា **លឹម សុខជា** អ្នកស្ម័គ្រចិត្ត
- លោក **ម៉ារកូស ស្មីត** ទីប្រឹក្សាកម្មវិធីអប់រំផ្សព្វផ្សាយ
- លោកស្រី **អេម៉ា លេស្លី** ទីប្រឹក្សាកម្មវិធីសិក្សាការអប់រំសន្តិភាព និងដកហូតអាវុធ

# របៀបប្រើសៀវភៅ

សៀវភៅនេះត្រូវបានចងក្រងឡើងនៅចំពេលមួយដែលប្រវត្តិសាស្ត្រនៃការអប់រំរបស់កម្ពុជា បានផ្តល់សម្ភារឧបទ្ទេសជាស្តង់ដាបានត្រឹមតែក្តារខៀន និងដីសតែប៉ុណ្ណោះ សម្រាប់ជាជំនួយដល់លោកគ្រូ-អ្នកគ្រូក្នុងការបង្រៀន មានន័យថាលទ្ធភាពសម្រាប់ការបង្រៀនមេរៀនឱ្យបានល្អត្រូវបានស្ថិតនៅក្នុងព្រំដែនមួយ ។ ជាការពិតណាស់ ទាំងអ្នកសរសេរកម្មវិធីសិក្សា និងលោកគ្រូ-អ្នកគ្រូ តម្រូវឱ្យមានគំនិតច្នៃប្រឌិតច្រើនថែមទៀតដើម្បីឱ្យអ្នកសិក្សា និងមិត្តអ្នកអាន អាចស្វែងយល់ពីគំនិតរបស់ពួកគេបាន ។

តើគំនិតនោះជាអ្វី? គំនិតនោះគឺជាអ្វីមួយដែលបដិសន្ធិឡើងស្របពេលជាមួយគ្នាដែលមានដូចជាៈ របៀបរស់នៅជាមួយគ្នាដោយគ្មានអំពើហិង្សា របៀបដោះស្រាយទំនាស់ប្រកបដោយលទ្ធផលខ្ពស់ របៀបធ្វើឱ្យប្រសើរដល់ទំនាក់ទំនង តាមរយៈការប្រាស្រ័យទាក់ទងគ្នាមួយដ៏ប្រសើរជាងមុន របៀបធ្វើការសម្រេចចិត្ត និងការឱ្យតំលៃដល់គំនិតខុសៗគ្នារបស់អ្នកដទៃ ។ សៀវភៅនេះមានបំណងផងដែរ ក្នុងការធ្វើឱ្យសិស្សានុសិស្សយល់ដឹងពីលទ្ធផលជាអវិជ្ជមាននៃការយកអាវុធមកដោះស្រាយបញ្ហាក្នុងសង្គម បញ្ហាទាក់ទងនឹងខ្លួនគេ ឬក៏ច្បាប់ទម្លាប់ជាដើម ។ ដូច្នេះមេរៀននីមួយៗត្រូវបានចងក្រងឡើងដោយផ្តោតលើទិដ្ឋភាពទាំងអស់នេះដែលទាក់ទងនិងសន្តិភាព ការដោះស្រាយទំនាស់ និងការអប់រំពីការដកហូតអាវុធ ។

មេរៀននីមួយៗត្រូវបានបែងចែកជា **សេចក្តីផ្តើម វត្ថុបំណង ចំណេះដឹង ឥរិយាបថ ជំនាញ និងសម្ភារឧបទ្ទេស** សម្រាប់ជំនួយដល់ការបង្រៀន **រយៈពេល** សម្រាប់មេរៀននីមួយៗ និង**លំនាំនៃការបង្រៀន** ។

កម្មវិធីសិក្សានេះមានសារៈសំខាន់ ព្រោះថា មេរៀននីមួយៗដែលបានរៀបចំឡើងនោះមានទំនាក់ទំនងភ្ជាប់ជាមួយមេរៀនសីលធម៌-ពលរដ្ឋវិជ្ជារបស់ក្រសួងអប់រំយុវជន និងកីឡា ។ កម្មវិធីសិក្សានេះត្រូវបានចងក្រងឡើងដោយយកចិត្តទុកដាក់ជាទីបំផុត ដើម្បីធ្វើឱ្យទៅជាជំនួយបន្ថែមដល់កម្មវិធីសិក្សាជាតិ ដោយសង្ឃឹមថានៅថ្ងៃណាមួយ កម្មវិធីសិក្សារបស់អង្គការ និងអាចត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាជាតិជាមិនខាន ។

"**ប្រាំនាទីដើម្បីសន្តិភាព**" ជាប្រធានបទទីមួយនៃកម្មវិធីសិក្សានេះ ដែលជាសម្រង់ពាក្យសំដីរបស់អ្នកកសាងសន្តិភាពផ្សេងៗនៅលើពិភពលោក ។ ប្រធានបទនេះត្រូវបានចងក្រងឡើងដើម្បីជួយដល់អ្នកកសាងសន្តិភាព មាន នាយក នាយិកាសាលា គ្រូបង្រៀន ដើម្បីយកទៅថ្លែងនៅក្នុងអង្គប្រជុំ ឬនៅថ្ងៃបុណ្យជាតិនានានៅតាមសាលារៀន ។ សម្រង់សេចក្តីទាំងនេះក៏អាចយកទៅប្រើនៅក្នុងផ្នែកមួយនៃសុន្ទរកថា ឬការចាប់ផ្តើមមេរៀនរបស់លោកគ្រូ-អ្នកគ្រូនៅក្នុងថ្នាក់សម្រាប់ធ្វើការឆ្លុះបញ្ចាំងដល់សិស្សានុសិស្ស ។

មានកម្រងមេរៀនមួយដែលផ្តោតលើរូបភាពផ្ទាំងធំរបស់អង្គការកាត់បន្ថយអាវុធ ។ មេរៀនទាំងនេះជាជម្រើសមួយ ប៉ុន្តែត្រូវការពន្យល់ឱ្យបានស៊ីជំរៅនូវអត្ថន័យនៃរូបភាពផ្ទាំងធំ សម្រាប់ការដកហូតអាវុធនៅក្នុងប្រទេសកម្ពុជា ។ រូបភាព

ផ្ទាំងធំទាំងនេះអាចរកបាននៅក្នុងសាលារៀន ឬអាចស្នើសុំពីអង្គការកាត់បន្ថយអាវុធ (សូមទំនាក់ទំនងតាមអាស័យដ្ឋានដូចខាងក្រោម)។ អង្គការកាត់បន្ថយអាវុធ មានបំណងបញ្ជូនធនធានមនុស្សដើម្បីថ្លែងសុន្ទរកថាក្នុងថ្នាក់រៀន ឬបណ្តុះបណ្តាលលោកគ្រូ-អ្នកគ្រូឱ្យចេះប្រើសម្ភារឧបទ្ទេសទាំងនោះផងដែរ។

អ្នកអាចមានលទ្ធភាពទទួលយកបាននូវធនធានបន្ថែមមួយចំនួនដូចជា: ការសែតវីដេអូ ផ្ទាំងគំនូរផ្សព្វផ្សាយពីអង្គការកាត់បន្ថយអាវុធ ដែលមានទីតាំងនៅផ្ទះលេខ ៩៥ មហាវិថីព្រះសុធារស សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា។

E-mail: wgwr@online.com.kh

ទូរស័ព្ទ : (៨៥៥) ២៣ ២២២ ៤៦២

អ៊ីនធឺណែត: www.wgwr.org

# ប្រាំនាទីមានប្រយោជន៍សម្រាប់សន្តិភាព

**មេរៀននេះផលិតឡើងសម្រាប់ទុកប្រើក្នុងពេលជួបជុំគ្នានៅសាលារៀន ពេលប្រជុំ និងបុណ្យជាតិផ្សេងៗ**

នៅក្នុងផ្នែកនេះ គឺត្រូវបានចងក្រងឡើងដើម្បីជួយដល់អ្នកកសាងសន្តិភាព មាន នាយក/នាយិកាសាលា គ្រូបង្រៀន ដើម្បីយកទៅថ្លែងនៅក្នុងអង្គប្រជុំ ឬនៅថ្ងៃបុណ្យជាតិនានានៅតាមសាលារៀន។ សម្រង់សេចក្តីទាំងនេះក៏អាចយកទៅប្រើនៅក្នុងផ្នែកមួយនៃសុន្ទរកថា ឬការចាប់ផ្តើមមេរៀនរបស់លោកគ្រូ-អ្នកគ្រូ នៅក្នុងថ្នាក់សម្រាប់ធ្វើការឆ្លុះបញ្ចាំងដល់សិស្សានុសិស្ស។

ជានិច្ចកាលយើងមិនអាចចំណាយមេរៀនមួយទាំងមូល ដើម្បីបង្រៀនសិស្សពីសន្តិភាពបានទេ។ ជួនកាលយើងត្រូវការពេលតែប្រាំនាទីប៉ុណ្ណោះដើម្បីអប់រំសិស្សអំពីសន្តិភាព។ មេរៀនខាងក្រោមនេះត្រូវបានចងក្រងឡើងដើម្បីជាការឆ្លុះបញ្ចាំងមួយយ៉ាងខ្លីដោយគ្រាន់តែចំណាយពេលតែ៥នាទីតែប៉ុណ្ណោះ។ អ្នកអាចប្រើមេរៀនទាំងនេះក្នុងការជួបប្រជុំនៅសាលារៀន នៅមុនពេលចាប់ផ្តើមមេរៀន ឬក៏សម្រាប់ថ្ងៃបុណ្យជាតិ ដែលប្រារព្ធធ្វើនៅសាលារៀន ដូចជា បុណ្យទិវាសិទ្ធិមនុស្សអន្តរជាតិ ទិវាសិទ្ធិកុមារ បុណ្យអុំទូក ទិវារំលឹកកិច្ចព្រមព្រៀងក្រុងប៉ារីសជាដើម។

នៅក្នុងសំដីរបស់ *រូស៍ ហ្វីហ្សែល* (Ruth Fishel)

ក្នុងមួយថ្ងៃមាន ១៤៤០នាទី ត្រូវជា ៨៦៤០០វិនាទី
ខ្ញុំអាចរួមចំណែកប្រាំនាទី សម្រាប់សន្តិភាពពិភពលោក
ខ្ញុំអាចរួមចំណែក ៣០០វិនាទី សម្រាប់សន្តិភាពពិភពលោក
ការធ្វើយ៉ាងដូច្នេះបានបន្សល់ពេលឱ្យខ្ញុំ ១៤៣៥នាទីដែរ
ការធ្វើយ៉ាងដូច្នេះបានបន្សល់ពេលឱ្យខ្ញុំ ៨៦១០០វិនាទីដែរ



*ប្រាំនាទីដើម្បីសន្តិភាព ដោយ រូស៍ ហ្វីហ្សែល* (Ruth Fishel)

ប្រសិនបើយើងចង់បានសន្តិភាពពិតប្រាកដ យើងត្រូវចាប់ផ្តើមជាមួយកុមារ

(Gandhi ជាសកម្មជនអហិង្សាជនជាតិឥណ្ឌា)

.................................................................................................................

**សន្តិភាព** មិនមែនមានន័យត្រឹមថា កន្លែងដែលគ្មានសម្លេង គ្មានបញ្ហា ឬការងារធ្ងន់ធ្ងរនោះទេ ប៉ុន្តែមានន័យថា សន្តិភាពស្ថិតនៅចំកណ្តាលវត្ថុទាំងនោះ ហើយអាចស្ងប់ស្ងាត់ក្នុងបេះដូងរបស់អ្នក។

(អនាមិក)

.................................................................................................................

**សន្តិភាព** គឺជាជំនឿដែលអ្នកមាននៅក្នុងខ្លួន។ វាគឺជាអ្វីដែលអ្នកចង់ឱ្យវាស្ថិតនៅក្នុងខ្លួនរបស់អ្នក វាជាអ្វីដែលធ្វើឱ្យអ្នកនិងខ្ញុំនៅជាមួយគ្នា។ សន្តិភាពមានអាថ៌កំបាំងជាច្រើន។ សន្តិភាពស្ថិតនៅជាមួយមនុស្សគ្រប់រូប មិនថា អ្នកនោះមានសម្បុរខ្មៅ ស ក្រហម ឬលឿងអ្វីទេ។ សន្តិភាព គឺជាជំរើសមួយដ៏អស្ចារ្យ។

សិស្សម្នាក់រៀនថ្នាក់ទី ៥ នៅសហរដ្ឋអាមេរិក

...

"កុំមើលស្រាលឱ្យសោះថា គ្មានបុគ្គលណាម្នាក់មានសមត្ថភាពផ្លាស់ប្តូរពិភពលោកបាន"

( គន្ធី Gandhi )

...

មនុស្សនិយាយថា ការដើរលើទឹកគឺជាអព្ភូតហេតុ ប៉ុន្តែសម្រាប់ខ្ញុំការដើរប្រកបដោយសន្តិភាពនៅលើផែនដីគឺជាអព្ភូតហេតុពិតៗ

( ព្រះតេជគុណ ថាច់ ញឹតហាន់ ព្រះសង្ឃវៀតណាម)

...

យើងមិនអាចផ្លាស់ប្តូរអតីតកាលបានមែន ប៉ុន្តែអាចកែប្រែឥរិយាបថរបស់យើងចំពោះអតីតកាលបាន។ ចូរដកទាំងឫសនូវភាពមានទោស និងដាំនូវការលើកលែងទោស។ ហែកចោលឱ្យអស់នូវភាពក្រអឺតក្រទម និងដាំនូវភាពសុភាពរាបសារ។ ចូរប្តូរយកសេចក្តីស្រលាញ់ពីសេចក្តីស្អប់ តាមរយៈនេះគឺត្រូវធ្វើឱ្យបច្ចុប្បន្នមានភាពប្រសើរ ធ្វើឱ្យអនាគតពោរពេញដោយសេចក្តីសង្ឃឹម។

(Maya Angelou សកម្មជនសម្រាប់សិទ្ធិមនុស្សនៅសហរដ្ឋអាមេរិក)

...

**សន្តិភាព** គឺជាបរិស្ថានដែលរាល់ទំនាស់ត្រូវបានដោះស្រាយប្រកបដោយភាពអហិង្សា និងជាកន្លែងដែលប្រជាពលរដ្ឋមានសិទ្ធិសេរីភាពក្នុងការរស់នៅ គ្មានការកេងប្រវ័ញ្ចយកផលប្រយោជន៍ពីអ្នកដទៃ។ ដូចនេះប្រជាពលរដ្ឋអាចរស់នៅប្រកបដោយសក្តានុពលដ៏ពេញលេញ។

(Gerard Vanderhaar សាស្ត្រាចារ្យកាតូលិក សហរដ្ឋអាមេរិក)

...

ការធ្វើដំណើររបស់យើងដើម្បីសន្តិភាពចាប់ផ្តើមនៅថ្ងៃនេះ និងជារៀងរាល់ថ្ងៃ។ ជំហាននីមួយៗជាការបួងសួង ជំហាននីមួយៗជាសមាធិ។ ជំហាននីមួយៗនោះនឹងស្ថាបនាបាននូវស្ពានមួយ។

( សម្តេចព្រះមហាឃោសានន្ទ ព្រះសង្ឃខ្មែរ)

...

**សន្តិភាព** និងការស្ងប់ស្ងាត់គឺជាមាសរាប់ពាន់ដុំ

(សុភាសិតប្រទេសចិន)

...

**សន្តិភាព** គឺជាពេលវេលាសម្រាប់ធ្វើអ្វីៗគ្រប់បែបយ៉ាងដែលបំរើប្រយោជន៍របស់មនុស្សគ្រប់រូប រួមទាំង ចំណីអាហារចិញ្ចឹមជីវិត ទ្រព្យសម្បត្តិ ការសិក្សា សុភមង្គល ផាសុខភាពជាដើម។ សង្គ្រាមបំផ្លាញអស់ និង ធ្វើឱ្យខ្ចះខ្ចាយនូវអ្វីៗគ្រប់បែបយ៉ាងដែលមានមកពីមុន។

(សុភាសិតប្រទេសដេនម៉ាក)

.............................................................................................................................

សន្តិភាពដែលពោរពេញដោយព្រួនង់នៅក្នុងដៃ គឺជាសង្គ្រាម

(សុភាសិតព័រទុយហ្គាល)

.............................................................................................................................

សន្តិភាពមិនមែនអវត្តមាននៃទំនាស់ទេ ប៉ុន្តែវាជាវត្តមាននៃយុត្តិធម៌

(ម៉ាទីន លូធឺ឴ ឃីង សកម្មជនសិទ្ធិមនុស្សនៅសហរដ្ឋអាមេរិក)

.............................................................................................................................

ទីកន្លែងណាដែលខ្ញុំនៅ តែងតែមានសន្តិភាពតាមជាប់ជាមួយខ្ញុំ ពីព្រោះទីណាគ្មានសន្តិភាព ទីនោះគ្មានខ្ញុំទេ

(កំណាព្យសន្តិភាពរបស់សិស្សអាយុ១៤ឆ្នាំម្នាក់នៅប្រទេសក្រូអាត អ៊ឺរ៉ុប)

.............................................................................................................................

- ទុក្ខវេទនារបស់ប្រជាជនកម្ពុជាមានទំហំធំធេងណាស់
- មើលឃើញទុក្ខវេទនានេះ នាំឱ្យមានមហាករុណា
- មហាករុណា នាំឱ្យមានចិត្តស្ងប់
- ចិត្តស្ងប់ នាំឱ្យបុគ្គលសុខសាន្ត
- បុគ្គលសុខសាន្ត នាំឱ្យគ្រួសារសុខសាន្ត
- គ្រួសារសុខសាន្ត នាំឱ្យសហគមន៍សុខសាន្ត
- សហគមន៍សុខសាន្ត នាំឱ្យជាតិសុខសាន្ត
- ជាតិសុខសាន្ត នាំឱ្យពិភពលោកបានសុខសាន្ត
- សូមសព្វសត្វទាំងអស់បានរស់នៅក្នុង សន្តិភាពសុភមង្គលតរៀងទៅ

(សម្តេចព្រះមហាឃោសានន្ទ ព្រះសង្ឃខ្មែរ)

.............................................................................................................................

ជំពូកទី ១

# ប្រធានបទនៃមេរៀន

## ជំពូក

## ១

# ការប្រាស្រ័យទាក់ទង និង ការទំនាក់ទំនងជាមួយអ្នកដទៃ

# សញ្ញាណខ្លួនផ្សេងៗគ្នារបស់យើង

ក្នុងជីវិតរស់នៅរបស់យើង យើងមានបទពិសោធន៍ផ្សេងៗគ្នាជាច្រើន ។ ប្រសិនបើយើងមកពីគ្រួសារអ្នកមាន ការយល់ឃើញរបស់យើងអំពីពិភពលោក នឹងខុសគ្នាពីយើងមកពីគ្រួសារអ្នកក្រ ។ បើយើងធំដឹងក្តីក្នុងទីក្រុង យើងនឹងឃើញវត្ថុទាំងឡាយប្លែកៗគ្នាទៅនឹងទស្សនៈយល់ឃើញរបស់យើងដែលជាអ្នកធំដឹងក្តីនៅជនបទ ។ បើយើងជាស្រី យោបល់ និងបទពិសោធន៍របស់យើង ខុសប្លែកពីបទពិសោធន៍របស់មនុស្សប្រុស ។ ភាពខុសគ្នាទាំងនេះ នឹងប៉ះពាល់ដល់មតិ និងគំនិតរបស់យើងរាល់គ្នា ។ មេរៀននេះព្យាយាមបង្ហាញដល់សិស្សានុសិស្សអំពីហេតុដែលនាំឱ្យយើងទាំងអស់គ្នា មានទស្សនៈផ្សេងៗគ្នា គឺអាស្រ័យលើបទពិសោធន៍នៃការរស់នៅផ្ទាល់របស់យើង ។ ទស្សនៈយល់ឃើញខុសៗគ្នាលើបញ្ហាអ្វីមួយនេះ ហើយដែលអាចដឹកនាំយើងទៅកាន់ទំនាស់យ៉ាងងាយស្រួល ប្រសិនបើយើងមិនព្យាយាមស្វែងយល់អំពីគ្នាទៅវិញទៅមកនោះទេ ។

**វត្ថុបំណង** :

ចៈ សិស្សយល់ពីបទពិសោធន៍ក្នុងជីវិតដែលមានឥទ្ធិពលរបៀបណាដល់សញ្ញាណខ្លួន គំនិត និងយោបល់ផ្សេងៗ

បៈ សិស្សអាចមានទំនាក់ទំនងកាន់តែប្រសើរជាមួយមិត្តភក្តិរបស់គេជាពិសេសនៅពេលគេប្រឈមមុខនឹងគ្នា ឬមានគំនិតខ្វែងគ្នា ឬខុសគ្នា

ឥៈ សិស្សនឹងចេះគោរពគំនិត និងយោបល់ផ្សេងៗ

**រយៈពេល** : ៣០ នាទី

**សម្ភារ** : រឿងបក្សីពីរក្បាល



## បក្សីពីរក្បាល

មានបក្សីពីរក្បាល បានហើរមកទំលើដើមមៀនព្រៃមួយដើមយ៉ាងសប្បាយរីករាយក្នុងពេលជាមួយគ្នា ។ បក្សីមួយទំលើមែកខ្ពស់បំផុតនៃដើមមៀននោះ រីឯបក្សីមួយទៀតបានទំនៅពីក្រោមប្រគាបមែកពីរដែលប្រសព្វគ្នា ។ បក្សីដែលទំនៅមែកខ្ពស់បំផុតបានបន្លឺវាចាថា "អូ! ស្លឹកឈើអ្វីក៏មានពណ៌បៃតងស្រស់ស្អាតម្ល៉េះទេ!"

បក្សីដែលទំមែកខាងក្រោមបានចាត់ទុកសម្តីនេះថាជាការបង្អៀងដល់ខ្លួន ដូច្នេះក៏ឆ្លើយតបទាំងខឹងច្រឡោតថា "ឯងខ្វាក់ទេឬ បានជាឯងមើលមិនឃើញថា ស្លឹកឈើនេះមានពណ៌ស?" បក្សីនៅខាងលើមិនអស់ចិត្តនិងសម្តីនេះសោះ ក៏ឆ្លើយតបវិញថា "តាមពិតអ្នកឯងទេដែល

ខ្វាក់នោះ! ស្លឹកឈើទាំងនេះមានពណ៌បៃតង" ។ បក្សីដែលនៅខាងក្រោមឆ្លើយតបដោយសើចចំអកឡើងថា "ខ្ញុំហ៊ានភ្នាល់ដាក់រោមកន្ទុយរបស់ខ្ញុំថា ស្លឹកឈើមានពណ៌ស ឯងមិនដឹងអ្វីទាល់តែសោះមែន" ។ បក្សីនៅខាងលើខឹងខ្លាំងណាស់ក៏លោតហក់ចុះក្រោមដោយមិនចាំបាច់គិតច្រើនដង មកទំលើមែកដែលគូបដិបក្ខរបស់វាកំពុងទំដើម្បីផ្តល់មេរៀនឱ្យបក្សីនោះ ។ បក្សីមួយទៀតបានឃើញហើយ ក៏មិនហើរចេញទៅណា ប៉ុន្តែវាទាំងពីរបានស្ថិតនៅជិតគ្នា ភ្នែកសម្លក់គ្នាទៅវិញទៅមក ។ ស្លាបរបស់ពួកវាបានបះឡើងជ្រោងដោយកំហឹង ។ ជាទម្លាប់របស់បក្សីវាតែងងើយមុខមើលទៅលើមុននឹងជល់គ្នា ។ រំពេចនោះស្រាប់តែបក្សីដែលចុះពីទីខ្ពស់និយាយយ៉ាងភ្ញាក់ផ្អើលថា "អូហ៍ចំឡែកមែនទែន! ចូរអ្នកមើលទៅស្លឹកឈើនេះ វាមានពណ៌សដូចឯងថាមែន!" ហើយវាក៏អញ្ជើញមិត្តវាទៅខាងលើម្តង" តោះទៅមើលស្លឹកឈើកន្លែងខ្ញុំឯលើម្តង!" ពួកវាក៏នាំគ្នាហើរទៅមែកឈើដែលខ្ពស់បំផុតនៃដើមឈើនោះ ។ ពេលនោះពួកគេស្រែកដំណាលគ្នាឡើងថា "មើលចុះ! ស្លឹកឈើខាងណេះមានពណ៌បៃតងមែនហ្ន៎!"

*និពន្ធដោយ H.Otero,from “Parabolas en san de paz”*

**វាក្យសព្ទ :**

**សញ្ញាណ្ណ :** ទស្សនៈយល់ឃើញបញ្ហាមួយ ឬមនុស្សណាម្នាក់ ឬរបៀបដែលយើងមើលឃើញពិភពលោក ។ សញ្ញាណ្ណរបស់មនុស្សម្នាក់ៗផ្សេងៗពីគ្នា ។ សញ្ញាណ្ណរបស់យើងត្រូវបានកកើតឡើងដោយសារឪពុកម្តាយយើង ដោយសារការអប់រំ ទីកន្លែងរស់នៅ មនុស្សដែលយើងស្គាល់ អ្វីដែលយើងបានអាន អ្វីដែលជាបទពិសោធន៍របស់យើង ។ល។

**ដំណើរការមេរៀន :**

១. គ្រូអានរឿង "**បក្សីពីរក្បាល**" ឱ្យសិស្សស្តាប់

២. **សំណួរបញ្ជាក់:** (តើសិស្សស្តាប់រឿង និងយល់សាច់រឿងបានប៉ុណ្ណា) ដោយប្រើសំណួរដូចខាងក្រោម:

ក. ហេតុអ្វីបានជាបក្សីដែលនៅខាងលើមិនសប្បាយចិត្ត?

ខ. តើបក្សីមួយទៀតបាននិយាយពីអ្វីដែលធ្វើឱ្យស្ថានការណ៍កាន់តែធ្ងន់ធ្ងរទៅបែបនេះ?

គ. តើបក្សីទាំងពីរបានឃើញអ្វីនៅតាមទីកន្លែងដែលវាទំ? (**ចម្លើយចូលរួម:** បក្សីនីមួយៗមើលឃើញស្លឹកឈើមានពណ៌ប្លែកៗពីគ្នាទៅតាមគំហើញផ្ទាល់ខ្លួន ។ ដូច្នេះអ្វីដែលបក្សីនីមួយៗមើលឃើញសុទ្ធតែត្រឹមត្រូវតាមកន្លែងវារៀងៗខ្លួន )

ឃ. តើបក្សីទាំងពីរគួរឆ្លើយយ៉ាងដូចម្តេច ដើម្បីឱ្យពួកគេអាចជៀសវាងមិនជល់គ្នាបាន?

៣. គ្រូសួរសំណួរពិភាក្សាដូចខាងក្រោម:

ក. តើយើងអាចរៀនសូត្រអ្វីខ្លះពីរឿងនេះ? (**ចម្លើយចូលរួម:** ព្រោះយើងទាំងអស់គ្នាមានភាពខុសៗគ្នាយើងមើលឃើញស្ថានភាព បញ្ហា និងពិភពលោកក៏ផ្សេងគ្នាដែរ) ។

ខ. តើអ្នកធ្លាប់មានទំនាស់ជាមួយនរណាម្នាក់ ពីព្រោះតែមានគំនិតខុសគ្នាពីបញ្ហាអ្វីមួយឬទេ? ឬដោយសារអ្នកទទួលបានព័ត៌មានប្លែកពីប្រធានបទដែលដូចគ្នា?

គ. តើអ្នកដោះស្រាយវាយ៉ាងដូចម្តេច? តើយើងអាចដោះស្រាយទំនាស់ដោយសារទស្សនៈខុសគ្នាបានយ៉ាងដូចម្តេច?

៤. **សន្និដ្ឋាន :**

យើងទាំងអស់គ្នាមើលឃើញពិភពលោកផ្សេងៗពីគ្នា។ ក្នុងជីវិតផ្ទាល់ខ្លួន ប្រសិនបើយើងយល់ថា សញ្ញាណទូទៅរបស់យើងដែលបានមកពីបទពិសោធន៍ក្នុងជីវិតផ្ទាល់ខ្លួន ធ្វើឱ្យយើងមានការយល់ឃើញខុសគ្នានោះ វាកាន់តែងាយស្រួលស្វែងយល់ពីគ្នាទៅវិញទៅមក។ យើងត្រូវចំណាយពេលស្តាប់គំនិតគេ និងស្វែងយល់ពីគំនិតគ្នាទៅវិញទៅមកមុននឹងបង្កទំនាស់ជាមួយអ្នកនោះ។

*មេរៀននេះត្រូវគ្នានឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១១ តម្លៃនៃបុគ្គលម្នាក់ៗ នៃក្រសួងអប់រំយុវជន និងកីឡា*

# ដំណោះស្រាយអំពីបុរេនិច្ឆ័យ

ជារៀងរាល់ថ្ងៃ យើងធ្វើការវិនិច្ឆ័យអ្នកដទៃ ដែលតាមធម្មតា ការវាយតម្លៃនោះមានលក្ខណៈអវិជ្ជមានដោយផ្អែកលើព័ត៌មានមិនពិត ។ ការវាយតម្លៃទាំងនោះបណ្តាលឱ្យយើងរើសអើងចំពោះអ្នកដទៃ ។ ការវាយតម្លៃបណ្តាលឱ្យយើងប្រព្រឹត្តមិនសមរម្យ ចំពោះអ្នកដទៃ ដោយមិនមានទំនាក់ទំនងជាមួយគេឱ្យសមស្រប និងស្មើភាពគ្នាឡើយ ។ មេរៀននេះបង្ហាញសិស្សនូវការរើសអើង ដែលពួកគេមានចំពោះសិស្សដទៃ ហើយនិងរបៀបដែលគេអាចផ្លាស់ប្តូរឥរិយាបថរើសអើងទាំងនេះចេញ ។

**វត្ថុបំណង :**

ចៈ សិស្សយល់ពីអត្ថន័យនៃពាក្យបុរេនិច្ឆ័យ និងរបៀបដែលនាំឱ្យមានទំនាស់

បៈ សិស្សអាចកំណត់ និងអនុវត្តយុទ្ធសាស្រ្តសម្រាប់ដោះស្រាយជាមួយបុរេនិច្ឆ័យនៅក្នុងសហគមន៍សាលារៀនរបស់ពួកគេ

ឥៈ សិស្សនឹងពិនិត្យមើលបុរេនិច្ឆ័យផ្ទាល់ខ្លួន ហើយដឹងថាប៉ះពាល់ដល់ទំនាក់ទំនងជាមួយអ្នកដទៃរបៀបណា

**រយៈពេល :** ៣០ នាទី

**សម្ភារ :** រឿង៦ ស្តីពីបុរេនិច្ឆ័យ

**វាក្យសព្ទ :**

**បុរេនិច្ឆ័យ:** គឺជាគំនិតដែលបង្កឡើងចំពោះនរណាម្នាក់ ដោយពុំមានហេតុផលច្បាស់លាស់ ឬទិពិសោធន៍គ្រប់គ្រាន់ ។ ជាទូទៅគំនិតទាំងនេះ ច្រើនតែមានលក្ខណៈអវិជ្ជមាន ។ **ឧទាហរណ៍:** នៅពេលនរណាម្នាក់មិនចូលចិត្តនរណាម្នាក់ទៀតដោយសារតែសម្បុរ ស្បែក សំលៀកបំពាក់ ឬគ្រួសាររបស់គេ ។

**ការរើសអើង:** ការប្រព្រឹត្តចំពោះនរណាម្នាក់ខុសប្លែកពីមនុស្សដទៃទៀតដោយយោងលើការវាយតម្លៃចំពោះអ្នកនោះ ។ **ឧទាហរណ៍:** ក្មេងស្លៀកសំលៀកបំពាក់កខ្វក់មិនត្រូវបានគេអនុញ្ញាតិឱ្យចូលសាលា (ការប្រកាន់រើសអើងចំពោះអ្នកក្រ) ឬមនុស្សកាន់សាសនាផ្សេងគ្នាមិនត្រូវបានគេអនុញ្ញាតឱ្យបោះឆ្នោត (ការរើសអើងសាសនា)

**ការនិយមទំលាប់:** គឺជាមតិយោបល់ ឬគំនិតមួយរបស់ក្រុមមួយ ដោយគ្មានការគោរពដល់ភាពខុសៗគ្នារបស់អ្នកដទៃ ។

**ដំណើរការនៃមេរៀន**

១. ណែនាំបង្ហាញទស្សនៈទាននៃពាក្យការរើសអើងបុរេនិច្ឆ័យ (មើលវាក្យសព្ទខាងលើ)

២. គ្រូឱ្យសិស្សអានរឿងខ្លីចំនួន៦



- ថ្ងៃមួយកញ្ញា **រតនា** បានជិះម៉ូតូដួលនៅលើចិញ្ចើមផ្លូវ ។ កែងជើងនាងឈឺយ៉ាងខ្លាំង ពេលនោះមាននារីបំរើស្រាបៀរដ៏ស្រស់ស្អាតម្នាក់ មកជួយលើកនាងឡើង ហើយបាននិយាយថា "បងនឹងជួយគ្រាប្អូនឱ្យមកអង្គុយលើកៅអីថ្មនេះដើម្បីមើលរបួសឱ្យប្អូន" ។ **រតនា** មិនទុកចិត្តស្រីបំរើស្រាបៀរនោះ ហើយឆ្លើយថា ទេ! អរគុណហើយ ខ្ញុំមិនអីឯណា ខ្ញុំអាចជួយខ្លួនឯងបាន ថារួចនាងក៏ដើរខ្ចើច១ ហើយឡើងជិះម៉ូតូចេញទៅទាំងមានឈាមហូរផង ។



- **សារិត** ត្រូវមួយបាល់ចំភ្នែក ហើយអ្វីដែលគេស្មានមិនដល់នោះ គឺត្រង់ដែល **សារិត** បានស្រែកយំហ៊ូ១ឡើង ។ ឃើញដូច្នេះ យុវជនឯទៀតនាំគ្នាសើចគឹល១ ។ **ផល្លា** បានសើចជាមួយគេឯងដែរទោះបីជាវាអាណិត **សារិត** យ៉ាងខ្លាំងក៏ដោយ ។



- យុវជន **វុទ្ធី** ជាអ្នករាំរបាំដ៏អស្ចារ្យម្នាក់ ។ ថ្ងៃមួយលោកគ្រូរបាំបានសំណូមពរឱ្យ **វុទ្ធី** ខំហាត់រាំរបាំនោះ ដើម្បីក្លាយជាអ្នករបាំអាជីព ។ **វុទ្ធី** ចូលចិត្តនឹងគំនិតនោះដែរ ប៉ុន្តែកាន់តែគិតគាត់កាន់តែខ្លាចថា អ្នកដទៃមុខជាសើចចំអកឱ្យគាត់ជាមិនខាន គិតដូច្នេះហើយ គាត់ក៏លះបង់គំនិតឈប់ចង់ហាត់រាំរបាំដែលជាអាជីពដ៏ប្រសើរមួយ និងជាជំនាញដែលគាត់អាចឈោងចាប់បាននោះចោលទៅ ។



- **សុខជា** មិនចេះធ្វើគណិតវិទ្យា ។ នាងខិតខំរៀនបន្ថែមទៀត ប៉ុន្តែចំណាត់ថ្នាក់របស់នាងនៅតែមិនបានប្រសើរសោះ ។ ថ្ងៃមួយលោកគ្រូបានប្រាប់នាងថា មិនអីទេ មិនបាច់ខំប្រឹងក៏បានដែរ ព្រោះតាមធម្មតា សិស្សនារីរៀនគណិតវិទ្យាមិនពូកែអញ្ចឹងហើយ ។



- សិស្សក្រីក្រមួយក្រុមបានសុំឱ្យ **ថាវរី** ចូលក្រុមរបស់គេដើម្បីធ្វើគណិតវិទ្យារួមគ្នា ។ ដោយសារពួកគេស្លៀកពាក់មិនស្អាតបាត **ថាវរី** គិតថា ពួកគេនោះពិតជាមិនឆ្លាតទេ ។ នាងក៏សម្រេចចិត្តចូលរួមជាមួយក្រុមផ្សេងទៀត ។ ជាលទ្ធផល ក្រុមក្មេងស្លៀកពាក់មិនស្អាតបាតនោះ បានចំណាត់ថ្នាក់លេខ១ រីឯនាង **ថាវរី** មិនបានលេខ១ ដូចគេទេ ។



- គ្រួសារ **វ៉ាន្នី** មិនសូវមានលុយកាក់ច្រើនទេ ហើយរស់នៅក្នុងប្លុកមួយផ្សេងពីគ្រួសារ **ពិសាខ**។ នៅពេល **វ៉ាន្នី** អញ្ជើញ **ពិសាខ** ទៅចូលរួមបុណ្យខួបកំណើតនាង **ពិសាខ** សន្មតថា ផ្ទះ **វ៉ាន្នី** រញ៉េរញ៉ៃហើយគគ្រិចគ្មានអនាម័យ ។ ដូច្នេះគាត់មិនទៅចូលរួមទេ ។ ក្រោយមកមានគេប្រាប់គាត់ថាផ្ទះ **វ៉ាន្នី** នៅថ្ងៃខួបកំណើតនោះ ត្រូវបានរៀបចំស្អាតខ្លាំងណាស់ ហើយមានម្ហូបឈ្ងុយឆ្ងាញ់ថែមទៀតផង ។

៣. គ្រូអានរឿងទាំងនោះចប់ ។ គ្រូត្រូវអានរឿងនីមួយៗឡើងវិញ រួចសួរសំណួរដូចខាងក្រោម:

**ក.** តើការរើសអើងនៅក្នុងរឿងនេះទាក់ទងនឹងអ្វី?

**ខ.** តើអ្វីខ្លះជាផលប៉ះពាល់នៃការរើសអើងនេះ?

(**ចម្លើយចូលរួម:** នៅក្នុងរឿងទីមួយ គឺជាការរើសអើងប្រឆាំងនារីលក់ស្រាបៀរ ពីព្រោះសង្គមយល់ឃើញថានារីលក់ស្រាបៀរគឺដូចជាស្ត្រីរកស៊ីផ្លូវភេទដែរ ។ ផលប៉ះពាល់គឺនារីលក់ស្រាបៀរនោះមានអារម្មណ៍មិនល្អ ហើយ **រតនា** ទ្រាំឡើងជិះម៉ូតូចេញទៅទាំងឈឺចាប់ និងមានឈាមហូរផង ។)

៤. **គ្រូសួរសិស្ស**

**ក.** តើការវាយតម្លៃទាំងនោះត្រឹមត្រូវ ឬទេ?

**ខ.** តើអ្នកអាចរកឧទាហរណ៍នៃការរើសអើងដែលយើងឃើញមានក្នុងប្រទេសកម្ពុជាបានឬទេ? (**ចម្លើយចូលរួម:** ប្រជាជនរស់នៅជាមួយអ្នកផ្ទុកមេរោគ HIV/AIDS មនុស្សស្បែកខ្មៅ អ្នកក្រ ក្មេងតាមចិញ្ចើមថ្នល់ ។ល ។)

**គ.** តើអ្នកធ្លាប់ជាជនរងគ្រោះនៃការរើសអើងឬទេ? រងគ្រោះរបៀបណា? តើអ្នកមានអារម្មណ៍ដូចម្តេច?

**ឃ.** តើអ្នកគិតថាការរើសអើងនឹងមានលទ្ធផលអ្វីខ្លះ? តើមនុស្សមានអារម្មណ៍យ៉ាងដូចម្តេច នៅពេលដែលពួកគេត្រូវបានអ្នកផងប្រកាន់រើសអើងនោះ?

៥. **គ្រូពន្យល់:** គ្មាននរណាម្នាក់ចូលចិត្តឱ្យគេរើសអើងយ៉ាងអវិជ្ជមានទេ ។ នៅពេលយើងរើសអើងនឹងនរណាម្នាក់ផ្សេងទៀតនោះគេនឹងមានការឈឺចាប់ ។ ការឈឺចាប់នេះហើយដែលនាំឱ្យមានទំនាស់ ។

៦. **គ្រូសួរសិស្សដើម្បីបំផុសគំនិត:**

**ក.** តើយើងអាចធ្វើអ្វីខ្លះ ដើម្បីលុបបំបាត់បុរេនិច្ឆ័យរបស់យើងផ្ទាល់?

**ខ.** គ្រូសរសេរចម្លើយសិស្សលើក្តារខៀន:

(**ចម្លើយចូលរួម:** ត្រូវទៅជួបមនុស្សដែលខុសប្លែកពីយើងនោះរួចសិក្សាស្វែងយល់ពីការរស់នៅរបស់ពួកគេ ។ ត្រូវរាប់អានចំពោះអ្នកនោះឱ្យបានស្មើភាពគ្នា ហើយត្រូវគិតពិចារណាពីអារម្មណ៍អ្នកនោះ នៅពេលដែលយើងផាត់ពួកគេចេញ ។

**៧. សន្និដ្ឋាន :**

កាលណាយើងវិនិច្ឆ័យយ៉ាងអវិជ្ជមានប្រឆាំងនឹងមនុស្សដទៃអាចបណ្តាលឱ្យអ្នកនោះឈឺចាប់បាន ។ ការធ្វើបែបនេះអាចនាំមកនូវអារម្មណ៍ខឹង និងស្អប់ខ្ពើម ។ កំហឹង និងការស្អប់ខ្ពើមជាគ្រាប់ពូជនៃទំនាស់ និងអំពើហិង្សា ។ ចូរយើងបើកចំហចិត្តគំនិត ហើយប្រព្រឹត្តិចំពោះអ្នកដទៃដូចយើងប្រព្រឹត្តិចំពោះខ្លួនយើងដែរ ។

*មេរៀននេះត្រូវគ្នានឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១០ មេរៀនៈ ការប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ Aids នៃក្រសួងអប់រំយុវជន និងកីឡា*

# ការធ្វើឱ្យអ្នកដទៃឈឺចាប់បណ្តាលមកពីការភ័យខ្លាច

ជួនកាលយើងទទួលអារម្មណ៍ភ័យខ្លាចអ្នកដទៃដោយសារតែយើងមិនស្គាល់ ឬមិនយល់អំពីពួកគេ ជាពិសេសប្រសិនបើពួកគេខុសពីពួកយើង ។ ពួកគេអាចជាអ្នកកាន់សាសនាខុសពីយើង ពួកគេជាជនជាតិភាគតិច ខុសគ្នាអំពីយេនឌ័រ និន្នាការនយោបាយ ឬក៏គ្រាន់តែមានរូបរាងខុសពីយើង ។ នៅពេលដែលយើងទទួលអារម្មណ៍ភ័យខ្លាច យើងនឹងព្យាយាមការពារខ្លួនយើងដោយធ្វើឱ្យអ្នកដទៃឈឺចាប់ ឬរើសអើងចំពោះអ្នកដទៃ ទោះបីវាមិនយុត្តិធម៌សម្រាប់អ្នកដទៃនោះក៏ដោយ ។ អាកប្បកិរិយាទាំងនេះ ជួនកាលដឹកនាំទៅរកអំពើហិង្សា ឬទំនាស់ ។ ប្រសិនបើយើងព្យាយាមយល់អំពីប្រជាពលរដ្ឋរបស់យើង និងគោរពដល់ភាពផ្សេងៗគ្នារវាងពួកយើងទាំងអស់ នោះយើងអាចជៀសវាងបុរេនិច្ឆ័យ អំពើហិង្សា ទំនាស់ និងបង្កើនសុវត្ថិភាពនៅក្នុងសហគមន៍របស់យើងផង ។ មេរៀននេះមានគោលបំណងជួយសិស្សឱ្យពិនិត្យមើលអារម្មណ៍របស់ពួកគេថាត្រឹមត្រូវហើយឬនៅ និងដើម្បីពិចារណានូវរបៀបកាត់បន្ថយបុរេនិច្ឆ័យ ដើម្បីបង្កើនអារម្មណ៍សន្តិសុខរបស់យើងផ្ទាល់ ។

**វត្ថុបំណង** :

- ចៈ សិស្សយល់កាន់តែច្បាស់ថាលទ្ធផលនៃបុរេនិច្ឆ័យ គឺបណ្តាលមកពីការភ័យខ្លាចនិងគ្មានសុវត្ថិភាព
- បៈ សិស្សអាចពិចារណាបានយ៉ាងច្បាស់លាស់អំពីមូលហេតុនៃការរើសអើង និងទំនាស់
- ឥៈ សិស្សពិនិត្យមើលការភ័យខ្លាច និងបុរេនិច្ឆ័យផ្ទាល់ខ្លួនរបស់គេហើយពិចារណារករបៀបដោះស្រាយ ដើម្បីកែប្រែអារម្មណ៍ទាំងនោះឱ្យបាន

**រយៈពេល** : ៣០នាទី

**សម្ភារ** : រឿងព្រះពុទ្ធសាសនា "ការបៀតបៀនអ្នកដទៃបណ្តាលមកពីការភ័យខ្លាច"



រឿងព្រះពុទ្ធសាសនា: "**ការបៀតបៀនអ្នកដទៃបណ្តាលមកពីការភ័យខ្លាច**"

សម័យថ្ងៃមួយ ព្រះពុទ្ធបានយាងជួបកុមារមួយក្រុមកំពុងតែវាយពស់មួយក្បាល ដែលមិនធ្លាប់បង្កគ្រោះថ្នាក់ដល់នរណាម្នាក់ឡើយ ។ **ព្រះពុទ្ធ** បានយល់ថា ពួកក្មេងៗទាំងនោះសុទ្ធសឹងជាមនុស្សល្អ ដូចនេះព្រះអង្គចោទសួរថា "ម្នាលអ្នកទាំងឡាយតើឯងកំពុងធ្វើអ្វី?" កុមារទាំងនោះបានឆ្លើយថា "យើងខ្ញុំកំពុងតែវាយសត្វពស់មួយ" ។ ពួកវាឆ្លើយផងទទួលអារម្មណ៍ដឹងខ្លួនផងថា វាកំពុងនាំគ្នាប្រព្រឹត្តអំពើខុសឆ្គងមួយស្រេចទៅហើយ ។ **ព្រះពុទ្ធ** មានដីកា តទៅទៀតថា "ហេតុអ្វីបានជាអ្នកនាំគ្នាធ្វើដូច្នេះ?" កុមារទាំងនោះឆ្លើយថា "ត្បិតពួក

យើងខ្ញុំខ្លាចសត្វពស់នេះខ្លាំងពេក" ដូច្នេះមានន័យថា "ការភ័យខ្លាចរបស់ពួកអ្នក អាចធ្វើឱ្យសត្វស្លូតបូតដែលគ្មានកំហុសនេះទទួលរងទុក្ខវេទនាឬ?" កុមារទាំងនោះឆ្លើយទាំងអៀនប្រៀនថា "ពិតមែនហើយក្រាបទូល" ។ តើកុមារឃើញទេថា "ការភ័យខ្លាចបានបណ្តាលឱ្យអ្នកក្លាយទៅជាមនុស្សខ្វាក់បែបនេះ?" កុមារឆ្លើយថា "យើងខ្ញុំព្រះករុណាបានគិតថា សត្វនេះអាចធ្វើឱ្យពួកខ្ញុំព្រះករុណាមានគ្រោះថ្នាក់ ទើបពួកខ្ញុំព្រះករុណាសម្រេចចិត្តវាយវា" ។ **ព្រះពុទ្ធ**បន្តទៀតថា "តើអ្នកដឹងទេថា ការធ្វើឱ្យអ្នកដទៃឈឺចាប់ មិនបានផ្តល់ឱ្យអ្នកនូវសុភមង្គលពិតប្រាកដនោះទេ ផ្ទុយទៅវិញបើអ្នកមិនបង្កការឈឺចាប់ដល់អ្នកដទៃទេនោះ ទើបអ្នកសប្បាយចិត្ត។ ចូរចាំថា យើងមិនត្រូវធ្វើអ្វីចំពោះអ្នកដទៃដែលយើងគិតថា មិនគួរត្រូវបានគេធ្វើចំពោះរូបយើងនោះទេ" ។

**ដំណើរការនៃមេរៀន**

១. គ្រូអានរឿងព្រះពុទ្ធសាសនា "**ការបៀតបៀនអ្នកដទៃបណ្តាលមកពីការភ័យខ្លាច**"

២. គ្រូសួរសំណួរទៅសិស្សក្នុងថ្នាក់

ក. តើរឿងនេះមានអត្ថន័យយ៉ាងណា?

ខ. ចូរគិតអំពីពេលអ្នកនិយាយអ្វីមួយមិនប្រសើរទៅកាន់នរណាម្នាក់ផ្សេងទៀត ព្រោះតែអ្នកខ្លាច ឬព្រោះតែអ្នកមិនបានយល់ពីពួកគេ តើមានអ្វីបានកើតឡើង? តើមានលទ្ធផលដូចម្តេច?

៣. គ្រូឱ្យសិស្សសរសេរមួយកថាខ័ណ្ឌ (ប្រហែល១០ឃ្លាយ៉ាងច្រើន) អំពីពេលមួយដែលសិស្សបានឃើញនរណាម្នាក់ធ្វើឱ្យអ្នកផ្សេងមួយទៀតរងទុក្ខលំបាកវេទនានៅក្នុងសាលារៀន ឬនៅក្នុងសហគមន៍របស់អ្នក ព្រោះតែភ័យខ្លាច ឬមិនយល់ពីអ្នកដទៃ។ សិស្សត្រូវសរសេររួមបញ្ចូលទាំងមូលហេតុដែលមនុស្សម្នាក់បញ្ចេញប្រតិកម្មយ៉ាងដូច្នេះ ហើយនិងសំណូមពរពីរសម្រាប់ឱ្យគេអាចមានប្រតិកម្មដោយសន្តិវិធីជាងនេះ។ គ្រូត្រូវទុកពេល១០នាទីឱ្យសិស្សសរសេររឿង។

៤. គ្រូហៅអ្នកស្ម័គ្រចិត្ត ដើម្បីអានរឿង និងសំណូមពររបស់គេ

៥. **សន្និដ្ឋាន :**

នៅក្នុងសង្គមយើងអាចជួបប្រទះជាញឹកញាប់ណាស់ នូវការបង្កឱ្យអ្នកដទៃឈឺចាប់តាមពាក្យសម្តី ឬសកម្មភាពដោយសារយើងមិនយល់ពីអ្នកដទៃនោះ ឬទទួលអារម្មណ៍ភ័យខ្លាចអ្នកនោះ។ ជួនកាលយើងធ្វើឱ្យអ្នកដទៃរងទុក្ខវេទនាដើម្បីគ្រាន់តែការពារខ្លួនយើងតែប៉ុណ្ណោះ។ ការធ្វើដូច្នេះអាចនាំយើងទៅកាន់ទំនាស់បន្ថែមទៀតក៏មាន។ ត្រូវចងចាំពុទ្ធឱវាទដែលថា "អ្នកមិនគួរធ្វើអ្វីចំពោះអ្នកដទៃ ដែលខ្លួនអ្នកមិនគួរត្រូវបានគេធ្វើមកលើយើងឡើយ" ។

# ការលើកតម្កើងភាពខុសគ្នារបស់អ្នកដទៃ

មនុស្សយើងទាំងអស់សុទ្ធតែមានភាពខុសប្លែកពីគ្នា ។ ទោះបីយើងជាខ្មែរដូចគ្នាក៏ដោយ ប៉ុន្តែគ្រួសាររបស់យើងមានប្រពៃណីទំនៀមទម្លាប់ និងចិត្តគំនិតខុសៗគ្នា ។ យើងមានប្រវត្តិ និងអតីតភាពរបស់គ្រួសារយើងខុសៗគ្នា ។ បទពិសោធន៍របស់យើងចំពោះពិភពលោកក៏ខុសគ្នាដែរ ។ អ្នកខ្លះមាន អ្នកខ្លះក្រ អ្នកខ្លះ ជាខ្មែរកាត់ចិន អ្នកខ្លះមកពីខេត្តរតនគិរី ខ្លះមកពីខេត្តស្វាយរៀង ខ្លះមកពីខេត្តបាត់ដំបង ។ល ។ ប្រជាពលរដ្ឋខ្មែរភាគច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា ប៉ុន្តែប្រជាពលរដ្ឋខ្មែរខ្លះទៀតកាន់សាសនាម៉ូស្លីម និងគ្រីស្តសាសនា ។ យើងគួរអបអរសាទរ ចំពោះភាពខុសគ្នាទាំងនេះនៅក្នុងប្រទេសរបស់យើង ។

**វត្ថុបំណង :**

ក: សិស្សយល់ថា ការចេះលើកតម្កើងចំពោះភាពខុសប្លែកគ្នារបស់អ្នកដទៃ អាចបង្កើនអារម្មណ៍សុវត្ថិភាព និងសន្តិភាពនៅក្នុងសហគមន៍

ខ: សិស្សអាចទំនាក់ទំនងជាមួយអ្នកដទៃទៀតដោយគ្មានបុរេនិច្ច័យ

គ: សិស្សលើកតម្កើងដល់ភាពខុសៗគ្នារបស់ពួកគេ

**រយៈពេល :** ៤០ នាទី

**ដំណើរការមេរៀន**

១. គ្រូសរសេរសំណួរដូចខាងក្រោមនៅលើក្តារខៀន ហើយឱ្យសិស្សចម្លងសំណួរទាំងនេះចូលក្នុងសៀវភៅ ។ ឱ្យពេលសិស្ស១៥នាទី ដើរសួរសំណួរនៅក្នុងបន្ទប់ដល់សិស្សតាមលទ្ធភាពចំនួនសិស្សដែលអាចសួរបាន ដើម្បីយកចម្លើយពីសិស្សទាំងនោះមកបំពេញក្នុងតារាង ។ សិស្សម្នាក់សួរបានតែមួយសំណួរ មិនអាចមានឈ្មោះសិស្សណាម្នាក់ពីរដងនៅក្នុងតារាង ។ អ្នកឈ្នះគឺសិស្សដែលរកបានចម្លើយមុនគេ ។

**កំណត់សម្គាល់ :**

លោកគ្រូ-អ្នកគ្រូប្រហែលជាអាចបន្ថែមសំណួរជាច្រើនទៀត ដើម្បីឱ្យសមទៅនឹងសិស្សរបស់គាត់ ។ ចូរចាំថាមេរៀននេះមានគោលបំណងជួយឱ្យសិស្សរកឃើញព័ត៌មានថ្មីៗ ដែលពួកគេមិនធ្លាប់បានដឹងពីមិត្តភ័ក្តិ ដើម្បីបង្កើនការយល់ដឹងរបស់គេ ។

| ស្វែងរកនរណាម្នាក់ដែល | ឈ្មោះសិស្សដែលបានសម្ភាស | ចម្លើយ |
| --- | --- | --- |
| ប្រកបរបរអ្វីមួយគួរឱ្យចាប់អារម្មណ៍ក្រៅពីការសិក្សា? តើជារបរអ្វី? | | |
| ចេះភាសាមួយផ្សេងទៀតក្រៅពីភាសាខ្មែរ? តើភាសាអ្វី? | | |
| ទើបរៀនធ្វើអ្វីមួយដែលថ្មី? តើជាអ្វីទៅ? | | |
| ធ្លាប់រស់នៅខេត្តផ្សេងពីខេត្តនេះឬទេ? តើខេត្តណាទៅ? | | |
| មានទេពកោសល្យផ្នែកសិល្បៈ? តើជាទេពកោសល្យអ្វី? | | |
| ចូលចិត្តម្ហូបបរទេស? តើជាម្ហូបអ្វី? | | |
| ចូលចិត្តធ្វើជាអ្នកនយោបាយនៅពេលធំឡើង? តើហេតុអ្វី? | | |
| ថ្មីៗនេះបានជួយដោះស្រាយទំនាស់គេ? តាមរបៀបណា? | | |

២. លំហាត់បន្ថែមតាមចំណូលចិត្ត។ គ្រូត្រូវឱ្យសិស្សក្រោកឈរប្រសិនបើជាចម្លើយត្រឹមត្រូវសម្រាប់ពួកគេ ចំពោះសំណួរដូចខាងក្រោមនេះ។

ក. អ្នកមានបងប្អូនប្រុសស្រីច្រើនលើសពីពីរនាក់?

ខ. អ្នកជិះកង់មករៀន?

គ. អ្នកចូលចិត្តញ៉ាំស្វាយខ្ចី?

ឃ. អ្នកប្រើដៃឆ្វេង?

ង. អ្នករស់នៅក្នុងទីក្រុង?

ច. អ្នកកើតនៅខេត្តផ្សេងពីខេត្តនេះ?

ឆ. អ្នកជាក្មេងប្រុស?

ជ. ជីដូនជីតារបស់អ្នករស់នៅជាមួយអ្នក?

ឈ. អ្នកចូលចិត្តរាំ?

គ្រូអាចបន្ថែមសំណួរផ្ទាល់ខ្លួនដែលទាក់ទងនឹងសិស្ស ដើម្បីបង្ហាញភាពខុសគ្នា និងភាពដូចគ្នាទៅសិស្ស

៣. គ្រូសួរសំណួរដូចខាងក្រោមៈ

ក. ប្អូនៗប៉ុន្មាននាក់ ដែលបានរកឃើញព័ត៌មានដែលគួរឱ្យចាប់អារម្មណ៍ ឬគួរឱ្យភ្ញាក់ផ្អើលពីមិត្តឯងទៀតឬទេ?

ខ. តើយើងរកឃើញព័ត៌មានអ្វីដែលដូចគ្នាក្នុងថ្នាក់រៀននេះឬទេ?

គ. តើអ្វីខ្លះជាភាពខុសគ្នារបស់យើង?

ឃ. តើអ្នកពេញចិត្តចំពោះភាពខុសគ្នានេះ ឬទេ? ហេតុអ្វីពេញចិត្ត? ហេតុអ្វីមិនពេញចិត្ត?

ង. ហេតុអ្វីបានជាយើងគួរកោតសរសើរដល់ភាពខុសគ្នារបស់យើងទាំងអស់គ្នា?

ច. តើពិភពលោកនឹងទៅជាយ៉ាងណាបើយើងទាំងអស់ដូចគ្នា? (**ចម្លើយចូលរួមៈ** គ្មានការរីកចម្រើន គួរឱ្យធុញទ្រាន់)

## ៤. សន្និដ្ឋាន :

សកម្មភាពនេះបង្ហាញឱ្យយើងឃើញយ៉ាងច្បាស់ពីភាពខុសគ្នារបស់យើង ទោះបីជាយ៉ាងណាក៏ដោយ យើងរស់នៅក្នុងប្រទេសតែមួយ សិក្សាក្នុងសាលារៀនតែមួយ តែយើងមានសមត្ថភាព បំណិន និងជីវប្រវត្តិផ្សេងៗពីគ្នា។ ប្រសិនបើយើងចំណាយពេលក្នុងការស្វែងយល់អំពីគ្នាទៅវិញទៅមក នោះយើងនឹងមានទំនាក់ទំនងកាន់តែល្អប្រសើរឡើង និងធ្វើឱ្យងាយស្រួលក្នុងការរស់នៅជាមួយគ្នា និងធ្វើការជាមួយគ្នា។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀនសីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី.១២ មេរៀន: ជនជាតិផ្សេងៗនៅកម្ពុជា នៃកម្មវិធីសិក្សារបស់ក្រសួងអប់រំយុវជន និងកីឡា*







# ការស្តាប់គ្នាទៅវិញទៅមក

ការស្តាប់ គឺជាសមត្ថភាពមួយយ៉ាងសំខាន់ក្នុងការជួយកាត់បន្ថយទំនាស់រវាងបុគ្គលនិងបុគ្គល ។ ប្រសិនបើយើងពិតជាយល់នូវអ្វីដែលនរណាមួយចង់និយាយមកកាន់យើងនោះ យើងអាចតបតក្នុងផ្លូវខុសយ៉ាងតិចបំផុត ។ ជួនកាលការយល់ខុស ឬទំនាស់របស់មនុស្សយើង សាងឡើងដោយសារតែយើងមិនបានយល់នូវអ្វីដែលអ្នកដទៃបាននិយាយ ។ មេរៀននេះសំដៅជួយសិស្សឱ្យចេះត្រិះរិះពិចារណាថា ជំនាញនៃការស្តាប់របស់គេដែលជាមធ្យោបាយបង្ការទំនាស់ នឹងអាចជួយធ្វើឱ្យប្រសើរដល់ទំនាក់ទំនងរបស់ពួកគេជាមួយអ្នកដទៃ ។

**វត្ថុបំណង** :

ចៈ សិស្សយល់អំពីឥទ្ធិពលនៃជំនាញស្តាប់ ដែលអាចជួយដល់ការកសាងទំនាក់ទំនងល្អ និងអាចជៀសវាងទំនាស់បាន

បៈ សិស្សចាប់ផ្តើមស្តាប់គ្រូ និងមិត្តភក្តិដោយយកចិត្តទុកដាក់ជាងមុន

ឥៈ សិស្សពិចារណាអំពីការស្តាប់ដោយយកចិត្តទុកដាក់ថា ជាជំនាញដ៏សំខាន់សម្រាប់ការចុះសម្រុងគ្នា ហើយសិស្សនឹងប្រើប្រាស់ជំនាញស្តាប់នេះ

**រយៈពេល** : ៣០នាទី

**ដំណើរការមេរៀន**

១. ជ្រើសរើសសិស្សពីរនាក់ឱ្យឈរទល់ខ្នងគ្នា

២. ឱ្យសិស្សម្នាក់និយាយប្រាប់សិស្សម្នាក់ទៀត នូវសកម្មភាពដែលគេបានធ្វើកាលពីថ្ងៃអាទិត្យ ។ ត្រូវធ្វើកាយវិការហាក់ដូចជាគេកំពុងនិយាយតាមទូរស័ព្ទ ។ បន្ទាប់ពីការសន្ទនាបានបញ្ចប់ ឱ្យសិស្សដែលធ្វើជាអ្នកស្តាប់និយាយរឿងនោះឡើងវិញប្រាប់សិស្សក្នុងថ្នាក់អំពីអ្វីដែលគេបានឮ ។

៣. ឱ្យសិស្សដទៃធ្វើការសង្កេត ឬស្តាប់ការសន្ទនា ។ តើអ្នកនិយាយឡើងវិញបានចាំអ្វីខ្លះ? តើគេបានភ្លេចអ្វីខ្លះ?

៤. គ្រូអានអត្ថបទដកស្រង់ដូចខាងក្រោម:

> ការកសាងសន្តិភាព ត្រូវការករុណាធម៌ និងការស្ទាត់ជំនាញក្នុងការស្តាប់ ។ ដើម្បីស្តាប់ឱ្យបានច្បាស់យើងត្រូវលះបង់អ្វីដែលហៅថា "អត្តា ឬអញ" ទោះបីក្នុងពាក្យពេចន៍យើងផ្ទាល់ក៏ដោយ ។ យើងត្រូវខំស្តាប់រហូតដល់យើងអាចឮអ្វីដែលជាកំណើតនៃសេចក្តីស្ងប់របស់យើង ។ នៅពេលយើងរៀនស្តាប់ខ្លួនយើង យើងក៏ត្រូវរៀនស្តាប់ពីអ្នកឯទៀតឱ្យបានច្បាស់លាស់ដែរ នោះគំនិតថ្មីៗនឹងរីកលូតលាស់ដុះដាលឡើង ។
>
> *ដកស្រង់ពីការបង្កើតសន្តិភាពមួយជំហានម្តងៗ ដែលនិពន្ធដោយ: Maha Ghosananda (សម្តេចព្រះមហាឃោសានន្ទ)*

៥. **សំណួរវាយតម្លៃ :**

**ក.** តើអ្នកគិតថា **សម្តេចព្រះមហាឃោសនន្ទ** ចង់មានសង្ឃដីកាយ៉ាងដូចម្តេចនៅក្នុងសម្រង់សេចក្តីនេះ?

**ខ.** ហេតុអ្វីការស្តាប់មានសារៈសំខាន់?

៦. គ្រូសួរបំផុសគំនិតសិស្សឱ្យឆ្លើយនូវសំណួរដូចខាងក្រោម ហើយកត់ត្រាចម្លើយសិស្សដាក់លើក្តារខៀន ។

- តើអ្នកស្តាប់ល្អត្រូវធ្វើអ្វីខ្លះ?

**ចម្លើយគួររួមបញ្ចូល:**

- ផ្តោតអារម្មណ៍យកចិត្តទុកដាក់ចំពោះអ្នកនិយាយ
- ភ្ញែកសម្លឹងឱ្យចំអ្នកនិយាយ ប៉ុន្តែមិនសម្លក់ដាក់គេទេ
- ខ្លួនត្រូវងាកទៅឱ្យចំអ្នកនិយាយ
- ត្រូវចេះអនុញ្ញាតឱ្យអ្នកនិយាយបានបញ្ចប់សិនមុននឹងនិយាយអំពីខ្លួនយើង
- ពេលស្តាប់មិនយល់ត្រូវសួរបញ្ជាក់
- ត្រូវគោរពដល់បទពិសោធន៍និងយោបល់របស់អ្នកនិយាយ
- សូមកុំនិយាយកាត់
- ត្រូវសួរសំណួរបើក (**ឧទាហរណ៍:** តើរឿងនោះបានកើតឡើងយ៉ាងដូចម្តេច?)
- កុំផ្តល់ដំបូន្មានលើកលែងតែអ្នកនិយាយសុំ
- សង្ខេបព័ត៌មានឡើងវិញដើម្បីផ្ទៀងផ្ទាត់ ។ល ។

៧. ឱ្យសិស្សធ្វើការជាគូៗ ។ ប្តូរវេនគ្នានិយាយពីរឿងរ៉ាវផ្សេងៗ អំពីជីវភាពរស់នៅរបស់ពួកគេជាដើម ។ នៅពេលគេបញ្ចប់ការនិយាយរឿងត្រូវឱ្យអ្នកស្តាប់និទានរឿងនេះឡើងវិញ ។ គ្រូសួរអ្នកនិទានរឿង ថាតើគេនិយាយឡើងវិញត្រឹមត្រូវ ឬទេ?

៨. បន្ទាប់ពីធ្វើលំហាត់នេះរួចសួរទៅសិស្ស ៖

ក. តើអ្នកស្តាប់បានល្អទេនៅពេលអ្នកធ្វើជាអ្នកស្តាប់? តើអ្នកអាចស្តាប់បានព័ត៌មានទាំងអស់នោះដែរឬទេ?

ខ. តើការស្តាប់គ្នាទៅវិញទៅមកស្រួលដែរឬទេ?

គ. តើអ្នកយល់ថា ពេលយើងស្តាប់បានច្រើនយើងអាចធ្វើឱ្យប្រសើរនូវទំនាក់ទំនងជាមួយអ្នកដទៃបានដែរឬទេ?

ឃ. ហេតុអ្វី? តាមរបៀបដូចម្តេច?

៩. **សន្និដ្ឋាន ៖**

ប្រសិនបើយើងស្តាប់គ្នានិយាយទៅវិញទៅមកដោយយកចិត្តទុកដាក់ប្រកបដោយមនសិការ និងបើកចំហរផ្លូវចិត្តស្តាប់គេនិយាយ យើងអាចយល់គ្នាបានប្រសើរជាងធម្មតា។ បើយើងប្រញាប់ប្រញាល់និងមិនស្តាប់គ្នាទៅវិញទៅមកទេនោះ យើងនឹងងាយយល់ច្រឡំពីគ្នា និងអាចឈានទៅរកទំនាស់ ឬបាក់បែកចំណងមិត្តភាព។ យើងគួរហាត់រៀនស្តាប់គ្នាទៅវិញទៅមកដោយយកចិត្តទុកដាក់។

# ការប្រាស្រ័យទាក់ទងល្អ

ជារៀងរាល់ថ្ងៃយើងទាក់ទងជាមួយនឹងអ្នកដទៃនៅសាលារៀន នៅតាមទីផ្សារ ឬទីសាធារណៈជាមួយមិត្តភក្តិ និងក្រុមគ្រួសាររបស់យើង។ នៅពេលយើងនិយាយទៅកាន់នរណាម្នាក់ យើងចង់ឱ្យគេយល់ និងចងចាំនូវអ្វីដែលយើងកំពុងនិយាយ។ ដូច្នេះយើងចាំបាច់ត្រូវរៀនពីវិធីសាស្ត្រក្នុងការប្រាស្រ័យទាក់ទងព័ត៌មានរបស់យើងដែលប្រកបដោយប្រសិទ្ធភាព។ នៅពេលគេមិនយល់ពីយើង ធ្វើឱ្យយើងមានអារម្មណ៍ក្តៅក្រហាយ ឬមានអារម្មណ៍បង្កទំនាស់។ នៅពេលអ្នកស្តាប់យល់ខុស គេអាចមានអារម្មណ៍ខឹងសម្បារ។ ដូច្នេះយើងត្រូវស្វែងយល់អំពីវិធីដែលប្រសើរបំផុតក្នុងការប្រាស្រ័យទាក់ទងគ្នា។

**វត្ថុបំណង** :

ចៈ សិស្សនឹងយល់អំពីវិធីដើម្បីធ្វើជាអ្នកប្រាស្រ័យទាក់ទងដ៏មានប្រសិទ្ធភាព

បៈ សិស្សធ្វើការប្រាស្រ័យទាក់ទងដោយមានប្រសិទ្ធភាពកាន់តែខ្លាំងជាមួយមិត្តភក្តិរបស់គេ

ឥៈ សិស្សនឹងចាត់ទុកការប្រាស្រ័យទាក់ទងដ៏មានប្រសិទ្ធភាព ថាជាវិធីដ៏មានប្រយោជន៍សម្រាប់ជៀសវាងការយល់ច្រឡំ ឬទំនាស់

**រយៈពេល** : ៣០នាទី

**សម្ភារ** : របាយការណ៍ **ស្តីពីចោរកម្ម**




មានអំពើចោរកម្ម! ខ្ញុំកំពុងតែដើរចូលទៅក្នុងហាងលក់ទំនិញមួយ ហើយបុរសម្នាក់បានកំពុងរត់ចេញទៅក្រៅ។ គាត់បានរត់បុកខ្ញុំ រួចបន្តរត់ទៅមុខទៀត ដោយមានកាន់កាបូបពណ៌សមួយក្នុងដៃស្តាំផង ហើយមើលទៅហាក់ដូចជាមានកាំភ្លើងក្នុងដៃឆ្វេងផងដែរ។ គាត់ពាក់អាវធំពណ៌ត្នោតដែលមានស្នាមរហែកត្រង់ស្មា នៅពីក្រៅអាវដៃវែងឆ្នូតពណ៌ខៀវ-បៃតង និងស្លៀកខោខូវប៊យពណ៌ខៀវ។ គាត់មានជើងតូចៗ និងក្បាលពោះធំ ហើយពាក់វ៉ែនតាដងដែក និងស្បែកជើងឃ្លុបពណ៌ខ្មៅ។ គាត់មានក្បាលទំពែក និងពុកមាត់ពណ៌ត្នោត ព្រមទាំងមានកំពស់ប្រហែល ១.៨០ម និងមានអាយុខ្ទង់ប្រហែល៣៥ឆ្នាំ។ សូមទៅប្រាប់ប៉ូលីសឱ្យស្វែងរកបុរសនោះផង។

**ដំណើរការមេរៀន :**

១. ជ្រើសរើសអ្នកស្ម័គ្រចិត្ត ៣នាក់ ។ ឱ្យអ្នកទាំងនោះដើរចេញក្រៅបន្ទប់ ។

២. គ្រូអាន "*របាយការណ៍ចោរប្លន់*" ឱ្យខ្លាំងៗ និងយឺតៗ ដើម្បីឱ្យសិស្សក្នុងថ្នាក់ស្តាប់ រួចឆ្លើយនូវរាល់សំណួរដែលអាចមាន ។ គ្រូត្រូវប្រាកដក្នុងចិត្តថា សិស្សម្នាក់ៗបានយល់រឿងនោះយ៉ាងពិស្តារ ។

៣. ហៅអ្នកស្ម័គ្រចិត្តទី១ ឱ្យចូលក្នុងថ្នាក់រៀន ។ និយាយរឿងប្រាប់គេយ៉ាងប្រញាប់ កុំអនុញ្ញាតឱ្យគាត់សួរ ឬឆ្លើយឱ្យសោះ ។ ហាមសិស្សក្នុងថ្នាក់ដែលបានស្តាប់រឿងនេះរួចឱ្យនៅស្ងៀមកុំនិយាយប្រាប់ ឬធ្វើសញ្ញាឱ្យអ្នកស្តាប់ដឹង ។

៤. ហៅអ្នកស្ម័គ្រចិត្តទី២ ឱ្យចូលថ្នាក់រៀន ។ ឱ្យអ្នកស្ម័គ្រចិត្តទី១ និយាយរឿងឡើងវិញប្រាប់អ្នកស្ម័គ្រចិត្តទី២ ។ កុំផ្តល់ឱកាសឱ្យគាត់សួរ ឬឆ្លើយឱ្យសោះ ។

៥. ហៅអ្នកស្ម័គ្រចិត្តទី៣ ឱ្យចូលថ្នាក់រៀន ។ ឱ្យអ្នកស្ម័គ្រចិត្តទី២ និយាយរឿងបន្តប្រាប់អ្នកស្ម័គ្រចិត្តទី៣ ។ កុំផ្តល់ពេលឱ្យគាត់សួរ ឬនិយាយ ។

៦. ឱ្យអ្នកស្ម័គ្រចិត្តទី៣ និយាយរឿងប្រាប់សិស្សទាំងអស់ក្នុងថ្នាក់វិញ ឱ្យសិស្សទាំងអស់ជជែកគ្នាលំអិតពីខ្លឹមសារដែលអ្នកស្ម័គ្រចិត្តទី៣ភ្លេច ។ គ្រូអានរឿងសារឡើងវិញឱ្យសិស្សស្តាប់ ។

៧. អនុញ្ញាតឱ្យអ្នកស្ម័គ្រចិត្តទាំងនោះគិតពីអារម្មណ៍របស់ពួកគេ ដើម្បីចងចាំរឿងរ៉ាវលំអិតជាច្រើន ហើយអាចនិយាយរឿងនោះឡើងវិញបាន

៨. គ្រូសួរសិស្សក្នុងថ្នាក់នូវសំណួរខាងក្រោម សម្រាប់ការពិភាក្សាលំអិត
   ក. តើរឿងនោះបានប្រែប្រួលយ៉ាងដូចម្តេចខ្លះ?
   ខ. តើមានព័ត៌មានសំខាន់ៗណាខ្លះដែលបាត់មិនបាននិយាយដែរឬទេ?
   គ. តើមានព័ត៌មានអ្វីត្រូវបានថែមឱ្យរឿងនេះ?
   ឃ. តើមានអ្វីខ្លះដែលធ្វើឱ្យអ្នកពិបាកចងចាំសាច់រឿង?
   ង. តើមានអ្វីខ្លះជាឧបសគ្គក្នុងការប្រាស្រ័យទាក់ទងគ្នា?
   ច. តើមានអ្វីខ្លះដែលអាចធ្វើឱ្យការចងចាំរឿងទាំងមូលបានស្រួលជាង?

៩. គ្រូបំបែកសិស្សជាក្រុមតូចៗ ។ ក្រុមនីមួយៗត្រូវឆ្លើយនឹងសំណួរខាងក្រោម
   ក. តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យការប្រាស្រ័យទាក់ទងក្នុងជីវិតប្រចាំថ្ងៃមានប្រសិទ្ធភាព? (**ចម្លើយចូលរួម:** ព័ត៌មានច្បាស់ ព័ត៌មានខ្លីៗ និយាយឡើងវិញនូវចំណុចសំខាន់ៗ ត្រួតពិនិត្យការយល់ដឹងរបស់អ្នកស្តាប់ផ្តល់ការយកចិត្តទុកដាក់ចំពោះអ្នកនិយាយ សួរបញ្ជាក់ពេលណាមិនយល់ច្បាស់ ប្រើប្រាស់ភាសាងាយយល់ដល់អ្នកស្តាប់)
   ខ. តើការប្រាស្រ័យទាក់ទងមិនល្អមានផលប៉ះពាល់អ្វីខ្លះ?

១០.	ក្រុមនីមួយៗឡើងបង្ហាញលទ្ធផលដល់សិស្សទាំងអស់

១១.	**សន្និដ្ឋាន :**

នៅពេលយើងធ្វើទំនាក់ទំនងគ្នាបានច្បាស់លាស់ដោយគ្មានព័ត៌មានលំអិតច្រើននោះ យើងនឹងអាចយល់គ្នាបាន និងងាយស្រួលធ្វើការចងចាំ ។ ដូចគ្នាដែរ នៅពេលយើងស្ដាប់យ៉ាងយកចិត្តទុកដាក់ និងមានការចាប់អារម្មណ៍ទាំងស្រុងចំពោះការនិយាយនោះ យើងអាចយល់អំពីព័ត៌មានបានយ៉ាងប្រសើរ ។ នៅពេលយើងមិនប្រើវិធីសាស្ត្រក្នុងការប្រាស្រ័យទាក់ទងឱ្យមានប្រសិទ្ធភាពទេនោះ យើងអាចយល់ខុសពីគ្នាដែលអាចឈានទៅរកទំនាស់បាន ។ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព គឺជាវិធីសាស្ត្រមួយសម្រាប់យើងក្នុងការការពារមិនឱ្យមានទំនាស់កើតឡើងបាន ។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១១ មេរៀនទី២: ការបង្កើតវប្បធម៌សន្តិភាព នៃកម្មវិធីរបស់ ក្រសួងអប់រំយុវជន និងកីឡា*

ជំពូក

២

# ទំនាស់

# បទពិសោធន៍របស់យើងអំពីទំនាស់

ទំនាស់គឺជាផ្នែកមួយនៃជីវភាពប្រចាំថ្ងៃ ។ យើងប្រឈមមុខនឹងទំនាស់នៅក្នុងផ្ទះ ក្នុងគ្រួសារ នៅសាលារៀន ជាមួយមិត្តភក្តិ នៅកន្លែងធ្វើការ និងក្នុងសហគមន៍ ។ ជានិច្ចកាលទំនាស់មិនមែនសំដៅលើសង្គ្រាម និងអំពើហិង្សានោះទេ ។ ទំនាស់ខ្លះអាចមានលក្ខណៈវិជ្ជមានប្រសិនបើគ្មានអំពើហិង្សា ពីព្រោះទំនាស់អាចជួយយើងឱ្យសម្រេចនូវតម្រូវការបាន ឬទំនាស់អាចជួយយើងឱ្យបញ្ចេញអារម្មណ៍របស់យើងបានដែរ ។ មេរៀននេះអាចឱ្យសិស្សពិនិត្យមើលការសន្និដ្ឋានរបស់ពួកគេ និងអារម្មណ៍ស្តីពីទំនាស់ ហើយពិចារណាថាតើទំនាស់ជានិច្ចកាលមានមុខងារវិជ្ជមានដែរឬទេ? ។

**វត្ថុបំណង :**

ក: សិស្សអភិវឌ្ឍការយល់ដឹងអំពីទំនាស់របស់គេកាន់តែស៊ីជំរៅ

ខ: សិស្សអាចបែងចែកប្រភេទនៃទំនាស់បែបវិជ្ជមាន និងអវិជ្ជមាន

គ: សិស្សពិចារណាអំពីភាពខុសគ្នានៃទំនាស់វិជ្ជមាន និងទំនាស់អវិជ្ជមាន

**រយៈពេល :** ៣០នាទី

**វាក្យស័ព្ទ :**

**ទំនាស់** : គឺជាទស្សនៈផ្ទុយគ្នាដែលកើតឡើងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីមនុស្សមួយក្រុម ទៅមនុស្សមួយក្រុមទៀតអំពីគំនិត គុណតម្លៃ ឬអាកប្បកិរិយា ។

**អំពើហិង្សា** : រាល់ទង្វើទាំងឡាយណាដែលធ្វើឱ្យអ្នកដទៃឈឺចាប់លើរាងកាយ ឬផ្លូវចិត្ត

**ទំនាស់វិជ្ជមាន:** គឺជាទំនាស់ដែលគ្មានហិង្សា ហើយនាំទៅរកការរីកចម្រើន

**ទំនាស់អវិជ្ជមាន:** គឺជាទំនាស់ដែលប្រើហិង្សា និងធ្វើឱ្យមនុស្សឈឺចាប់

**ចំណាំកនាំមេរៀន:**

១. គ្រូគូសរង្វង់មួយនៅចំកណ្តាលក្តារខៀន ហើយសរសេរពាក្យ "**ទំនាស់**" នៅក្នុងរង្វង់នោះ រួចសួរសិស្សឱ្យរកពាក្យ ឬឃ្លាប្រយោគដែលទាក់ទងនឹងពាក្យ "**ទំនាស់**" ។ ពាក្យទាំងអស់នេះអាចពិពណ៌នាអំពីស្ថានភាព ភាគីទំនាស់ ប្រភេទទំនាស់ អារម្មណ៍ ប្រភពនៃទំនាស់ ឬលទ្ធផលនៃទំនាស់ជាដើម ។ គ្រូត្រូវទទួលយករាល់ចម្លើយរបស់សិស្ស ដោយគ្មានធ្វើការពិភាក្សា ឬកាត់សេចក្តីអ្វីឡើយ ។

២. ខាងក្រោមនេះជាគំរូនៃបណ្ដាញទំនាស់




៣. នៅពេលបណ្ដាញទំនាស់នេះត្រូវបានបញ្ចប់ គ្រូឱ្យសិស្សក្រឡេកមើលបណ្ដាញទំនាស់នោះមួយឬពីរនាទី ។

៤. គ្រូសួរសិស្ស

**ក.** តើចម្លើយទាំងអស់នេះភាគច្រើនអវិជ្ជមានមែនទេ?

**ខ.** តើទំនាស់អាចមានលទ្ធផលវិជ្ជមានដែរឬទេ? ( **ឧទាហរណ៍:** ការដោះស្រាយបញ្ហា ឬឱកាសសម្រាប់កែប្រែដោយការស្ថាបនា)

**គ.** ហេតុអ្វីបានជាប្រតិកម្មរបស់យើងចំពោះទំនាស់ជាញឹកញាប់ទទួលលទ្ធផលអវិជ្ជមាន?

**ឃ.** តើអ្វីជាគុណសម្បត្តិនៃទំនាស់? ( **ចម្លើយចូលរួម:** ទំនាស់អាចជួយឱ្យភាគីទំនាស់បានយល់ច្បាស់ និងទទួលជោគជ័យនូវសន្តិភាពដែលពួកគេត្រូវការ ហើយវាជួយយើងផងដែរក្នុងការបញ្ចេញនូវអារម្មណ៍បើកទូលាយសម្រាប់អ្នកដទៃ ។ នៅពេលដែលយើងដោះស្រាយទំនាស់ដោយសន្តិភាព យើងនឹងបង្កើននូវទំនាក់ទំនង ។)

៥. **សន្និដ្ឋាន:**

ក្នុងការរស់នៅ យើងប្រឈមមុខនឹងទំនាស់ជារៀងរាល់ថ្ងៃ ជាមួយឪពុកម្ដាយ បងប្អូនប្រុសស្រី មិត្តភក្តិ និងមនុស្សដទៃដែលយើងជួប ។ គឺជារឿងធម្មតាព្រោះថា យើងសុទ្ធតែមានលក្ខណៈ តម្រូវការ និងផលប្រយោជន៍ខុសៗគ្នា ។ ក្នុងន័យនេះ បើទំនាស់ត្រូវបានដោះស្រាយតាមវិធីស្ថាបនា វាអាចមានលក្ខណៈវិជ្ជមាន ព្រោះវាអាចជួយឱ្យយើងទទួលនូវអ្វីដែលយើងត្រូវការ ឬចង់បាន ។ ទោះបីជាយ៉ាងណាក៏ដោយ បើទំនាស់ក្លាយជាហិង្សា នោះវាមានលក្ខណៈអវិជ្ជមាន ហើយតែងបង្កឱ្យមានគ្រោះថ្នាក់ ។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀនសីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១០ មេរៀន: ភាពថ្លៃថ្នូរក្នុងការរស់នៅនៃកម្មវិធីរបស់ក្រសួងអប់រំយុវជន និងកីឡា*

# ទំនាស់ និង អំពើហិង្សា

ជារឿយៗទំនាស់អាចក្លាយជាអំពើហិង្សាយ៉ាងឆាប់រហ័ស ។ នៅពេលទំនាស់កើតឡើង មនុស្សបាត់បង់គំហើញនៃអ្វីដែលគេកំពុងប្រយុទ្ធចង់បាន ប៉ុន្តែគេផ្តោតអារម្មណ៍តែលើការខឹងសម្បារ និងការស្អប់ខ្ពើមតែមួយប៉ុណ្ណោះ ។ មេរៀននេះផ្តល់ឱ្យសិស្សនូវឱកាសដើម្បីគិតពីមូលហេតុអ្វីដែលធ្វើឱ្យទំនាស់ឈានទៅរកអំពើហិង្សាយ៉ាងឆាប់រហ័ស និងរបៀបដោះស្រាយទំនាស់មុនពេលវាកាន់តែធ្ងន់ធ្ងរឡើង ព្រមទាំងលើកឡើងនូវបញ្ហាស្តីពីតថភាពរបស់សង្គ្រាម ។

**វត្ថុបំណង** :

ច: សិស្សយល់អំពីមូលហេតុដែលនាំឱ្យទំនាស់ចេះតែវិវឌ្ឍន៍ធ្ងន់ធ្ងរទៅៗយ៉ាងឆាប់រហ័ស

ប: សិស្សបង្កើនសមត្ថភាពរបស់ខ្លួនលើការដោះស្រាយបញ្ហា

ឥ: សិស្សពិចារណាអំពីវិធីផ្តោតការយកចិត្តទុកដាក់ដោះស្រាយបញ្ហា ជាងបណ្តោយទៅតាមអារម្មណ៍របស់ខ្លួន

**រយៈពេល** : ៣០នាទី

**សម្ភារ** : រឿង "ហេតុអ្វីអ្នកប្រយុទ្ធគ្នា?"



**រឿង "ហេតុអ្វីអ្នកប្រយុទ្ធគ្នា?"**

កាលពីព្រេងនាយមានសហគមន៍ពីររស់នៅសងខាងទន្លេមួយ ។ ពួកគេបានរស់នៅដោយចុះសម្រុងនឹងគ្នាក្នុងខណៈដែលគ្មានបញ្ហាអ្វីឡើយ ។ ប៉ុន្តែក្រោយមកមានគ្រោះរាំងស្ងួតកើតឡើង ហើយក្រុមទាំងពីរក៏មានចិត្តលោភលន់យ៉ាងខ្លាំង ។ ពួកគេគិតតែរៀងៗខ្លួនថា ពួកគេគួរបានគ្រប់គ្រងទឹកទន្លេទាំងអស់ ហើយសហគមន៍ម្ខាងទៀតមិនគួរបានទឹកនោះប្រើប្រាស់ជាដាច់ខាត ។ ព្រោះតែហេតុនេះពួកគេចាប់ផ្តើមឈ្លោះប្រកែកគ្នា ។ ជម្លោះនេះធ្វើឱ្យពួកគេខឹងគ្នាទៅវិញទៅមក ហើយបណ្តាលឱ្យពួកគេហៅឈ្មោះគ្នាអាក្រក់ទៅវិញទៅមកតាមកំហឹង ដើម្បីធ្វើឱ្យភាគីម្ខាងទៀតឈឺចាប់កាន់តែខឹងខ្លាំងឡើងៗ ។ កាលណាមនុស្សម្នាក់ខឹង អ្នកនោះងាយនឹងធ្វើឱ្យអ្នកដទៃខឹងតាមដែរ ។ មិនយូរប៉ុន្មានពួកគេម្នាក់ៗខឹងគ្នាទៅវិញទៅមកសូម្បីតែអ្នកដែលមិនជាប់ទាក់ទងបញ្ហាពីដើមទី ក៏ចូលរួមមានកំហឹងដែរ ។ នៅពេលនោះពួកគេត្រៀមខ្លួនជាស្រេច សម្រាប់ការធ្វើសង្គ្រាមយ៉ាងលឿនបំផុត ។

នៅមុនពេលសង្គ្រាមចាប់ផ្ដើមបន្តិច **ព្រះពុទ្ធ** បានយាងមកដល់ដោយព្រះអង្គឈ្វេងយល់ថា មានបញ្ហាអ្វីមួយមិនស្រួល ។ ព្រះអង្គសួរទៅមនុស្សដែលក្រេវក្រោធថា "តើអ្នកកំពុងធ្វើអ្វី?" ពួកគេស្រែកទាំងកំហឹងថា "ពួកយើងនឹងមានសង្គ្រាម" ព្រះអង្គសួរថា "តើហេតុអ្វី?" ប៉ុន្តែគ្មាននរណាមួយដឹងពីមូលហេតុនៃជម្លោះនោះទេ ។ ពួកគេខឹងខ្លាំងពេក រហូតភ្លេចពីមូលហេតុដំបូងដែលនាំឱ្យពួកគេចង់ធ្វើសង្គ្រាម ។ ឥឡូវនេះពួកគេចាប់ផ្ដើមដឹងខ្លួនថា ពួកគេទាំងអស់គ្នាជាមនុស្សឆោតល្ងង់ ។ ម្នាក់ៗសួរគ្នាថា តើសង្គ្រាមនេះធ្វើដើម្បីអ្វី? ប៉ុន្តែគ្មាននរណាម្នាក់ដឹងទេ ហើយនៅទីបញ្ចប់ពួកគេត្រូវទៅសួរ **ស្ដេចផែនដី** ដែលព្រះអង្គបានពន្យល់ថា ពួកគេប្រយុទ្ធគ្នាដើម្បីទឹក ។

**ព្រះពុទ្ធ** បានត្រាស់សួរថា តើនឹងមានមនុស្សប៉ុន្មាននាក់ស្លាប់ បើអ្នករាល់គ្នាធ្វើសង្គ្រាម? អ្នកទាំងអស់នោះបានឆ្លើយថាៈ "ជាការពិតណាស់ក្រាបទូល បើមានសង្គ្រាមកើតឡើង នោះនឹងមានមនុស្សរាប់រយនាក់ត្រូវស្លាប់" **ព្រះពុទ្ធ** ក្បង់ទឹកមួយបាតដៃពីទន្លេ ហើយសួរថា "តើមនុស្សបរិសុទ្ធរាប់រយនាក់នឹងត្រូវស្លាប់ដោយសារតែទឹកនេះឬ?" គ្រប់ៗគ្នានៅស្ងៀម ។ "តើមនុស្សប៉ុន្មាននាក់នឹងស្លាប់ បើអ្នកចេះចែករំលែកទឹកនេះយ៉ាងប្រុងប្រយ័ត្ន ហើយសហការជាមួយគ្នានោះ?" ប្រជាជននាំគ្នាឆ្លើយថាប្រហែលជាគ្មានទេ ។ ដូច្នេះប្រជាជនបានយល់ថា ពួកគេមិនត្រូវប្រយុទ្ធគ្នាឡើយ ។ ប្រជាជនទាំងនោះដឹងគុណ **ព្រះពុទ្ធ** យ៉ាងខ្លាំង បន្ទាប់មកពួកគេក៏បញ្ជូនមនុស្ស ៥០០នាក់ឱ្យធ្វើជាសិស្សរបស់ព្រះអង្គជំនួសឱ្យការប្រយុទ្ធគ្នា និងការស្លាប់ ពួកគេរៀនរំងាប់ចិត្តទាំងសម្រាប់ខ្លួនគេ និងសម្រាប់អ្នកដទៃផងដែរ ។

**វាក្យសព្ទ :**

**ទំនាស់ :** គឺជាការខ្វែងគំនិតគ្នារវាងមនុស្សពីរក្រុម (ឬបុគ្គលពីរនាក់) អំពីយោបល់ គុណតម្លៃ ឬអាកប្បកិរិយា ។

**អំពើហិង្សា :** គឺជាទង្វើទាំងឡាយណាដែលធ្វើឱ្យមានការឈឺចាប់ទាំងផ្លូវចិត្ត និងផ្លូវកាយ ។

**ដំណើរការបង្រៀន**

១. គ្រូអានរឿងនៅក្នុងថ្នាក់ "**ហេតុអ្វីអ្នកប្រយុទ្ធគ្នា?**"

២. **គ្រូសួរសិស្សនូវសំណួរខាងក្រោមៈ**

**ក.** ហេតុអ្វីបានជាប្រជាជននៅក្នុងសហគមន៍ទាំងពីរប្រយុទ្ធគ្នា?

**ខ.** ហេតុអ្វីបានជាទំនាស់ក្នុងរឿងនេះ រីកធំឡើងយ៉ាងឆាប់រហ័ស?

**គ.** ហេតុអ្វីបានជាប្រជាជនសប្បាយរីករាយចំពោះព្រះពុទ្ធ?

**ឃ.** តើគេអាចដោះស្រាយទំនាស់បាននៅពេលទំនាស់មានស្ថានភាពដូចម្ដេច? (**ចម្លើយចូលរួមៈ** ប្រជាជនគួរតែដោះស្រាយបញ្ហានៅពេលចាប់ផ្ដើមដំបូង មុនពេលក្លាយជាទំនាស់ ។)

**ង.** តើទំនាស់ផ្សេងៗទៀតអាចដោះស្រាយតាមរបៀបនេះបានដែរឬទេ? តើដោះស្រាយតាមរបៀបណា?

**ច.** តើសហគមន៍ ឬប្រទេសប្រយុទ្ធគ្នា ដោយសារមូលហេតុអ្វីផ្សេងពីនេះទៀត?

### ៣. សន្តិដ្ឋានៈ

ជាការប្រសើរសម្រាប់យើងក្នុងការព្យាយាមដោះស្រាយទំនាស់ មុននឹងឱ្យវាក្លាយជាអំពើហិង្សា ដែលបណ្ដាលឱ្យមនុស្សជាច្រើនត្រូវរងទុក្ខវេទនា ។ នៅពេលដែលយើងមានបញ្ហាកើតឡើង ហើយមិនបានដោះស្រាយដោយទុកឱ្យបញ្ហានោះ អូសបន្លាយពេលយូរទៅៗ នោះធ្វើឱ្យមនុស្សមានអារម្មណ៍ខឹងសម្បារខ្លាំងឡើងៗ ដែលជាហេតុធ្វើឱ្យមនុស្សងាយស្រួលក្នុងការប្រយុទ្ធគ្នា ។ ជួនកាលយើងមិនដឹងថាយើងប្រយុទ្ធគ្នាដើម្បីអ្វីផង ។ យើងនឹងក្លាយជាអ្នកជាប់ជំពាក់ក្នុងអារម្មណ៍ស្អប់ខ្ពើម និងខឹងសម្បារចំពោះអ្នកដទៃ ។ នៅក្នុងសាច់រឿងនេះ ព្រះពុទ្ធបានបង្ហាញដល់មនុស្សរាល់គ្នាផងដែរថា ការប្រយុទ្ធគ្នាអាចធ្វើឱ្យរងទុក្ខវេទនាជាងនេះ ហើយក៏គ្មាននរណាម្នាក់បានទទួលនូវអ្វីដែលពួកគេចង់បានទេ ។

# ការគ្រប់គ្រងពាក្យចចាមអារ៉ាម

គេអាចឃើញអ្នកនិយាយអេចអូច និងពាក្យចចាមអារ៉ាមនៅគ្រប់សហគមន៍ ឬក៏ឃើញនៅក្នុងចំណោមក្រុមនីមួយៗនៃមនុស្សនៅក្នុងពិភពលោក ។ ពេលដែលអ្នកនិយាយអេចអូច និងពាក្យចចាមអារ៉ាមដែលជាផ្នែកមួយនៃជីវិតរស់នៅប្រចាំថ្ងៃរបស់យើង វាក៏ធ្វើឱ្យអ្នកដទៃឈឺចាប់យ៉ាងខ្លាំង ។ ទោះបីថាអ្នកនិយាយអេចអូច និងពាក្យចចាមអារ៉ាម ពុំមែនតែងតែពិតជានិច្ចជាកាលនោះក៏ដោយ ក៏វាមានផ្ទុកព័ត៌មានដ៏គួរឱ្យឈឺចាប់ វាបង្កឱ្យមានកំហឹង និងទំនាស់ ។ ពាក្យចចាមអារ៉ាមសាយភាយលឿនណាស់ ពីព្រោះជាញឹកញាប់ប្រជាជនមិនមានចម្ងល់ពីអត្ថន័យរបស់ពាក្យចចាមអារ៉ាម ពួកគេទទួលយកពាក្យចចាមអារ៉ាម ហើយធ្វើតាមពាក្យចចាមអារ៉ាមដោយមិនបានបញ្ជាក់ពីការពិត ។ សកម្មភាពនេះជួយឱ្យសិស្សគិតពីរបៀបដែលពាក្យចចាមអារ៉ាមរីកសាយភាយ អំពីរបៀបកំចាត់ចោល និងរបៀបបញ្ឈប់ពាក្យចចាមអារ៉ាម ។

**វត្ថុបំណង** :

- ច: សិស្សយល់អំពីរបៀបដែលពាក្យចចាមអារ៉ាមអាចបង្កើត ឬធ្វើឱ្យទំនាស់កាន់តែរាលដាលខ្លាំងឡើង
- ប: សិស្សឈប់និយាយពាក្យចចារ៉ាម ឬផ្សព្វផ្សាយពាក្យចចាមអារ៉ាម
- ឥ: សិស្សឃើញថាការធ្វើឱ្យពាក្យចចាមរ៉ាមកាន់តែរីកសាយភាយ នោះមានន័យថា គេកំពុងចូលរួមធ្វើឱ្យអ្នកដទៃឈឺចាប់

**រយៈពេល** : ៣០ នាទី

**វាក្យសព្ទ :**

**ពាក្យចចាមអារ៉ាម:** គឺជារឿងដែលនិយាយតៗគ្នា ឬគំនិតដែលចរាចរដោយគ្មានមូលដ្ឋាន ឬប្រភពច្បាស់លាស់
**អ្នកនិយាយអេចអូច:** គឺអ្នកដែលតែងតែនិយាយពីរឿងមិនល្អរបស់អ្នកដទៃ ឬអ្នកដែលផ្សព្វផ្សាយពាក្យចចាមអារ៉ាម ។

**ដំណើកនាំមេរៀន:**

១. លេងល្បែង "**ចចាមអារ៉ាម**" ។ ឱ្យសិស្សអង្គុយជារង្វង់ ។ សិស្សខ្សឹប "**ដំណឹង**" មួយពីត្រចៀកសិស្សម្នាក់ទៅត្រចៀកសិស្សបន្ទាប់ម្នាក់ទៀត ។ ធ្វើរបៀបនេះរហូតដល់សិស្សទាំងអស់ឮដំណឹងនោះ ។ សិស្សចុងក្រោយដែលបានឮដំណឹងនោះ ត្រូវនិយាយខ្លាំងៗនូវអ្វីដែលគាត់បានឮ ប្រាប់ទៅសិស្សទាំងអស់ ។ ចូរប្រើដំណឹងដែលអាចប្រែក្លាយជាការគំរាមកំហែង ឬវិបត្តិធ្ងន់ធ្ងរបានដូចជា "**ស៊ីថាកំពុងរកមុខអ្នក ហើយនាងមានកាំភ្លើងមួយដើមផង**" ឬក៏និយាយថា "**ពិសាខ** បាន និយាយថាស្រឡាញ់មិត្តស្រីរបស់អ្នក" ជាដើម ។

២. សិស្សកំណត់ន័យនៃពាក្យចចាមអារ៉ាម និងអ្នកនិយាយអេចអូច (មើលវាក្យសព្ទខាងលើ)

៣. គ្រូសួរសិស្សនូវសំណួរខាងក្រោម (ដែលអាចជ្រើសរើសបាន)

ក. តើអាចឱ្យឧទាហរណ៍មួយអំពីពាក្យចចាមអារ៉ាមដែលអ្នកបានឮឬទេ?

ខ. តើវាជាការពិតដែរឬទេ?

គ. ចូរអ្នកគិតពីពាក្យចចាមអារ៉ាមមិនពិតណាមួយដែលអ្នកបានឮ ប៉ុន្តែមានមនុស្សធ្វើតាម តើមានអ្វីកើតឡើង?

ឃ. តើពេលណាដែលពាក្យចចាមអារ៉ាមធ្វើឱ្យអ្នកឈឺចាប់ ឬបង្កើតបញ្ហាសម្រាប់អ្នក?

ង. តើហេតុអ្វីក៏មានមនុស្សធ្វើការផ្សព្វផ្សាយពាក្យចចាមអារ៉ាមប្រកបដោយភាពបំផ្លិចបំផ្លាញបែបនេះ? តើពួកគេបានទទួលអ្វីខ្លះពីពាក្យចចាមអារ៉ាមទាំងនោះ? (**ចម្លើយចូលរួម:** ធ្វើឱ្យអ្នកដទៃឈឺចាប់ ឬសម្លុតអ្នកដទៃ ហើយប្រហែលជាធ្វើឱ្យអារម្មណ៍គេរីករាយ ។)

ច. តើពាក្យចចាមអារ៉ាមអាចធ្វើឱ្យទំនាស់រីករាលដាលឡើងបែបណាខ្លះទៀត?

ឆ. តើអ្នកត្រូវធ្វើអ្វីដើម្បីជាការទទួលខុសត្រូវពេលដែលឮពាក្យចចាមអារ៉ាមណាមួយ? (**ចម្លើយចូលរួម:** កុំស្តាប់វា កុំផ្សព្វផ្សាយបន្ត)

៤. ឱ្យសិស្សរចនារូបភាពផ្ទាំងធំមួយ សម្រាប់សាលារៀនដែលមានន័យប្រឆាំងនិងពាក្យចចាមអារ៉ាម ឧទាហរណ៍

ក. "ពាក្យចចាមអារ៉ាមអាចមានគ្រោះថ្នាក់ កុំចំណាយពេលឥតប្រយោជន៍មើលវា"

ខ. "គឺគ្រាន់តែជាពាក្យចចាមអារ៉ាមទេ ចូរកុំស្តាប់វា ចូរកុំផ្សព្វផ្សាយវាបន្តទៀត"

៥. **សន្និដ្ឋាន:**

ពាក្យចចាមអារ៉ាមអាចបណ្តាលឱ្យមានការឈឺចាប់ ។ ជាញឹកញាប់វាគ្មានការពិតទេ ប៉ុន្តែផ្សព្វផ្សាយទៅគេឆាប់ជឿណាស់ ។ វាអាចធ្វើឱ្យមនុស្សខ្មាស់អៀន ឬខឹងសម្បារ ។ ទោះបីពាក្យចចាមអារ៉ាមខ្លះមិនពិតក៏ដោយ ក៏មនុស្សមួយចំនួនធ្វើតាមវាដែរ ។ ដោយហេតុនេះ ទើបពាក្យចចាមអារ៉ាមបង្កើតបាននូវទំនាស់ និងអំពើហិង្សារវាងមនុស្ស និងមនុស្ស ។

នៅពេលដែលយើងឮពាក្យចចាមរ៉ាមណាមួយ ពេលនោះយើងគួរតែប្បីព្យាយាមស្វែងរកថាតើវាចេញពីប្រភពណាមក? តើវាពិតឬទេ? បើយើងមិនច្បាស់ថាតើវាពិត ឬអត់ យើងមិនគួរប្រាប់អ្នកដទៃឡើយ ព្រោះពាក្យចចាមអារ៉ាមនេះ អាចធ្វើឱ្យគេមានការឈឺចាប់ខ្លាំងណាស់ ។ ដូច្នេះគួរទុកវានៅក្នុងខ្លួនយើងវិញប្រសើរជាជាងយើងផ្សព្វផ្សាយបន្តទៅទៀត ។



# សុភាសិតស្តីពីទំនាស់នៅលើពិភពលោក

សុភាសិត គឺជាឃ្លាដែលមានគតិបណ្ឌិត និងការអប់រំទូន្មាន ហើយជាធម្មតាត្រូវបានផ្ទេរបន្តពីជំនាន់មួយទៅជំនាន់មួយ ដោយសារតែវាងាយស្រួលចងចាំ ។ វប្បធម៌របស់ជាតិសាសន៍នីមួយៗ មានសុភាសិតរៀងៗខ្លួន ។ ជួនកាលសុភាសិតរបស់វប្បធម៌ខ្លះ មានភាពប្រហាក់ប្រហែលនឹងសុភាសិតនៃវប្បធម៌ខ្លះទៀត ។ សុភាសិត គឺជាវិធីសាស្រ្តដ៏ល្អមួយសម្រាប់ចែករំលែកសារស្តីពីសន្តិភាព ។

**វត្ថុបំណង :**

- ចៈ តាមរយៈសុភាសិតដែលដកស្រង់ចេញពីប្រទេសនានាក្នុងពិភពលោក សិស្សអាចយល់ពីអត្ថន័យ និងទស្សនៈទាននៃពាក្យសន្តិភាព និងទំនាស់កាន់តែច្បាស់ ។
- បៈ សិស្សអភិវឌ្ឍបំណិនវិភាគដោយព្យាយាមស្វែងយល់អត្ថន័យនៃសុភាសិតទាំងនោះ
- ឥៈ សិស្សស្រឡាញ់គតិបណ្ឌិតរបស់ប្រទេសផ្សេងៗ ថាជាតម្លៃដ៏ខ្ពង់ខ្ពស់មួយ និងអនុវត្តតាមខ្លឹមសារសុភាសិត ។

**រយៈពេល** : ៣០នាទី

**សម្ភារ** : សន្លឹកក្រដាសសុភាសិត

**លំនាំនៃការបង្រៀនៈ**

១. គ្រូចែកសិស្សក្នុងថ្នាក់ជាក្រុមតូចៗដែលមានសមាជិកពីរ ឬបីនាក់ ។ គ្រូឱ្យសុភាសិតមួយទៅសិស្សមួយក្រុមៗ ហើយសួរពួកគេនូវសំណួរដូចតទៅ :

- ក. តើសុភាសិតនោះមានន័យដូចម្តេច?
- ខ. តើសុភាសិតនេះ បង្រៀនអ្នកអ្វីខ្លះអំពីសន្តិភាព និងទំនាស់?
- គ. តើប្រទេសកម្ពុជាមានសុភាសិតប្រហាក់ប្រហែលសុភាសិតទាំងនេះដែរឬទេ?
- ឃ. តើអ្នកបានរៀនសូត្រអ្វីខ្លះ ពីសុភាសិតនេះសម្រាប់ជីវិតរបស់អ្នក?

២. បន្ទាប់ពី ២០នាទីក្រោយមក គ្រូឱ្យសិស្សគ្រប់ក្រុមទាំងអស់បង្ហាញអំពីសុភាសិតរបស់ពួកគេ និងអត្ថន័យរបស់វា ។

៣. **សន្និដ្ឋានៈ**

ទំនាស់ជាបញ្ហាសកល ។ កន្លែងណាដែលមានមនុស្សរស់នៅកន្លែងនោះ តែងតែមានទំនាស់ ក៏ប៉ុន្តែក៏មានគតិបណ្ឌិត និងដំបូន្មានសម្រាប់ដោះស្រាយទំនាស់ទាំងនោះផងដែរ ។ យើងអាចចេះសុភាសិតជាច្រើនទៀតពីប្រទេសដទៃ ។ សុភាសិតគ្រាន់តែជាវិធីមួយជួយឱ្យយើងចេះបានច្រើនថែមទៀត អំពីរបៀបធ្វើឱ្យសម្រេចនូវសន្តិភាពក្នុងពិភពលោករបស់យើង ។

# សុភាសិតផ្សេងៗនៅក្នុងពិភពលោក

✂ ....................................................................................................

ពាក្យសំដីល្អតែមួយម៉ាត់ ជួយឱ្យអ្នកកក់ក្ដៅបានរយៈពេល៣រដូវរងា *(សុភាសិតប្រទេសចិន)*

✂ ....................................................................................................

ពាក្យពិរោះល្អៗទាំងឡាយមិនមានគិតថ្លៃទេ ដូច្នេះសូមអ្នកជ្រើសរើសយកពាក្យទាំងនោះទៅធ្វើឱ្យសប្បាយដល់ត្រចៀកអ្នកដទៃផង *(សុភាសិតប្រទេសវៀតណាម)*

✂ ....................................................................................................

ថ្ងៃនេះជាអគ្គីភ័យ ថ្ងៃស្អែកនឹងជាផេះ *(សុភាសិតប្រទេសអារ៉ាប់)*

✂ ....................................................................................................

នៅពេលដែលអ្នកជិតខាងធ្វើខុស អ្នកយកដៃចង្អុលចាប់កំហុសគេ ប៉ុន្តែនៅពេលអ្នកធ្វើខុសវិញ អ្នកយកដៃបិទបាំងវា *(សុភាសិតរបស់ជនជាតិភាគតិច អេកុងដា សាធារណរដ្ឋកុងហ្គោ អាហ្វ្រិកកណ្ដាល)*

✂ ....................................................................................................

ប្រសិនបើអ្នកយកម្រាមដៃមួយចង្អុលគេ នោះអ្នកនឹងមានម្រាមបីចង្អុលមកខ្លួនអ្នកវិញ

*(សុភាសិត នីស្សេរីយ៉ា អាហ្វ្រិកខាងលិច)*

✂ ....................................................................................................

ប្រសិនបើអ្នកធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ នោះអ្នកនឹងធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់ខ្លួនឯងផងដែរ

*(សុភាសិតនីស្សេរីយ៉ា អាហ្វ្រិកខាងលិច)*

✂ ....................................................................................................

នៅលើវាលរហោស្ថាន អ្នកឆ្លាតវៃតែងធ្វើដំណើរជាក្បួន ចំណែកឯអ្នកល្ងិតល្ងង់ចូលចិត្តធ្វើដំណើរតែម្នាក់ឯង

*(សុភាសិតអារ៉ាប់ ពីអាហ្វ្រិកខាងជើង)*

✂ ....................................................................................................

បន្ទាប់ពីមានមនុស្សធ្លាក់ទឹក ទើបគេជួសជុលស្ពាន *(សុភាសិត សូម៉ាលី)*

✂ ............................................................................................................................................

អ្នកដែលស្វែងរកការសងសឹក ត្រូវតែជីកផ្នូរពីរទុកឱ្យស្រេច *(សុភាសិតចិន)*

✂ ............................................................................................................................................

បើមិនមានការសងសឹកគ្នាទៅវិញទៅមកទេ នោះថ្ងៃណាមួយនឹងលែងមានអំពើអាក្រក់ នៅលើលោកយើងនេះទៀតហើយ *(សុភាសិត នីហ្សេរីយ៉ា អាហ្វ្រិកខាងលិច)*

✂ ............................................................................................................................................

ខ្យល់នឹងមិនធ្វើឱ្យដើមឈើដែលអោនបាក់បាននោះទេ *(ស៊ូគុម៉ា សុភាសិត តង់ហ្សានី អាហ្វ្រិកខាងកើត)*

✂ ............................................................................................................................................

មនុស្សដែលឆ្លាត តែងតែផ្លាស់ប្តូរចិត្តរបស់ខ្លួន *(សុភាសិត ជប៉ុន)*

✂ ............................................................................................................................................

ដើម្បីចូលប្រឡូកក្នុងទំនាស់ អ្នកមិនត្រូវយកកាំបិតមកកាត់ទេ ប៉ុន្តែត្រូវយកម្ជុលមកដេរវិញ

*(សុភាសិត ប្រទេសហ្ស៊ែមប៊ីយ៉ា)*

✂ ............................................................................................................................................

នៅពេលដៃស្តាំដុសលាងដៃឆ្វេង ហើយដៃឆ្វេងដុសលាងដៃស្តាំវិញ នោះដៃទាំងពីរនឹងស្អាត

*(សុភាសិត នីហ្សេរីយ៉ា អាហ្វ្រិកខាងលិច)*

# ទូរទស្សន៍ និង អំពើហិង្សា



អំពើហិង្សាតាមទូរទស្សន៍ ឬតាមខ្សែភាពយន្តជារឿងសាមញ្ញនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងពិភពលោក។ នៅពេលដែលគ្មានការត្រួតពិនិត្យ កែលំអកំហុស មាតាបិតាសិស្ស ក្រុមគ្រួសារ និងសិស្សខ្លួនឯងផ្ទាល់នឹងធ្វើការសម្រេចចិត្តខ្លួនឯងថា គួរមើលកម្មវិធីទូរទស្សន៍ណាដើម្បីមានសុខភាពល្អ។ មេរៀននេះមានបំណងធ្វើឱ្យសិស្សដឹងច្រើនថែមទៀតអំពីកម្មវិធីដែល ពួកគេកំពុងតែមើល។ នៅពេលពួកគេស៊ាំនឹងទិដ្ឋភាពនៃអំពើហិង្សា ហើយពួកសិស្សទាំងនោះអាចជឿថា អំពើហិង្សាគឺជាផ្នែកមួយនៃជីវិតធម្មតារបស់ពួកគេ ហើយដែលពួកគេអាចទទួលយកអំពើហិង្សាទាំងនោះបាន។ នេះជាទស្សនៈខុសឆ្គងមួយដែលជួយទ្រទ្រង់វដ្តនៃអំពើហិង្សាជំនួសវប្បធម៌សន្តិភាព។

**វត្ថុបំណង :**

ចៈ សិស្សគិត និងពិចារណាថា ទូរទស្សន៍មានឥទ្ធិពលយ៉ាងណា ទៅលើការគិត និងអាកប្បកិរិយារបស់ពួកគេ នឹងវាយតម្លៃផលប៉ះពាល់អវិជ្ជមាននៃការទស្សនាទូរទស្សន៍ហិង្សា

បៈ សិស្សគិតពិចារណាហ្មត់ចត់ឡើងវិញ អំពីកម្មវិធីអ្វីដែលពួកគេគួរជ្រើសរើសទស្សនា

ឥៈ សិស្សកែប្រែទម្លាប់មើលទូរទស្សន៍របស់ពួកគេ

**រយៈពេល :** ៣០ នាទី

**លំនាំនៃការបង្រៀនៈ**

១. គ្រូឱ្យសិស្សសរសេរប្រភេទនៃអំពើហិង្សា ដែលគេបានឃើញតាមកញ្ចក់ទូរទស្សន៍ (**ចម្លើយចូលរួមៈ** ការស្បថស្បែរ ការវាយតប់គ្នា ការប្រើកាំភ្លើង ការគំរាមកំហែង ការស្រែកគំហកដាក់គ្នា។ល។)

២. គ្រូឱ្យសិស្សរកនឹកគិតពីកម្មវិធីទូរទស្សន៍ដែលពួកគេបានទស្សនាកាលពីសប្តាហ៍កន្លងទៅ។ គ្រូឱ្យសិស្សគូរតារាងនៅក្នុងសៀវភៅរបស់គេ ហើយបំពេញចម្លើយ

ក. ចូរសរសេរឈ្មោះកម្មវិធីទូរទស្សន៍នៅតាមចន្លោះផ្នែកខាងលើបំផុតនៃតារាង

ខ. នៅបន្ទាត់ទីពីរ ឱ្យសិស្សសរសេរអំពីពេលវេលាដែលគេបានមើលកម្មវិធីនោះ និងកាលបរិច្ឆេទ

គ. ចូរសរសេរឈ្មោះប៉ុស្តិ៍ទូរទស្សន៍ដែលពួកគេបានមើល

ឃ. ហើយបន្ទាប់មក ឱ្យសិស្សសម្រេចថា តើគេគួរបែងចែកកម្មវិធីនោះជាប្រភេទអ្វីខ្លះៈ អំពើហិង្សាតាមរយៈពាក្យសំដី រឿងកំប្លែង រឿងស៊ើបអង្កេត រឿងស្នេហា រឿងខ្មោច។ល។ និង។ល។ ចូរសរសេរអំពីចំនួនម៉ោងក្នុងមួយសប្តាហ៍ ដែលអ្នកបានទស្សនាកម្មវិធីទូរទស្សន៍ទៅក្នុងតារាងម្ខាងទៀត។

៣. គ្រូឱ្យសិស្សឆ្លើយនឹងសំណួរដូចខាងក្រោម ដោយសរសេរនៅក្នុងសៀវភៅរបស់ពួកគេ។ (ដែលអាចជ្រើសរើសបាន)

ក. តើអ្នកមើលទូរទស្សន៍ប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍?

ខ. តើអ្នកគិតថា ការមើលទូរទស្សន៍របស់អ្នកវាច្រើនជ្រុលពេកដែរឬទេ?

គ. តើអ្នកអាចធ្វើអ្វីបានខ្លះ ជំនួសឱ្យពេលអ្នកចំណាយមើលទូរទស្សន៍?

ឃ. ក្នុងរយៈពេលដែលអ្នកចំណាយមើលទូរទស្សន៍នោះ តើរយៈពេលមានប៉ុន្មានភាគរយដែលអ្នកមើលអំពើហិង្សា?

ង. តើហេតុអ្វីក៏អ្នកចូលចិត្តមើលអំពើហិង្សាតាមទូរទស្សន៍? តើអ្នកគិតថាការមើលនោះវាល្អសម្រាប់អ្នកឬ? តើហេតុអ្វីអ្នកថាល្អ? ហេតុអ្វីថាមិនល្អ?

ច. តើអ្នកគិតថា អំពើហិង្សាជាផ្នែកមួយដែលអាចទទួលយកបានសម្រាប់ជីវិតដែរឬទេ? តើយើងគួរទទួលយកអំពើហិង្សាទាំងនោះបានទេ បើវាកើតឡើងក្នុងគ្រួសារ សាលារៀន ឬក្នុងសហគមន៍របស់យើង?

## ៤. សន្និដ្ឋានៈ

ជាញឹកញាប់រូបភាពដែលយើងមើលឃើញតាមទូរទស្សន៍ ឬក្នុងទស្សនាវដ្ដី មានលក្ខណៈអវិជ្ជមានច្រើន។ រូបភាពទាំងនោះ អាចជារូបភាពនិយាយអំពីសង្គ្រាម ការប្រយុទ្ធគ្នា និងមនុស្សដែលត្រូវគេធ្វើឱ្យឈឺចាប់ជាដើម។ ទោះបីជាយើងមិនទទួលស្គាល់វាយ៉ាងណាក៏ដោយ ក៏រូបភាពទាំងនោះអាចក្លាយជាចំណែកមួយនៃការគិតរបស់អ្នកដោយទស្សនាមិនដឹងខ្លួន។ មួយរយៈក្រោយមករូបភាពទាំងនោះលែងធ្វើឱ្យយើងរន្ធត់ទៀតហើយ ពេលនោះយើងនឹងគិតថារូបភាពទាំងនោះ ជាផ្នែកមួយនៃជីវិតធម្មតារបស់យើងដែលអាចទទួលបាន។ យើងគួរចំណាយពេលដែលយើងប្រើប្រាស់ក្នុងការមើលអំពើហិង្សាតាមទូរទស្សន៍ ទៅធ្វើកិច្ចការផ្សេងៗវាប្រសើរជាងដូចជា ទៅអានសៀវភៅ គូររូប រៀនជាក្រុមជាមួយមិត្តភក្ដិមើលខ្សែភាពយន្តឯកសារ សរសេរកំណត់ហេតុប្រចាំថ្ងៃ និងគិតពីអ្វីដែលដែលត្រូវធ្វើទៅអនាគត។

**តើអ្នកមើលទូរទស្សន៍ប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?**

| កម្មវិធី | តំនុំ និង ចម្លោសចម្លៀតនា | ភាពយន្ត | ប្រដាល់ | ------ | ------ | ចំនួនម៉ោងសរុបក្នុងមួយសប្ដាហ៍ |
|---|---|---|---|---|---|---|
| ម៉ោង | ១៧-១៨ | ២០-២១ | ១៦-១៨ | | | |
| ថ្ងៃណាខ្លះ | សៅរ៍ | សុក្រ | អាទិត្យ | | | |
| ប៉ុស្តិ៍ | ទទក | ទទខ ៩ | ទទខភម ៥ | | | |
| អំពើហិង្សាតាមរយៈពាក្យសំដី | ✓ | | | | | ១ ម៉ោង |
| រឿងកំប្លែង/រឿងគួរឱ្យចង់សើច | | | | | | |
| ឃាតកម្ម/ហិង្សាលើរាងកាយ | ✓ | | | | | ១ ម៉ោង |
| តន្ត្រី | | | | | | |
| ភាពយន្តតុក្កតា | | | | | | |
| រឿងស្នេហា | ✓ | ✓ | | | | ២ ម៉ោង |
| ការអប់រំ/ភាពយន្តឯកសារ | | | | | | |
| ភាពយន្តកូនជ្រូក | | | | | | |
| រឿងរន្ធត់/ខ្មោច | | | | | | |
| កីឡា/ផ្សេងៗ | | | ✓ | | | ២ ម៉ោង |
| ចំនួនម៉ោងសរុបនៃការមើលទូរទស្សន៍ក្នុងមួយសប្ដាហ៍ | | | | | | ៦ ម៉ោង |

# ផលវិបាកនៃការប្រើប្រាស់អាវុធ

ទោះបីជាជម្លោះប្រដាប់អាវុធនៅក្នុងប្រទេសកម្ពុជាបានបញ្ចប់យូរមកហើយក្តី ក៏អាវុធជាច្រើនបានកំពុងតែស្ថិតនៅរាយប៉ាយនៅក្នុងប្រទេសកម្ពុជាដែរ ។ ការប្រើប្រាស់អាវុធទាំងនោះ បានផ្តល់ផលវិបាកយ៉ាងធ្ងន់ធ្ងរសម្រាប់ប្រជាជនទាំងនៅក្នុងផ្ទះ និងក្នុងសហគមន៍របស់ពួកគេ ។ សហគមន៍របស់យើងនឹងមានសុវត្ថិភាពជាងនេះ បើគ្មានអាវុធទាំងនោះ ។ មេរៀននេះជួយឱ្យសិស្សគិតពីផលវិបាកនៃការប្រើប្រាស់អាវុធ ហើយជួយសិស្សគិតថា ពួកគេត្រូវធ្វើអ្វីដើម្បីកាត់បន្ថយអាវុធជាតិផ្ទុះ ។

**វត្ថុបំណង :**

ក. សិស្សយល់អំពីផលវិបាកនៃការកាន់កាប់ និងការប្រើប្រាស់អាវុធជាលក្ខណៈបុគ្គល និងសហគមន៍

ខ. សិស្សដឹងថាពួកគេគួរធ្វើយ៉ាងណាដើម្បីប្រមូលអាវុធខុសច្បាប់ចេញពីសហគមន៍

គ. សិស្សមានឆន្ទៈក្នុងការជួយលុបបំបាត់អាវុធខុសច្បាប់នៅកម្ពុជា

**រយៈពេល :** ៣០ នាទី

**សម្ភារ : រឿងរបស់យុវជនអាយុ ១៨ឆ្នាំ**

**ដំណើរការមេរៀន :**

១. អានរឿងខាងក្រោមឱ្យសិស្សស្តាប់ (រឿងរបស់យុវជនអាយុ ១៨ឆ្នាំ នៅខេត្តបន្ទាយមានជ័យ)

### រឿងរបស់យុវជនអាយុ ១៨ឆ្នាំ



រាត្រីមួយ នៅពេលដែលខ្ញុំកំពុងដេកស្កប់ស្កល់ បុរសពីរនាក់បានចូលមកដល់ផ្ទះខ្ញុំ ។ ពួកគេបានបាញ់សម្លាប់ឪពុកខ្ញុំ ហើយវាយម្តាយរបស់ខ្ញុំដោយកាំភ្លើងអាកា ៥៩ (AK59) ។ ខ្ញុំបានឮប្អូនស្រីខ្ញុំស្រែកហៅខ្ញុំឱ្យក្រោកពីដេក ហើយខ្ញុំក៏ក្រោកភ្លាម នាងបានទុកកាំបិតវែងមួយក្បែរខ្ញុំ បន្ទាប់មកខ្ញុំបានរត់ទៅកាន់ផ្ទះប្រធានភូមិដើម្បីសុំជំនួយ ។ ប៉ុន្តែគ្មាននរណាមកជួយពួកយើងឡើយ ពីព្រោះជនល្មើសមានកាន់អាវុធ ។ ខ្ញុំបានឃើញបុរសទាំងពីររត់ចេញពីផ្ទះ ហើយពួកគេមិនបានយកម៉ូតូរបស់យើងទេ គឺពួកគេបានប្លន់យកតែខ្សែកមាសម្តាយខ្ញុំតែប៉ុណ្ណោះ ។

ជនល្មើសគឺជាអ្នកជិតខាងរបស់ខ្ញុំដែលសងសឹកជាមួយគ្រួសារខ្ញុំ ព្រោះតែការឈ្លោះប្រកែកគ្នាដោយសារពាក្យសំដីកាលពីសប្តាហ៍មុន។ ពួកគេមានជម្លោះនេះ ដោយសារម្តាយរបស់ខ្ញុំបានសុំឱ្យចែកលុយដែលម្តាយខ្ញុំ និងប្រពន្ធអ្នកជិតខាងបានរកស៊ីរួមគ្នាពីការងារមួយនៅក្នុងប្រទេសថៃ។

ក្រៅពីសម្លាប់ឪពុកខ្ញុំ និងបង្កឱ្យមានរបួសដល់ម្តាយខ្ញុំ ជនល្មើសបានគំរាមកំហែងដល់គ្រួសារខ្ញុំថា គេនឹងសម្លាប់ពួកយើងទាំងអស់។ ម្តាយខ្ញុំបានប្តឹងរឿងនេះទៅប៉ូលីសស្រុក និងតុលាការខេត្តរួចហើយ ប៉ុន្តែគេបានសួរម្តាយខ្ញុំថា តើអ្នកមានលុយសូកប៉ាន់តុលាការទេ? ចាប់ពីពេលនោះមក គ្រួសាររបស់ខ្ញុំត្រូវរស់ឃ្លាតឆ្ងាយពីគ្នា។ ម្តាយខ្ញុំត្រឡប់ទៅប្រទេសថៃដើម្បីសុំទានគេ ហើយបងប្អូនប្រុស-ស្រីរបស់ខ្ញុំរស់នៅក្នុងមណ្ឌលកុមារកំព្រាក្នុងខេត្តផ្សេងមួយទៀត ដើម្បីកុំឱ្យមានការគំរាមកំហែងដល់ជីវិត។ ខ្ញុំរស់នៅភូមិដដែល ប៉ុន្តែរស់នៅជាមួយអ្នកជិតខាងដែលនៅឆ្ងាយពីផ្ទះខ្ញុំ។ ខ្ញុំមិនអាចត្រលប់ទៅផ្ទះរបស់ខ្ញុំផ្ទាល់ក្នុងភូមិបានទេ ពីព្រោះខ្ញុំខ្លាចជនល្មើសគំរាមកំហែងចង់សម្លាប់ខ្ញុំ។

(រឿងរបស់យុវជនអាយុ ១៨ឆ្នាំ នៅខេត្តបន្ទាយមានជ័យ)[១]

២. គ្រូសួរសិស្សក្នុងថ្នាក់

**ក.** តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចដែរចំពោះរឿងនេះ?

**ខ.** តើអ្នកដឹងរឿងអ្វីផ្សេងដែលប្រហាក់ប្រហែលរឿងនេះដែរឬទេ?

**គ.** ហេតុអ្វីក៏មនុស្សនៅតែរក្សាកាំភ្លើងទុក?

**ឃ.** តើកាំភ្លើងទាំងនោះបានមកពីណា?

៣. បំផុសគំនិតក្នុងក្រុមតូចៈ

បំបែកសិស្សជាក្រុមតូចៗ ហើយឆ្លើយនឹងសំណួរដូចខាងក្រោម :

ក. តើអាវុធមានផលប៉ះពាល់អ្វីខ្លះដល់រាងកាយមនុស្ស?

ខ. តើអាវុធមានផលប៉ះពាលអ្វីខ្លះ ដល់ផលប្រយោជន៍គ្រួសារ និងសហគមន៍?

**ចម្លើយចូលរួម :**

**លទ្ធផលដែលអាច :**

នៅពេលដែលមនុស្សប្រើប្រាស់អាវុធខុសច្បាប់ ពួកគេមានរបួសស្នាមខ្លួនគេ ឬធ្វើឱ្យអ្នកដទៃរងរបួស ឬអ្នកនោះត្រូវបានបញ្ជូនទៅពន្ធនាគារ ។ ខាងក្រោមនេះជាផលវិបាកនៃឥទ្ធិពលទាំងនោះ

- កូនៗត្រូវបានឈប់រៀន
- សមត្ថភាពរកប្រាក់ចំណូលត្រូវបានថយចុះ
- បាក់មុខក្នុងសង្គម ឬត្រូវសង្គមមើលងាយ

[1] Yem Sam Oeun and Catalla, R.F., “I live in fear”, Consequences of Small Arms and Light Weapons on Woman and Children in Cambodia. WGWR, June 2001.

- មានការភ័យខ្លាច បញ្ហាសុខភាពផ្លូវចិត្ត មានកង្វល់ ការព្រួយបារម្ភណ៍ ការខឹងឆេវឆាវ
- កូនៗអាចក្លាយជាកុមារកំព្រា ឬក្មេងអនាថា
- មានគំនុំគំគួនចង់សងសឹក ឬត្រូវការអាវុធដើម្បីការពារគ្រួសារ
- ក្រុមគ្រួសារអាចផ្លាស់ប្តូរទីលំនៅដើម្បីស្វែងរកការការពារ ឬលាក់ខ្លួន
- ជំពាក់បំណុល លក់ទ្រព្យសម្បត្តិ ឬបាត់បង់ទ្រព្យសម្បត្តិ
- បាត់បង់សមាជិកគ្រួសារ និងមិត្តភក្តិ
- ការញៀនថ្នាំ រកស៊ីផ្លូវភេទ ក្លាយជាក្មេងពាល

៤. តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សា

៥. **គ្រូបំផុសគំនិតសិស្ស:** តើប្រជាពលរដ្ឋអាចធ្វើអ្វីខ្លះ ដើម្បីកាត់បន្ថយអាវុធក្នុងសហគមន៍របស់ពួកគេ?

ចំលើយទាំងអស់គួររួមបញ្ចូលចំលើយខាងក្រោមផងដែរ

- រាយការណ៍ជូនប៉ូលីស ឬប្រធានភូមិ ឬរដ្ឋអំណាចមូលដ្ឋាននៅពេលដែលពួកគេប្រទះឃើញគ្រាប់មិនទាន់ផ្ទុះ ឃើញមនុស្សកាន់អាវុធជាតិផ្ទុះខុសច្បាប់ និងការប្រព្រឹត្តិបទឧក្រិដ្ឋដោយប្រើអាវុធជាតិផ្ទុះ ។
- បើអ្នកចង់យកអាវុធទៅប្រគល់ជូនអាជ្ញាធរ អ្នកត្រូវរកមនុស្សដែលអ្នកទុកចិត្តបាន (អ្នកនោះអាចជាអាចារ្យវត្ត មេភូមិ មេឃុំ ឬអង្គការក្រៅរដ្ឋាភិបាលដែលមានកម្មវិធីទាក់ទងនឹងអាវុធ) ហើយអ្នកដែលយើងទុកចិត្តនោះ ត្រូវទៅធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរក្នុងការប្រគល់អាវុធនេះ ។
- ចូលរួមសកម្មភាពប្រមូលអាវុធជាតិផ្ទុះរបស់រាជរដ្ឋាភិបាល
- ជួយប្រាប់អ្នកដទៃអំពីច្បាប់អាវុធ
- ជំរុញឱ្យមានកិច្ចសហការក្នុងចំណោមអ្នកភូមិដើម្បីស្វែងរក និងរាយការណ៍ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតអំពីគ្រាប់មីន និងអាវុធជាតិផ្ទុះខុសច្បាប់ ។
- សុំជំនួយពីប៉ូលីស រដ្ឋអំណាចមូលដ្ឋាន ឬប៉េអឹម បើមានការគំរាមកំហែងដល់គ្រួសារដោយការប្រើប្រាស់អាវុធជាតិផ្ទុះ ប្តឹងជនល្មើសដែលប្រព្រឹត្តបទល្មើស (ឧ-ចង់យកដីរបស់គ្រួសារ) ។
- អប់រំសមាជិកគ្រួសារមិនឱ្យមានអំពើហិង្សា ជាពិសេសការប្រើប្រាស់អាវុធដើម្បីដោះស្រាយជម្លោះ ។ អប់រំគេ ឱ្យដឹងអំពីផលប៉ះពាល់នៃហិង្សាបែបនោះ ។
- លើកទឹកចិត្តសមាជិកក្នុងគ្រួសារឱ្យយកអាវុធទៅប្រគល់ជូនអាជ្ញាធរបើគេមាន ។
- ក្រើនរំលឹកមិត្តភក្តិអំពីផលប៉ះពាល់អវិជ្ជមាននៃការកេះគ្រាប់ដែលមិនទាន់ផ្ទុះលេង (unexploded ordnance,UXOs) ឬយក កាំភ្លើងទៅដោះស្រាយបញ្ហាពេលមានទំនាស់ ។

៧. គ្រូសួរសិស្ស ៖

តើអ្វីជាជម្រើសក្នុងការដោះស្រាយបញ្ហាដោយមិនប្រើអាវុធ? គ្រូកត់ត្រាចម្លើយរបស់សិស្ស ដាក់លើក្ដារខៀន

៨. **សន្និដ្ឋាន៖**

វាមានសារៈសំខាន់ណាស់ដែលយើងព្យាយាមយកចេញឱ្យអស់នូវអាវុធខុសច្បាប់ពីសហគមន៍របស់យើង។ ផលប៉ះពាល់នៃអាវុធជាតិផ្ទុះបែបនេះមានលក្ខណៈអវិជ្ជមានខ្លាំងណាស់ ពីព្រោះវាបង្កឱ្យមានភាពក្រីក្រ ការភ័យខ្លាច និងការឈឺចាប់ដល់មនុស្សជាច្រើន។ ប្រសិនបើអ្នកដឹងព័ត៌មានពីអាវុធខុសច្បាប់ អ្នកគួររាយការណ៍ប្រាប់ទៅប៉ូលិស ឬអ្នកគួរលើកទឹកចិត្តជនដែលមានអាវុធដើម្បីឱ្យគេយកអាវុធនោះប្រគល់ជូនទៅអាជ្ញាធរមូលដ្ឋាន ។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀនសីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១០ មេរៀនៈ ការជួយសង្គ្រោះជីវិតអ្នកដទៃ នៃកម្មវិធីរបស់ ក្រសួងអប់រំយុវជន និងកីឡា*

# គោលការណ៍សម្រាប់ការរស់នៅរបស់សហគមន៍យើង

វិន័យទាំងឡាយមានសារៈសំខាន់សម្រាប់ជួយជៀសវាងទំនាស់ ឬជួយកសាងនូវសន្តិភាព ។ នៅពេលដែលវិន័យណាមួយមិនត្រូវបានឯកភាពដោយក្រុម ឬសហគមន៍នោះ វានឹងនាំមកនូវភាពវឹកវរ ។ មនុស្សម្នាក់ៗនឹងប្រព្រឹត្តតាមអំពើចិត្ត ដែលគេចង់ធ្វើ ហើយគ្មាននរណាម្នាក់ដឹងថា អ្វីនឹងរំពឹងទុកអំពីអ្វីខ្លះទេ ។ ប្រសិនបើមានវិន័យ និងគ្មានការបង្ខិតបង្ខំនៃវិន័យទាំងនោះ អ្នកដែលគោរពតាមគោលការណ៍ទាំងនោះនឹងស្រងាកចិត្ត ។ មេរៀននេះ មានគោលបំណងធ្វើឱ្យមានភាពផ្សារភ្ជាប់គ្នារវាងសារៈសំខាន់នៃច្បាប់គោលការណ៍ និងវិន័យសម្រាប់អភិបាលកិច្ចក្រុមដើម្បីជៀសវាងទំនាស់ ។

**វត្ថុបំណង :**

- ចៈ សិស្សយល់អំពីសារៈសំខាន់នៃការបង្កើតគោលការណ៍សម្រាប់សហគមន៍ និងការអនុវត្តន៍តាមគោលការណ៍នោះទាំងអស់គ្នា
- បៈ សិស្សនឹងគោរពតាមវិន័យនៃសាលារៀនរបស់គេ ព្រោះពួកគេយល់អំពីតួនាទីនៃវិន័យទាំងនោះ ដែលគាំទ្រឱ្យមានការរស់នៅដោយចេះអធ្យាស្រ័យគ្នាទៅវិញទៅមកប្រកបដោយសន្តិភាព
- ឥៈ សិស្សនឹងកោតសរសើរអំពីតួនាទីនៃច្បាប់ ឬវិន័យទាំងនោះក្នុងអភិបាលកិច្ចក្រុមមនុស្ស

**រយៈពេល :** ៣០ នាទី

**លំនាំនៃការបង្រៀនៈ**

១. គ្រូសួរទៅសិស្សក្នុងថ្នាក់ :

តើសាលារៀននេះមានបទបញ្ជាផ្ទៃក្នុងអ្វីខ្លះ? គ្រូកត់ត្រាចម្លើយសិស្សលើក្តារខៀន ។

**ចំណាំ:** ប្រសិនបើគ្រូមានបទបញ្ជាអ្វីបន្ថែមសម្រាប់សិស្សរបស់គាត់ គាត់ក៏អាចកត់ត្រាបញ្ចូលបានដែរ ។

២. **គ្រូសួរសិស្សៈ**

- ក. ហេតុអ្វីបានជាយើងមានបទបញ្ជាទាំងនេះ? ( **ចម្លើយចូលរួមៈ** បទបញ្ជា ឬគោលការណ៍ដែលបានព្រមព្រៀងគ្នាអាចជួយយើងដើម្បីឱ្យដឹងនូវអ្វីដែលយើងរំពឹងទុកសម្រាប់យើង និងយើងក៏ដឹងផងដែរថា តើអ្វីដែលយើងអាចធ្វើបាន និងអ្វីមិនអាចធ្វើបាន)
- ខ. តើអ្វីខ្លះជាការជំពាក់ទាក់ទងនឹងការប្រព្រឹត្តល្មើសនឹងវិន័យសាលា? តើនឹងមានអ្វីកើតឡើងសម្រាប់អ្នក? ( **ចម្លើយចូលរួមៈ** អ្នកអាចនឹងត្រូវបានគេបញ្ជូនទៅឱ្យនាយកសាលា អ្នកនឹងត្រូវបណ្តេញចេញពីសាលាសាលានិងកោះហៅមាតាបិតាអ្នកមកជាមិនខាន)
- គ. តើអ្នកឯកភាពនិងគោរពបទបញ្ជាផ្ទៃក្នុងរបស់សាលារៀនឬទេ? ហេតុអ្វីឯកភាព? ហេតុអ្វីមិនឯកភាព?
- ឃ. ប្រសិនបើអ្នកចង់បង្កើតបទបញ្ជាថ្មី តើអ្នកគួរបង្កើតអ្វីខ្លះ?

ង. តើនឹងមានអ្វីកើតឡើងប្រសិនបើគ្មានបទបញ្ជានៅក្នុងសាលា? ឬប្រសិនបើគ្មាននរណាម្នាក់គោរព?

ច. ប្រសិនបើសិស្សពីរនាក់ល្មើសនឹងវិន័យសាលាដូចគ្នា ហើយមានសិស្សតែម្នាក់ប៉ុណ្ណោះដែលទទួលទណ្ឌកម្ម តើអ្នកមានអារម្មណ៍ដូចម្តេច? តើសិស្សដែលទទួលទណ្ឌកម្មមានអារម្មណ៍ដូចម្តេច? តើសិស្សដែលមិនទទួលទណ្ឌកម្មមានអារម្មណ៍ដូចម្តេច? ( **ការពន្យល់:** បទបញ្ជា ឬវិន័យត្រូវតែបានគ្រោងឡើងដោយសមភាព។ នៅពេលសិស្សម្នាក់មិនត្រូវបានធ្វើទណ្ឌកម្ម សិស្សដទៃទៀតនឹងមានការខកចិត្ត ដែលអាចឈានទៅដល់ការថ្នាំងថ្នាក់ចិត្ត និងមានទំនាស់នៅទីបំផុត) ។

៣- គ្រូឱ្យសិស្សធ្វើការពីរនាក់ដើម្បីឆ្លើយនឹងសំណួរដូចខាងក្រោម :

ក. ចូរសរសេរមធ្យោបាយ៣យ៉ាងដែលលើកទឹកចិត្តសិស្សឱ្យគោរពវិន័យបានប្រសើរឡើង។ ( **ចម្លើយចូលរួម:** ការណែនាំល្អពីគ្រូ ការទទួលស្គាល់សម្រាប់ការងារល្អ បន្ទប់រៀនមានបរិយាកាសល្អ) ។ល។

ខ. ចូរសរសេរឈ្មោះទារុណកម្មឱ្យបាន៣ប្រភេទដែលធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អ និងបន្សល់ទុកឱ្យអ្នកនូវកំហឹង ( **ចម្លើយចូលរួម:** វាយ បណ្តេញចេញពីថ្នាក់ ការធ្វើឱ្យអាប់កិត្តិយស ។ល។)

## ៤. សន្និដ្ឋាន:

នៅពេលយើងព្យាយាមធ្វើការទាំងអស់គ្នាជាក្រុមមួយ ឬសហគមន៍មួយ (ដូចជានៅសាលារៀនក្នុងការិយាល័យ ឬសូម្បីតែក្នុងប្រទេសមួយទាំងមូល) យើងត្រូវការគោលការណ៍ ឬវិធានដើម្បីជួយដឹកនាំអាកប្បកិរិយារបស់យើង។ ប្រសិនបើយើងត្រូវបានផ្តល់ដំបូន្មានអំពីវិន័យ យើងអាចរួមចំណែកចែករំលែកយោបល់របស់យើងផ្ទាល់ នោះយើងនឹងឱ្យតម្លៃវិន័យនោះ ហើយគោរពតាមគោលការណ៍ និងវិធានទាំងនោះ។

ប្រសិនបើមាននរណាម្នាក់ល្មើសនឹងវិន័យ ពួកគេនឹងទទួលនូវផលវិបាក។ ប្រសិនបើយើងត្រូវបានដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ឬក៏យ៉ាងអាម៉ាស់មុខនោះ យើងនឹងមានការខកចិត្ត ហើយគ្មានអារម្មណ៍ល្អអំពីក្រុមឡើយ។ ប៉ុន្តែប្រសិនបើយើងត្រូវបានលើកទឹកចិត្តនោះ យើងមានអារម្មណ៍ល្អអំពីក្រុម ហើយយើងនឹងគោរពវិន័យ របស់ក្រុម។

ប្រសិនបើមនុស្សត្រូវអនុញ្ញាតឱ្យប្រព្រឹត្តល្មើសនឹងវិន័យដោយគ្មានទណ្ឌកម្ម គឺវាអយុត្តិធម៌សម្រាប់អ្នកដទៃ។ ភាពអយុត្តិធម៌នេះអាចឈានទៅរកអារម្មណ៍ខកចិត្ត និងទំនាស់នៅទីបំផុត។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី.១១. មេរៀន: ប្រពន្ធ័ច្បាប់នៅកម្ពុជា នៃកម្មវិធីរបស់ក្រសួងអប់រំយុវជន និងកីឡា*

# សន្តិសុខនៅក្នុងជីវិតរបស់ខ្ញុំ

នៅគ្រប់សហគមន៍ យើងតែងតែប្រឈមមុខទៅនឹងស្ថានភាពអសន្តិសុខដូចជាៈ ឧក្រិដ្ឋកម្ម អំពើហិង្សាក្នុងគ្រួសារ គ្រោះមហន្តរាយដែលបង្កឡើងដោយធម្មជាតិ ការគំរាមកំហែងចំពោះសុខភាព និងទំនាស់ផ្សេងៗ។ មេរៀននេះមានគោលបំណងបំផុសបទពិសោធន៍ និងអារម្មណ៍របស់សិស្សស្តីអំពីសន្តិសុខ និងអសន្តិសុខ។ មេរៀននេះ ក៏សង្កត់ធ្ងន់ផងដែរលើសន្តិសុខផ្លូវកាយ ប៉ុន្តែក៏បានបង្ហាញសិស្សឱ្យយល់ថា មានទិដ្ឋភាពខ្លះដែលអាចធ្វើឱ្យយើងមានអារម្មណ៍ថា មានសុវត្ថិភាព ឬគ្មានសុវត្ថិភាព រួមទាំងសន្តិសុខអារម្មណ៍ សន្តិសុខវប្បធម៌ និងសន្តិសុខនយោបាយ។ មេរៀននេះផ្សារភ្ជាប់អារម្មណ៍នៃសន្តិសុខទៅនឹងការទប់ស្កាត់ទំនាស់។

**វត្ថុបំណង :**

ចៈ សិស្សប្រាប់បានពីទស្សនៈទាននៃពាក្យសន្តិសុខ និងមានការយល់ដឹងអំពីអត្ថន័យនៃពាក្យ "មានសន្តិសុខ"

បៈ សិស្សពិចារណារកវិធីកាត់បន្ថយគ្រោះថ្នាក់នៅក្នុងស្ថានភាពអសន្តិសុខ

ឥៈ សិស្សស្ទង់អារម្មណ៍របស់គេផ្ទាល់ ស្តីអំពីការរស់នៅ ទាក់ទិននឹងសុវត្ថិភាព

**រយៈពេល :** ៤០នាទី

**វាក្យស័ព្ទ :**

**សន្តិសុខរាងកាយៈ** មានអាហារបរិភោគ មានសំលៀកបំពាក់សម្រាប់ស្លៀកពាក់ និងមានលំនៅស្ថានសម្រាប់រស់នៅ ការពារមិនឱ្យមានជំងឺមកបៀតបៀន និងការព្យាបាលជំងឺជាដើម។

**សន្តិសុខសុវត្ថិភាពៈ** គឺជាភាពមានសណ្តាប់ធ្នាប់ មានច្បាប់សម្រាប់ការពារ និងមានការការពារទប់ទល់នឹងការធ្វើទុក្ខទោសលើរាងកាយ ការរំលោភបំពាន ហិង្សា ភេរវកម្ម និងភាពទទួលបាននូវតម្រូវការជាមូលដ្ឋាន។

**សន្តិសុខអារម្មណ៍ៈ** គឺជាអារម្មណ៍ដែលថា ខ្លួនយើងត្រូវបានអ្នកដទៃស្រលាញ់យកចិត្តទុកដាក់ អារម្មណ៍ដែលថាខ្លួនយើងត្រូវបានទទួលការរាប់អានពីអ្នកដទៃ អារម្មណ៍មានទំនាក់ទំនងប្រសើរជាមួយសមាជិកក្នុងគ្រួសារ មិត្តភក្តិ មិត្តស្រករវ័យ មនុស្សពេញវ័យ ឬសហសេវិកជាដើម។

**សន្តិសុខអភិវឌ្ឍន៍ៈ** គឺជាលទ្ធភាពដើម្បីទទួលបាននូវការអប់រំ ឱកាស និងសេរីភាពក្នុងការរៀនសូត្រ ក្នុងការសម្រេចសមិទ្ធិផល និងការរួមចំណែកដើម្បីបុព្វហេតុសង្គមដែលខ្លួនរស់នៅ។

**សន្តិសុខវប្បធម៌ៈ** គឺជាការអះអាងបញ្ជាក់នូវអត្តសញ្ញាណវប្បធម៌ តំលៃនៃវប្បធម៌ និងប្រពៃណី ការគោរព និង ការពារផ្អែកច្បាប់ដល់ជនជាតិ ពូជសាសន៍ សាសនា យេនឌ័រ សេរីភាពក្នុងការចូលរួមក្នុងសង្គមក្នុងនាមជាដៃគូពេញមុខដោយមិនគិតពីអត្តសញ្ញាណវប្បធម៌អ្វីឡើយ។

**សន្តិសុខនយោបាយ:** គឺជាការការពារ និងសុវត្ថិភាពដែលរដ្ឋាភិបាលមួយផ្តល់ជូនប្រជាពលរដ្ឋក្នុងនាមសញ្ជាតិមួយ ហើយវាក៏ជាការការពារពីការគំរាមកំហែងពីប្រជាជាតិដទៃ ដែលនៅជិតខាងជាមួយគ្នាដែរ ។ សន្តិសុខនយោបាយ គឺជាគុណភាព និងកិត្តិនៃសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការធ្វើការសម្រេចចិត្ត

**សន្តិសុខសេដ្ឋកិច្ច:** គឺជាលទ្ធភាពទទួលបាននូវការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ជំនាញដ៏មានប្រយោជន៍ គឺជាលទ្ធភាពសម្រាប់ទទួលបានការងារ និងប្រាក់កម្រៃសមស្រប ការផ្តល់ជូននូវអត្ថប្រយោជន៍ចំពោះជនចាស់ជរា អ្នកមានជំងឺ ជនពិការ និងកុមារ ។

**សន្តិសុខបរិស្ថាន:** គឺការការពារឱ្យរួចផុតពីគ្រោះមហន្តរាយនានា ដែលបណ្តាលមកពីបរិស្ថាន និងជាតិពុល ការផ្តល់ជូននូវខ្យល់ ទឹក និងអាហារដែលមានអនាម័យ និងមានសុវត្ថិភាព ព្រមទាំងជាការផ្តល់នូវទីកន្លែងរស់នៅដែលមានអនាម័យ និងសុវត្ថិភាព ។

**លំនាំនៃការបង្រៀន :**

១. គ្រូធ្វើការបំផុសគំនិតសិស្សក្នុងថ្នាក់អំពីអ្វីដែលមនុស្សត្រូវការ ដើម្បីឱ្យមានសុវត្ថិភាពបំផុត ហើយសរសេររាល់ចម្លើយទាំងនោះនៅលើក្តារខៀន

២. គ្រូសរសេរប្រភេទសន្តិសុខដូចខាងក្រោមនៅលើក្តារខៀន: សន្តិសុខរាងកាយ សន្តិសុខសុវត្ថិភាព សន្តិសុខអារម្មណ៍ សន្តិសុខអភិវឌ្ឍន៍ សន្តិសុខវប្បធម៌ សន្តិសុខនយោបាយ សន្តិសុខសេដ្ឋកិច្ច និងសន្តិសុខបរិស្ថាន (មិនចាំបាច់សរសេរ និយមន័យទាំងស្រុងរបស់សន្តិសុខនីមួយៗទេ) ។

៣. ឱ្យសិស្សពន្យល់អត្ថន័យនៃពាក្យទាំងអស់នេះ (ដើម្បីឱ្យយល់កាន់តែច្បាស់ សូមមើលវាក្យស័ព្ទនៅខាងដើម)

៤. ឱ្យសិស្សរកឧទាហរណ៍មួយសម្រាប់សន្តិសុខនីមួយៗ

៥. ឱ្យសិស្សសរសេរប្រភេទសន្តិសុខឱ្យបានបីដែលគេគិតថាសំខាន់បំផុតចំពោះខ្លួនគេ ហើយពន្យល់ពីមូលហេតុផង

៦. គ្រូសួរសិស្សនូវសំណួរដូចខាងក្រោម:

   ក. តើយើងអាចធ្វើអ្វីខ្លះដើម្បីបង្កើនសន្តិសុខសម្រាប់ខ្លួនយើង និងសហគមន៍របស់យើង? (**ចំណាំ:** ប្រសិនបើសិស្សឆ្លើយថា យកអាវុធជាមធ្យោបាយដើម្បីបង្កើនសុវត្ថិភាពនោះ គ្រូគួរសម្របសម្រួលការពិភាក្សាស្តីពីអាវុធ និងសន្តិសុខ ។ ការយកអាវុធមកការពារការរំលោភបំពាននោះភាគច្រើនគឺនាំឱ្យអ្នកនោះ ឬក៏សមាជិកគ្រួសារនោះនូវសេចក្តីស្លាប់ ឬបង្ករបួសស្នាម ។

៧. **សន្និដ្ឋាន :**

កាន់តែមានសន្តិសុខ យើងកាន់តែមានអារម្មណ៍ថា យើងបានកាត់បន្ថយការធ្វើឱ្យអ្នកដទៃឈឺចាប់ ឬការយាយីគ្នា ។ ប្រសិនបើយើងមានសន្តិសុខរាងកាយ យើងគ្មានអារម្មណ៍ថា យើងបង្កអំពើហិង្សាទេ ។ បើយើងមានសន្តិសុខផ្លូវចិត្ត និងសេដ្ឋកិច្ច នោះយើងនឹងមិនបារម្ភ ឬតានតឹងចិត្តឡើយ ។ ប្រសិនបើយើងមានសន្តិសុខបរិស្ថានជីវិតរបស់យើង និងជីវិតកូនរបស់យើង ក៏មានសន្តិសុខដែរ ។ តាមវិធីនេះ យើងរស់នៅបានស្រួលដោយមិនចាំបាច់បង្កទំនាស់ដាក់គ្នាឡើយ ។

# សិទ្ធិ និង តម្រូវការ

នៅពេលដែលសិទ្ធិមនុស្សមិនត្រូវបានគោរព ហើយតម្រូវការជាមូលដ្ឋានមិនត្រូវបានទទួលស្គាល់ នោះបណ្តាលឱ្យមនុស្សយើងស្រងាកចិត្ត ហើយថែមទាំងមានកំហឹងក្រេវក្រោធទៀតផង ។ ការខកចិត្តអាចបណ្តាលឱ្យមានអំពើហិង្សា ជាពិសេសគឺសំដៅដល់មនុស្សទាំងឡាយដែលមានឯកសិទ្ធិខ្ពង់ខ្ពស់ជាង ។ ប្រសិនបើម្នាក់ៗនៅក្នុងសង្គម បានទទួលនូវសេចក្តីត្រូវការជាមូលដ្ឋានគ្រប់គ្រាន់ សិទ្ធិត្រូវបានគេគោរព មានន័យថាបានកាត់បន្ថយភាពទំនាស់ ។ មេរៀននេះ គឺមានគោលបំណងនាំឱ្យសិស្សគិតអំពីតម្រូវការជាមូលដ្ឋានផ្សេងៗរបស់មនុស្ស និងគិតអំពីវិធីដែលធ្វើឱ្យសម្រេចជោគជ័យលើការគោរពសិទ្ធិជាមូលដ្ឋានសម្រាប់មនុស្សទាំងអស់គ្នា ។

**វត្ថុបំណង** :

ចៈ សិស្សអាចយល់បានពីតម្រូវការផ្សេងគ្នា និងសិទ្ធិដែលមនុស្សគ្រប់រូបមាន

បៈ សិស្សអាចពិភាក្សាយ៉ាងឈ្លាសវៃអំពីតម្រូវការ និងសិទ្ធិជាមូលដ្ឋានផ្សេងៗ និងពិចារណាថា តើត្រូវធ្វើដូចម្តេចដើម្បីឱ្យតម្រូវការទាំងនេះបានឆ្លើយតបនៅក្នុងសហគមន៍របស់ពួកគេ

ឥៈ សិស្សយល់ថា សមភាពក្នុងការទទួលតម្រូវការមូលដ្ឋាន និងសិទ្ធិស្មើគ្នា គឺជាការកាត់បន្ថយទំនាស់

**រយៈពេល** : ៣០ នាទី

**សម្ភារ** : សេចក្តីថ្លែងការណ៍ជាសកល ស្តីពីសិទ្ធិមនុស្ស មាត្រាទី១ មាត្រាទី២ មាត្រាទី៣

**ដំណើរការនាំមេរៀនៈ**

១. គ្រូបំផុសគំនិតសិស្សរកតម្រូវការផ្សេងៗដើម្បីការរស់នៅ សរសេរបញ្ជីអំពីតម្រូវការទាំងនោះលើក្តារខៀន ។

២. សរសេរចប់គ្រូសួរទៅសិស្សថា តើគេអាចចែកជាក្រុមនូវតម្រូវការនោះជាផ្នែកៗបានដែរឬទេ ដូចជាៈ តម្រូវការរាងកាយ តម្រូវការសង្គម តម្រូវការស្មារតី

៣. បន្ទាប់មកចែកសិស្សជា៣ក្រុម មួយក្រុមសម្រាប់តម្រូវការមួយប្រភេទៈ តម្រូវការរាងកាយ សង្គម និងស្មារតី ។ ក្រុមនីមួយៗត្រូវឆ្លើយសំណួរដូចខាងក្រោមតាមរយៈការពិភាក្សាក្នុងក្រុម

ក. ធ្វើបញ្ជីតម្រូវការទាំងអស់ដែលអ្នកនឹកដល់នៅពីក្រោមចំណងជើងប្រភេទតម្រូវការនីមួយៗ ។

៤. គ្រូឱ្យសិស្សតាមក្រុមនីមួយៗ បង្ហាញពីលទ្ធផលនៃការពិភាក្សាទៅសិស្សក្នុងថ្នាក់ ( **ចម្លើយចូលរួមៈ**

តម្រូវការរាងកាយ ដូចជា អាហារ ទឹក ការដេក ទីជំរក

តម្រូវការសង្គម ដូចជាៈ មិត្តភក្តិ គ្រួសារ ការសម្រាក

តម្រូវការស្មារតីដូចជា សមាធិ ការអប់រំ សម្មស្ស ក្តីស្រលាញ់ )

៥. គ្រូសួរសិស្ស៖

**ក.** តើតម្រូវការទាំងអស់ខាងលើ ពិតជាបានឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍យើងដែរឬទេ? បើបានហេតុអ្វី? បើមិនបានហេតុអ្វី?

**ខ.** តើអ្នកគិតថា គ្រប់គ្នានៅក្នុងសហគមន៍យើងសមនឹងទទួលបានតម្រូវការទាំងនេះឬទេ? បើសមតើហេតុអ្វី? បើមិនសមតើហេតុអ្វី ?

៦. គ្រូអានឱ្យសិស្សសរសេរសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ដាក់ក្នុងសៀវភៅ៖

## សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស

### មាត្រា ១

មនុស្សទាំងអស់កើតមកមានសេរីភាព និងភាពស្មើៗគ្នាក្នុងសិទ្ធិ និងសេចក្តីថ្លៃថ្នូរ ។ មនុស្សគ្រប់រូបសុទ្ធតែមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈ ហើយត្រូវប្រព្រឹត្តិចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីរាប់អានគ្នាជាបងប្អូន ។

### មាត្រា ២

មនុស្សគ្រប់រូបមានសិទ្ធិ និងសេរីភាពគ្រប់បែបយ៉ាងទាំងអស់ ដែលមានចែងក្នុងប្រកាសនេះ ដោយគ្មានបែងចែក ជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ប្រភពជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬឋានៈដទៃៗទៀតឡើយ ។

បន្ថែមលើនេះទៀត មិនត្រូវធ្វើការបែងចែកណាមួយដោយសំអាងទៅលើឋានៈខាងនយោបាយ ខាងដែនសមត្ថកិច្ច ឬឋានៈជាអន្តរជាតិនៃប្រទេស ឬដែនដីដែលបុគ្គលមួយរូបជាសមាជិកឡើយ ទោះប្រទេសនោះជាប្រទេសឯករាជ្យ ឬស្ថិតនៅក្រោមអាណាព្យាបាលគ្រប់គ្រង ឬមិនគ្រប់គ្រងដោយខ្លួនឯង ឬស្ថិតក្រោមការដាក់កម្រិតដទៃៗណាមួយនៃអធិបតេយ្យភាពយ៉ាងណាក៏ដោយ ។

### មាត្រា ៣

បុគ្គលម្នាក់ៗត្រូវមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

៧. គ្រូសួរសិស្ស៖

**ក.** តើអ្នកគិតយ៉ាងដូចម្តេចអំពីមាត្រានេះ?

**ខ.** តើអ្នកគិតថាមាត្រានេះត្រូវបានគេគោរពនៅប្រទេសកម្ពុជាដែរឬទេ?

**គ.** តើមានអ្វីកើតឡើងនៅពេលសិទ្ធិស្មើគ្នារបស់មនុស្សមិនត្រូវបានគេគោរព ឬតម្រូវការជាមូលដ្ឋានមិនត្រូវបានគេផ្តល់ឱ្យ? តើអ្នកអាចឱ្យឧទាហរណ៍មួយ ពីក្នុងសហគមន៍របស់យើងបានដែរឬទេ? ( **ចម្លើយចូលរួម៖** មនុស្សលួច ពីព្រោះគេអត់ឃ្លាន)

ឃ. តើអ្នកគិតថា ការប្រព្រឹត្តិតប្បីចំពោះគ្នាទៅវិញទៅមកដោយយុត្តិធម៌ ស្មើភាព និងរាក់ទាក់ នោះយើងអាចជៀសវាងទំនាស់បានដែរឬទេ? ហេតុអ្វី?

៨. **សន្និដ្ឋាន:**

យើងទាំងអស់គ្នាមានតម្រូវការជាមូលដ្ឋាននិងសិទ្ធិដូចៗគ្នា មិនថាយើងមកពីទីណា ឬយើងជានរណាទេ។ នៅពេលតម្រូវការរបស់យើងមិនត្រូវបានឆ្លើយតប ហើយសិទ្ធិរបស់យើងមិនត្រូវបានគេគោរព យើងមានអារម្មណ៍ស្រងាកចិត្ត និងខឹងសម្បារ។ នេះអាចជំរុញឱ្យមនុស្សទាមទារសិទ្ធិដោយប្រើហិង្សា។ សហគមន៍របស់យើងអាច មានសុវត្ថិភាព និងសន្តិភាពបាន បើយើងព្យាយាមប្រព្រឹត្តិឱ្យបានសមស្រប និងមានការគោរពគ្នា មិនប្រកាន់សញ្ជាតិ ពូជសាសន៍ អាយុ ភេទ ស្ថានភាពសេដ្ឋកិច្ច ឬគំនិតនយោបាយ។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១០ មេរៀនៈ សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ នៃកម្មវិធីរបស់ក្រសួងអប់រំយុវជន និងកីឡា*

# អាវុធ និង ច្បាប់របស់កម្ពុជា

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ គណៈរដ្ឋមន្ត្រីបានយល់ព្រមលើអនុក្រឹត្យលេខ៣៨ ចែងពីការគ្រប់គ្រង និងត្រួតពិនិត្យការនាំចូល ការផលិត ការលក់ ការចែកចាយ និងការប្រើប្រាស់អាវុធគ្រប់ប្រភេទ។ ដោយយោងតាមការសិក្សាស្រាវជ្រាវខ្លះ យើងឃើញថា សិស្សានុសិស្សនៅតែមានលទ្ធភាពរកទិញអាវុធកាន់កាប់ និងប្រើប្រាស់អាវុធបាន។ មេរៀននេះមានសារៈសំខាន់សម្រាប់សិស្សយល់ដឹងពីការអនុវត្តន៍ច្បាប់ទាក់ទិននឹងទង្វើទាំងនេះ។

**វត្ថុបំណង :**

ក: សិស្សចេះច្បាប់ដែលទាក់ទងនឹងការកាន់កាប់អាវុធ

ខ: សិស្សដឹងអំពីអ្វីដែលពួកគេគួរធ្វើនៅពេលគេរកឃើញ ឬដឹងអំពីអាវុធខុសច្បាប់

គ: សិស្សចាត់ទុកថា ការរក្សាអាវុធជាតិផ្ទុះទុកជាកម្មសិទ្ធិជាអំពើខុសច្បាប់

**រយៈពេល :** ៣០ នាទី

**សម្ភារ :** ឯកសារចម្លងអនុក្រឹត្យលេខ ៣៨

អនុក្រឹត្យលេខ៣៨ ចែងថា ហាមដាច់ខាតរាល់ការលក់ ការទិញ ការដូរ ការធ្វើអំណោយ ការស្តុកទុកក្នុងផ្ទះ ឬទីកន្លែងផ្សេងទៀតនូវរាល់អាវុធជាតិផ្ទុះនៅលើទឹកដីប្រទេសកម្ពុជា។ នេះរួមបញ្ចូលទាំងកាំភ្លើងដៃ និងកាំភ្លើងខ្លី គ្រាប់រ៉ុក្កែត អាវុធគីមី និងជីវសាស្ត្រ ដំបងឆក់ គ្រាប់បែក គ្រាប់មីន និងគ្រាប់កាំភ្លើងគ្រប់ប្រភេទ។

អ្នកដែលត្រូវបានអនុញ្ញាតិឱ្យកាន់កាប់អាវុធមានជាអាទិភាពរួមមាន: សមាជិកព្រឹទ្ធសភា សមាជិកសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ប្រធានតុលាការ និងព្រះរាជអាជ្ញា អគ្គលេខាធិការនៃក្រសួង និងស្ថាប័នរដ្ឋាភិបាល អភិបាល អភិបាលរងថ្នាក់ខេត្តក្រុង និងអភិបាលស្រុក។

សមាជិកកងយុទ្ធពលខេមរៈភូមិន្ទកម្ពុជា កងរាជអាវុធហត្ថ និងប៉ូលីសជាតិ មានឋានៈចាប់ពីស័ក្តិប្រាំឡើងទៅត្រូវបានអនុញ្ញាតឱ្យប្រើកាំភ្លើងខ្លី។

ការពិន័យចំពោះការរំលោភអនុក្រឹត្យនេះ គឺការជាប់ពន្ធនាគារ។

**ដំណើរការនាំមេរៀន :**

១. គ្រូពន្យល់សិស្សថា: នៅក្នុងសេចក្តីថ្លែងការណ៍ជាសកលនៃសិទ្ធិមនុស្សបានចែងថា មនុស្សម្នាក់ៗមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខបុគ្គល។

២. គ្រូសួរសិស្សនូវសំណួរដូចខាងក្រោម៖

ក. តើឃ្លាថា៖ សិទ្ធិរស់រានមានជីវិត សេរីភាព សន្តិសុខបុគ្គល មានន័យយ៉ាងដូចម្តេច?

ខ. តើអ្វីខ្លះជាឧបសគ្គក្នុងសហគមន៍របស់អ្នកសម្រាប់ "**ការរស់នៅ សេរីភាព និងមានសន្តិសុខបុគ្គល**"?

៣. គ្រូពន្យល់សិស្ស៖

អាវុធគឺជាការគំរាមកំហែងចម្បងក្នុងចំណោមការគំរាមកំហែងដទៃទៀត ដល់សន្តិភាពក្នុងប្រទេសកម្ពុជា។

គ្រូសួរសិស្ស

ក. តើអ្នកធ្លាប់ឃើញអាវុធប្រភេទណាខ្លះ នៅក្នុងសហគមន៍របស់អ្នក?

ខ. ចូរចែករំលែកបទពិសោធន៍ដែលទាក់ទិននឹងអាវុធជាតិផ្ទុះ ដែលបង្កទុក្ខទោសដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់អ្នក។

៤. គ្រូពន្យល់សិស្សថា នៅកម្ពុជា រាជរដ្ឋាភិបាលបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ដោយអនុម័តនូវអនុក្រឹត្យលេខ៣៨។ ដោយសារអាវុធធ្វើឱ្យប្រជាជនមានទុក្ខទោស របួសស្នាម បង្កអសន្តិសុខ និងគ្រោះថ្នាក់នៅក្នុងសហគមន៍ អនុក្រឹត្យលេខ៣៨ បានចាត់ទុកអាវុធជាតិផ្ទុះ ថាជាអាវុធខុសច្បាប់។

៥. គ្រូអានអនុក្រឹត្យលេខ៣៨ខ្លាំងៗឱ្យសិស្សកត់ចូលក្នុងសៀវភៅ។ ពេលចប់ គ្រូឱ្យសិស្សអានឡើងវិញ។

៦. សំណួរពិភាក្សា ៖

ដោយសារនេះជាច្បាប់របស់កម្ពុជា តើយើងគួរធ្វើយ៉ាងដូចម្តេចនៅពេលយើងដឹងថា មានការប្រើប្រាស់អាវុធខុសច្បាប់ក្នុងសហគមន៍របស់យើង? ( **ចម្លើយចូលរួម៖** គ្រូគួរផ្តល់ដំបូន្មានឱ្យសិស្សស្វែងរកនរណាម្នាក់ដែលទុកចិត្ត ដើម្បីផ្តល់ព័ត៌មានទាក់ទងនិងការប្រគល់អាវុធ អ្នកទាំងនោះអាចជា មេឃុំ អាចារ្យ ឬតំណាងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីឱ្យពួកគេជួយផ្តល់ដំណឹងនេះទៅអាជ្ញាធរក្នុងការប្រគល់អាវុធ ហើយផ្តល់ការលើកទឹកចិត្តដល់សមាជិកគ្រួសារឱ្យធ្វើដូចគ្នាដែរ។)

៧. **សន្និដ្ឋាន៖**

រក្សាអាវុធ គឺជាការខុសច្បាប់ និងមានគ្រោះថ្នាក់។ វាអាចបង្កគ្រោះថ្នាក់មិនថាសម្រាប់ជនរងគ្រោះប៉ុណ្ណោះទេ តែថែមទាំងដល់អ្នកប្រើប្រាស់វាទៀតផង។ ប្រសិនបើអ្នកមានអាវុធ ឬដឹងថានរណាម្នាក់មានអាវុធ អ្នកគួរជួយណែនាំឱ្យពួកគេប្រគល់អាវុធឱ្យទៅអ្នកទទួលខុសត្រូវណាម្នាក់ដែលអ្នកទុកចិត្ត ហើយប្រគល់បន្តជូនដល់អាជ្ញាធរមូលដ្ឋានដើម្បីធ្វើការបំផ្លាញចោល ឬរក្សាទុកក្នុងឃ្លាំង។ នេះមិនគ្រាន់តែជាច្បាប់ទេ ប៉ុន្តែជាឥរិយាបថប្រកបដោយការទទួលខុសត្រូវ ដើម្បីឱ្យមានសន្តិសុខក្នុងសហគមន៍របស់យើង។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១០ មេរៀនការជួយជីវិតអ្នកដទៃ នៃកម្មវិធីរបស់ក្រសួងអប់រំយុវជន និងកីឡា*

ជំពូក

៣

# ការសម្រេចចិត្ត

# តើយើងធ្វើការសម្រេចចិត្តយ៉ាងដូចម្ដេច?

យើងធ្វើការសម្រេចចិត្តរៀងរាល់ថ្ងៃ ។ ការសម្រេចចិត្តនោះជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់យើង ។ ការសម្រេចចិត្តខ្លះអាចបណ្ដាលឱ្យមានទំនាស់ ។ ដូចគ្នាដែរវិធីដែលយើងសម្រេចចិត្ត ក៏អាចនាំឱ្យមានទំនាស់ផងដែរ ។ ប្រភេទនៃការសម្រេចចិត្តខ្លះអាចធ្វើឱ្យមនុស្សមានអារម្មណ៍ថា ខ្លួនត្រូវបានគេទាត់ចោល ឬត្រូវបដណ្ដប់ពីលើ ។ ការសម្រេចចិត្តខ្លះទៀតហាក់ដូចជាមិនសមហេតុផល ឬមិនត្រឹមត្រូវដែរ ។ មេរៀននេះផ្ដោតអារម្មណ៍លើវិធីសាស្ត្រផ្សេងៗនៃការសម្រេចចិត្ត និងរបៀបផ្សេងៗដែលការសម្រេចចិត្តអាចប្រសើរបំផុតសម្រាប់ប្រើនៅក្នុងស្ថានភាពផ្សេងៗ ។ ជាពិសេសវាបញ្ជាក់ពីការសម្រេចចិត្តដែលអាចធ្វើបាន ដែលត្រូវបានធ្វើជាក្រុម សហគមន៍ ឬសង្គមទាំងមូល ។

**វត្ថុបំណង :**

ក: សិស្សយល់អំពីវិធីសាស្ត្រប្លែកៗ សម្រាប់ធ្វើការសម្រេចចិត្តនៅក្នុងក្រុម

ខ: សិស្សចេះវិធីសាស្ត្រផ្សេងៗ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ វិធីសាស្ត្រសម្រេចចិត្តដែលអាចជៀសវាងទំនាស់បាន ឬក៏វិធីសាស្ត្រដែលអាចជួយដោះស្រាយទំនាស់នៅក្នុងក្រុមបាន

គ: សិស្សមានការប្រុងប្រយ័ត្នខ្លាំងជាងមុន ចំពោះរបៀបទាក់ទងជាមួយអ្នកដទៃក្នុងក្រុមនៅពេលធ្វើការសម្រេចចិត្ត

**រយៈពេល :** ៤០ នាទី

**សម្ភារ :** បន្ទះសន្លឹកក្រដាសអំពីប្រភេទនៃការសម្រេចចិត្ត

**វាក្យស័ព្ទ :**

**ការសម្រេចចិត្តដោយការបោះឆ្នោត:** ជម្រើស ឬដំណោះស្រាយជាច្រើនត្រូវបានស្នើឡើង ។ សមាជិកទាំងអស់ត្រូវនិយាយថា ជម្រើសណាមួយដែលគេចូលចិត្ត ។ ជម្រើសដែលគាំទ្រដោយមតិភាគច្រើនក្នុងក្រុម គឺជាការសម្រេចចិត្ត ។

**ការសម្រេចចិត្តកុងសង់ស៊ុស:** មនុស្សម្នាក់ៗនៅក្នុងក្រុម សម្រេចចិត្តយកជម្រើសមួយ ។ ក្រុមមិនធ្វើការបោះឆ្នោតទេ ។ សមាជិកម្នាក់ៗមិនត្រូវបានបង្ខំឱ្យប្ដូរចិត្តទេ ប៉ុន្តែត្រូវជជែករកហេតុផលការពារគំនិតរបស់ខ្លួន និងត្រូវស្ដាប់គ្នាទៅវិញទៅមក ។ លុះត្រាតែក្រុមទាំងមូលឯកភាពគ្នា ទើបជាការសម្រេចចិត្តបែបកុងសង់ស៊ុស ។

**ការសម្រេចដោយផ្សងសំណាង:** ការសម្រេចចិត្តធ្វើឡើងដោយផ្សងសំណាង ដូចជាការបោះកាក់ ឬក៏ការចាប់សន្លឹកបៀរ ស្ដោះទឹកមាត់ដាក់បាតដៃ ហើយយកម្រាមដៃទះ ។

**ការសម្រេចចិត្តតាមអ្នកដឹកនាំ:** សមាជិកក្រុមជ្រើសរើសអ្នកដឹកនាំម្នាក់ ។ អ្នកដឹកនាំត្រូវស្ដាប់ឮអំពីអ្វីដែលសមាជិកម្នាក់ៗនិយាយ ។ បន្ទាប់មកអ្នកដឹកនាំត្រូវសម្រេចថា ក្រុមទាំងមូលត្រូវធ្វើអ្វី ។

**ការសម្រេចចិត្តដោយការព្រមព្រៀង:** សមាជិកក្នុងក្រុម សុខចិត្តលះបង់ផ្នែកខ្លះដែលគេចង់បានបន្តិចបន្តួច ប៉ុន្តែមកព្យាយាមរកដំណោះស្រាយមួយដែលសមាជិកក្រុមម្នាក់ៗអាចទទួលយកបាន

**ការសម្រេចចិត្តតាមរយៈអាជ្ញាកណ្តាលៈ** ក្រុមជ្រើសរើសអ្នកខាងក្រៅណាម្នាក់ ឱ្យធ្វើការសម្រេចចិត្តជំនួសពួកគេ។ អ្នកខាងក្រៅនោះហៅថា អាជ្ញាកណ្តាល។ ក្រុមទាំងមូលយល់ព្រមធ្វើអ្វីមួយដែលអាជ្ញាកណ្តាលនោះសម្រេច។

**ការសម្រេចចិត្តតាមរយៈអ្នកជំនាញៈ** នរណាម្នាក់នៅក្នុងក្រុមដែលមានបទពិសោធន៍ ឬចេះដឹងច្រើនជាងគេបំផុតអំពីបញ្ហាអ្វីមួយ ជាអ្នកធ្វើការសម្រេចចិត្ត។

**ដំណើរការនាំមេរៀន**

១. គ្រូសរសេរអំពីប្រភេទនៃការសម្រេចចិត្តទាំងប្រាំពីរនោះនៅផ្ទាលើក្តារខៀន ហើយពន្យល់ប្រភេទនីមួយៗដល់សិស្ស (**ចំណាំៈ** មិនចាំបាច់សរសេរនិយមន័យទាំងស្រុងទេ)។

២. គ្រូឱ្យសិស្សរកឧទាហរណ៍នៃរបៀបសម្រេចចិត្តនីមួយៗ យកចេញពីសហគមន៍ ឬសង្គមដែលគេរស់នៅ។

**ចម្លើយចូលរួមៈ** ការសម្រេចចិត្តតាមៈ

- **ការបោះឆ្នោតៈ** ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ឬជ្រើសរើសមេឃុំ/សង្កាត់
- **កុងសង់ស៊ុសៈ** ប្តីប្រពន្ធចង់ទិញផ្ទះមួយ
- **ការផ្សងសំណាងៈ** មិត្តភក្តិព្យាយាមសម្រេចចិត្តធ្វើអ្វីមួយនៅចុងសប្តាហ៍
- **មេដឹកនាំៈ** នាយកសាលាធ្វើការសម្រេចចិត្តអំពីវិធីចំណាយថវិកា
- **ការព្រមព្រៀងៈ** រវាងបងប្អូនប្រុសស្រីដែលឈ្លោះដណ្តើមផ្លែឈើគ្នា
- **អាជ្ញាកណ្តាលៈ** មេភូមិដោះស្រាយបញ្ហាជម្លោះដីធ្លី
- **ជំនាញៈ** វេជ្ជបណ្ឌិតអាចសម្រេចចិត្តប្រើថ្នាំណាមួយដែលល្អបំផុតសម្រាប់ព្យាបាលជម្ងឺ

៣. ឱ្យសិស្សបង្កើតក្រុមតូចៗឱ្យបានចំនួន៧។ ចែកឱ្យក្រុមនីមួយៗនូវរបៀបធ្វើការសម្រេចចិត្តមួយ ហើយស្នើឱ្យពួកគេសរសេរនូវរាល់អត្ថប្រយោជន៍ និងផលវិបាកនៃប្រភេទការសម្រេចចិត្តនោះ ជាពិសេសសង្កត់ធ្ងន់លើរបៀបសម្រេចចិត្តដែលអាចបណ្តាលឱ្យមានទំនាស់ ឬបង្ការទំនាស់។ (គ្រូផ្តល់ពេលឱ្យសិស្ស ១០នាទីដើម្បីពិភាក្សា)។

៤. គ្រូឱ្យក្រុមនីមួយៗឡើងរាយការណ៍លទ្ធផល

៥. គ្រូសួរទៅសិស្សម្នាក់ៗ ថាតើរបៀបសម្រេចចិត្តមួយណាដែលអ្នកចូលចិត្តជាងគេ? ហេតុអ្វី?

៦. **សន្និដ្ឋានៈ**

ការសម្រេចចិត្តត្រូវបានគេធ្វើឡើងតាមពេលវេលាខុសគ្នា និងតាមរបៀបផ្សេងៗគ្នា។ អាស្រ័យលើស្ថានភាព និងប្រភេទនៃការសម្រេចចិត្តនោះ យុទ្ធវិធីខ្លះមានជោគជ័យជាងយុទ្ធវិធីឯទៀត។ ប្រភេទនៃការសម្រេចចិត្តខ្លះអាចជួយកាត់បន្ថយទំនាស់ ប្រភេទសម្រេចចិត្តខ្លះទៀត អាចធ្វើឱ្យមនុស្សមានអារម្មណ៍ខឹងសម្បារ និងត្រូវបានគេ ទាត់ចោល។ ការខឹងសម្បារ និងការផាត់ចេញ អាចនាំឆ្ពោះទៅរកទំនាស់ ឬការមិនសហការបាន។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១១. មេរៀន ការចេះគិតគូរសមហេតុសមផល នៃកម្មវិធីរបស់ក្រសួង អប់រំយុវជន និងកីឡា*

# ការសម្រេចចិត្តរួមគ្នា

នៅពេលយើងធ្វើការសម្រេចចិត្តក្នុងក្រុម មានវិធីសាស្ត្រសម្រេចចិត្តច្រើនយ៉ាងណាស់ដែលយើងអាចយកមកប្រើបាន ដូចជាៈ ការសម្រេចចិត្តតាមរបៀបកុងសង់ស៊ុស តាមការបោះឆ្នោត តាមជំនាញ និងតាមភាពជាអ្នកដឹកនាំ។ មុនការសម្រេចចិត្តត្រូវបានគេធ្វើឡើង វាមានសារៈសំខាន់ណាស់ដើម្បីយល់ស្របតាមការសម្រេចចិត្តណាមួយ ដែលត្រូវបានអនុវត្តដោយអ្នកពាក់ព័ន្ធក្នុងដំណើរការធ្វើការសម្រេចចិត្តនោះអាចទទួលយកបាន។

**វត្ថុបំណង :**

ចៈ សិស្សនឹងត្រូវបានណែនាំ និងពិចារណាកាន់តែស៊ីជំរៅអំពីដំណើរការនៃការសម្រេចចិត្តនៅក្នុងក្រុម

បៈ សិស្សកំណត់បាននូវឧបសគ្គដែលធ្វើឱ្យការសម្រេចចិត្តអាចបញ្ចប់បាន

ឥៈ សិស្សយល់ថា ការពិគ្រោះយោបល់ និងការចូលរួមពាក់ព័ន្ធរបស់អ្នកដទៃក្នុងដំណើរការធ្វើការសម្រេចចិត្តនោះបង្កើនការតាំងចិត្តរបស់ក្រុមដើម្បីធ្វើការសម្រេចចិត្ត

**រយៈពេល :** ៣០នាទី

**សម្ភារ :** ក្រដាស, ខ្មៅដៃ

**ដំណើរការនាំមេរៀន**

១. ឱ្យសិស្សគិតពីស្ថានភាពដូចតទៅនេះ ក្រុមទាំងមូលត្រូវបានគេបញ្ជូនទៅកោះមួយកណ្តាលមហាសមុទ្រ តែពួកគេត្រូវបានអនុញ្ញាតឱ្យយកតាមខ្លួននូវ របស់១០មុខបន្ថែមពីលើសំលៀកបំពាក់ផ្ទាល់ខ្លួន។

២. ផ្តល់ពេលឱ្យសិស្សម្នាក់ៗ ៥នាទី ដើម្បីធ្វើបញ្ជីរាយនាមវត្ថុ១០មុខ ដែលគេគិតថាសំខាន់សម្រាប់យកទៅប្រើនៅលើកោះ។

៣. គ្រូបំបែកសិស្សជា៥ក្រុមតូចៗ។ ក្រុមនីមួយៗត្រូវធ្វើបញ្ជីរាយនាមវត្ថុថ្មីមួយទៀតមានវត្ថុ១០មុខ ដែលជ្រើសរើសពីបញ្ជីរាយនាមរបស់ខ្លួនគេម្នាក់ៗ។ ពួកគេមានពេល ១០នាទី ដើម្បីបញ្ចប់ការងារនេះ។

៤. គ្រូឱ្យសិស្សសរសេរបញ្ជីរាយនាមវត្ថុរួមគ្នារបស់ក្រុមគេលើក្តារខៀន។ ទាំងអស់គួរមានបញ្ជីចំនួន៥ ដកចេញនូវវត្ថុដែលដូចគ្នា ដូច្នេះវត្ថុមួយសរសេរបានតែម្តងទេលើក្តារខៀន។ ឥឡូវនេះសួរទៅសិស្សក្នុងថ្នាក់ឱ្យជ្រើសរើសវត្ថុចំនួន១០មុខ ផ្តាច់ព្រ័ត្រសម្រាប់បញ្ជីរាយនាមវត្ថុរបស់គេ។ គ្រូមិនត្រូវរំខានការសម្រេចចិត្តរបស់សិស្សទេ។

៥. គ្រូសួរសិស្សៈ

**ក.** តើអ្នកជ្រើសរើសឈ្មោះវត្ថុទាំងនោះយ៉ាងដូចម្ដេចក្នុងក្រុមតូចដំបូង?

**ខ.** តើមួយណាស្រួលសម្រេចចិត្តជាងក្នុងក្រុមតូចដំបូង ឬថ្នាក់ទាំងមូល? តើហេតុអ្វី?

**គ.** តើអ្វីជាឧបសគ្គចំពោះការធ្វើការសម្រេចចិត្ត? តើអ្នកជំនះវាបានយ៉ាងដូចម្ដេច?

**ឃ.** ក្នុងកំឡុងពេលពិភាក្សានៅក្នុងក្រុមតូច តើសិស្សបានដើរតួនៅក្នុងតួនាទីផ្សេងៗគ្នាដែរឬទេ? តើតួនាទីអ្វីដែលពួកគេបានធ្វើនោះ? (**ឧទាហរណ៍:** សិស្សខ្លះដើរតួនាទីជាអ្នកសម្របសម្រួល ឬអ្នកដឹកនាំ ឬអ្នកចាំតែយល់ស្របតាមគេ ឬជាអ្នកកត់ត្រា)

៦. **សន្និដ្ឋានៈ**

ជានិច្ចកាលយើងមិនអាចទទួលបានអ្វីដែលយើងចង់បានទេ ជាពិសេសពេលមានអ្នកដទៃមកពាក់ព័ន្ធ។ នៅពេលយើងមិនអាចទទួលយកអ្វីដែលយើងចង់បាន យើងមានអារម្មណ៍ខឹងសម្បារ និងមួរម៉ៅ។ មានឧបសគ្គមួយចំនួននៅពេលយើងធ្វើការសម្រេចចិត្តជាក្រុម ទោះបីជាយ៉ាងណាក៏ដោយ បើយើងពិគ្រោះយោបល់ និងពិចារណាពីគំនិតរបស់គេច្រើនកាលណា នោះយើងកាន់តែមានភាពងាយស្រួលក្នុងការរកដំណោះស្រាយដែលធ្វើឱ្យអ្នករាល់គ្នាសប្បាយចិត្ត។ ជួនកាលយើងត្រូវតែសម្រេចតាមវិធីសាស្ត្រធ្វើការសម្របសម្រួល ជួនកាលត្រូវធ្វើតាមការសម្រេចចិត្តដោយរបៀបធ្វើការសម្រេចតាមមតិភាគច្រើន ប៉ុន្តែបើយើងមានអារម្មណ៍ថា មតិយើងត្រូវបានគេស្ដាប់ នោះយើងប្រាកដជាទទួលយកការសម្រេចចិត្តរបស់ក្រុមជាពុំខាន។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី...១០មេរៀន វិធីធ្វើការសម្រេចចិត្តនៃកម្មវិធីរបស់ក្រសួងអប់រំយុវជន និងកីឡា*

# ការធ្វើការសម្រេចចិត្តដោយកុងសង់ស៊ុស

ការសម្រេចចិត្តក្នុងក្រុមមិនមែនងាយស្រួលជានិច្ចនោះទេ ។ នៅពេលដែលមនុស្សម្នាក់ៗដឹងថា យោបល់របស់គេមិនត្រូវបានគេពិចារណា ឬត្រូវបានគេបដិសេធនឹងលទ្ធផលនោះ វាអាចបណ្ដាលឱ្យមានបញ្ហានៅក្នុងក្រុមទាំងមូល ។ អ្នកទាំងនោះមានអារម្មណ៍ថា មិនមានសារៈសំខាន់ និងមានការខកចិត្ត ។ ការធ្វើកុងសង់ស៊ុសលើការសម្រេចចិត្ត ទាមទារឱ្យមានការចូលរួមកំរិតខ្ពស់របស់ក្រុមហើយធានាថា ការផ្ដល់មតិយោបល់ របស់សមាជិកក្រុមម្នាក់ៗ ត្រូវបានគេពិចារណាថាសំខាន់ និងផ្ដល់ឱកាសឱ្យគ្រប់គ្នាបញ្ចេញយោបល់ ។ ការសម្រេចចិត្តបែបកុងសង់ស៊ុស មិនអាចដល់ទីបញ្ចប់បាន កាលណាគ្រប់គ្នាក្នុងក្រុមមិនយល់ព្រម ។ នេះមិនមានន័យថា ជាការដាក់សម្ពាធលើការចាប់ផ្ដើមជំទាស់ទេ ប៉ុន្តែត្រូវព្យាយាមលើកហេតុផលមកពន្យល់គ្នារហូតដល់គ្រប់គ្នាយល់ព្រម ។ វាមិនមែនជាការងាយស្រួលទេ ហើយវាត្រូវចំណាយពេលវេលាច្រើន ប៉ុន្តែនៅទីបញ្ចប់វាអាចផ្ដល់នូវលទ្ធផលដែលគ្រប់ៗគ្នាសប្បាយចិត្ត និងមានឆន្ទៈក្នុងការសម្រេចចិត្តនេះ ។

**វត្ថុបំណង :**

ចៈ សិស្សត្រូវបានបង្ហាញអំពីទស្សនៈទាននៃការសម្រេចចិត្តបែបកុងសង់ស៊ុស

បៈ សិស្សប្រើប្រាស់ការសម្រេចចិត្តបែបកុងសង់ស៊ុសបានយ៉ាងត្រឹមត្រូវ

ឥៈ សិស្សវាយតម្លៃថាការសម្រេចចិត្តបែបកុងសង់ស៊ុស គឺជាវិធីសាស្ត្រមួយជួយបង្កើនការចូលរួម និងជៀសវាងទំនាស់

**ពេលវេលា :** ៣០ នាទី

**សម្ភារ :** ក្រដាស, ខ្មៅដៃ

**វាក្យស័ព្ទ :**

កុងសង់ស៊ុស : ការសម្រេចចិត្តនឹងមិនមានទេ ដរាបណាអ្នករាល់គ្នាក្នុងក្រុមមិនយល់ព្រម ។

ការកសាងកុងសង់ស៊ុស: ជាការអះអាងរាល់ការយកចិត្តទុកដាក់របស់មនុស្ស ត្រូវបានគេពិចារណានៅពេលធ្វើការសម្រេចចិត្ត ដែលសមាជិកម្នាក់ៗក្នុងក្រុមអាចទទួលយកបាន ។ នៅក្នុងការកសាងកុងសង់ស៊ុស ជាការសំខាន់ណាស់ដែលត្រូវអះអាងថា ម្នាក់ៗមានអារម្មណ៍សុខស្រួលដើម្បីបានបញ្ចេញពីអារម្មណ៍ពិតរបស់គេ ទោះបីថា គេជាមនុស្សខុសពីគេនៅក្នុងក្រុមទាំងមូលក៏ដោយ ។ ធ្វើបែបនេះអាចជួយធានាបាននូវគំនិតដែលអាចទទួលយកបាន និងដំណោះស្រាយត្រូវបានរកឃើញ ។ ការកសាងកុងសង់ស៊ុស សម្លេងភាគតិចត្រូវបានគេចាត់ទុកថាសំខាន់ ពីព្រោះគំនិតទាំងនោះអាចប្រកបដោយឧត្តមគតិ ចំណេះដឹង ឬការយល់ដឹងដែលជួនកាលមតិភាគច្រើនគ្មាន ។ ដូច្នេះការកសាងកុងសង់ស៊ុសឱ្យតម្លៃទៅ

លើសម្លេងភាគតិច ជាងមតិរបស់អ្នកភាគច្រើន។ សូមចងចាំថា ការសម្រេចចិត្តបែប កុងសង់ស៊ុស អាចមានប្រសិទ្ធភាពទៅបានលុះត្រាតែមានការឯកភាពពីគ្រប់ៗគ្នា។ ការសម្រេចចិត្តបែបកុងសង់ស៊ុស អាចចំណាយពេលច្រើន ប៉ុន្តែវាមានសារៈសំខាន់ សម្រាប់មនុស្សគ្រប់ៗគ្នាដែលគ្មានការបង្ខិតបង្ខំ ឬគំរាមកំហែងឱ្យប្តូរចិត្តមកយល់ព្រម តាមមតិភាគច្រើនឡើយ។

**ចំណាំកនាំមេរៀន :**

១. ឱ្យសិស្សស្វែងរកដៃគូ ឱ្យសិស្សធ្វើការជាដៃគូដោយស្រមៃថា មានគេឱ្យប្រាក់ ២០០ដុល្លារ។ ពួកគេត្រូវពិភាក្សាគ្នាថាតើត្រូវចាយលុយរបៀបណា? ៣នាទីក្រោយមក ពួកគេត្រូវតែព្រមព្រៀងគ្នាលើរបៀបចំណាយប្រាក់នោះ។

២. បន្ទាប់មកពួកគេត្រូវចូលរួមក្រុមជាមួយក្រុមមួយផ្សេងទៀត ដើម្បីបង្កើតក្រុមថ្មី១មានគ្នា៤នាក់។ មួយក្រុមៗមានគ្នាពីរនាក់នោះត្រូវពន្យល់គ្នាពីការសម្រេចចិត្តត្រូវចាយលុយ២០០ដុល្លារនោះ។ អ្នកទាំង៤ ត្រូវឈានដល់ការព្រមព្រៀងអំពីរបៀបត្រូវចាយលុយ។ ( **ចំណាំ:** ចំនួនប្រាក់គឺ ២០០ដុល្លារដដែល មិនកើនតាមចំនួនមនុស្សទេ)

៣. ៥នាទីបន្ទាប់មកក្រុមនីមួយៗដែលមានគ្នា៤នាក់ត្រូវរួមជាមួយក្រុមមួយទៀត ដើម្បីបង្កើតក្រុមថ្មីមានគ្នា ៨នាក់។ ជាថ្មីម្តងទៀតគេត្រូវយល់ព្រមជាមួយគ្នាពីរបៀបត្រូវចាយប្រាក់២០០ដុល្លារនោះ។

៤. បន្ទាប់ពី៥នាទីមក, បញ្ឈប់ការធ្វើលំហាត់ រួចសួរទៅកាន់ក្រុមនីមួយៗក្នុងការសម្រេចចិត្ត។ បន្ទាប់មកសួរទៅថ្នាក់ទាំងមូល
   - ក. តើការសម្រេចចិត្តមួយណាមានភាពងាយស្រួលជាង? ជាមួយមនុស្ស ២នាក់ ឬ៨នាក់? ហេតុអ្វី?
   - ខ. តើអ្នកឈានដល់កិច្ចព្រមព្រៀងក្នុងក្រុមនីមួយៗដោយរបៀបណា?
   - គ. ហេតុអ្វីការសម្រេចចិត្តរបៀបនេះធ្វើឱ្យមានសារៈសំខាន់?
   - ឃ. តើយើងគួរប្រើវានៅពេលណា?

៥. ការណែនាំបង្ហាញពី "**កុងសង់ស៊ុស**" និង "**ការធ្វើកុងសង់ស៊ុស**" (មើលវាក្យស័ព្ទខាងលើ)

៦. គ្រូសួរសិស្ស :
   - ក. តើអ្វីខ្លះជាផលប្រយោជន៍ និងផលវិបាកនៃការធ្វើកុងសង់ស៊ុសសម្រាប់ជាវិធីសម្រេចចិត្ត?

     (**ចម្លើយចូលរួមគួររួមបញ្ចូល:**
     - **ផលប្រយោជន៍:** មានការចូលរួមផ្តល់យោបល់បានគ្រប់ៗគ្នា គ្រប់ៗគ្នាពេញចិត្តចំពោះលទ្ធផលនៃការសម្រេចចិត្តមានការចែកចាយគំនិតយោបល់យ៉ាងទូលាយ។
     - **គុណវិបត្តិ:** ប្រើពេលវែង បុគ្គលខ្លះអាចមានអារម្មណ៍ថាគាបសង្កត់ក្នុងការសម្របតាមក្រុម។)
   - ខ. តើអ្នកគិតថា គេគួរធ្វើការសម្រេចចិត្តរបៀបកុងសង់ស៊ុសសម្រាប់ស្ថានភាពអ្វី ឬក្រុមអ្វី?

## ៧. សង្ខេប:

ការប្រើកុងសង់ស៊ុស ជាវិធីសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តមួយ ដែលអាចកាត់បន្ថយជាអតិបរិមានូវលទ្ធភាពបង្កទំនាស់ ពីព្រោះវាពិចារណាលំអិតរាល់ទស្សនៈរបស់មនុស្សម្នាក់ៗ ។ ការសម្រេចចិត្តត្រូវបានធ្វើឡើងក្នុងករណីដែលសមាជិកម្នាក់ៗក្នុងក្រុមយល់ព្រមតែប៉ុណ្ណោះ ។ ជួនកាលការសម្រេចចិត្តបែបកុងសង់ស៊ុស គឺមិនអាចធ្វើបានជាពិសេសជាមួយក្រុមធំ ហើយបន្ទាប់មកយើងអាចព្យាយាមព្រមព្រៀងគ្នាធ្វើការសម្រេចចិត្តបែបបោះឆ្នោតវិញ ។



# ការផ្តល់អាទិភាព និង ការធ្វើការសម្រេចចិត្ត

យើងធ្វើការសម្រេចចិត្តរាល់ថ្ងៃថាអ្វីត្រូវញ៉ាំ? អ្វីត្រូវស្លៀកពាក់? ត្រូវចំណាយប្រាក់យ៉ាងដូចម្តេច? ថាត្រូវប្រើពេលវេលាយ៉ាងដូចម្តេច? ។ល។ យើងធ្វើការសម្រេចចិត្ត ពីព្រោះយើងមានជម្រើសច្រើន។ បើគ្មានជម្រើសទេនោះ យើងមិនចាំបាច់ធ្វើការសម្រេចចិត្តទេ។ នៅពេលយើងត្រូវបានគេបង្ហាញឱ្យឃើញនូវជំរើសប្លែកៗគ្នានោះ ជារឿយៗវាតែងធ្វើឱ្យយើងពិបាកសម្រេចចិត្តថា ជម្រើសមួយណាប្រសើរជាងគេ?។ នេះជាការពិតណាស់ ជាពិសេសក្នុងករណីដែលយើងសម្រេចចិត្តជាក្រុម។ មេរៀននេះផ្តោតអារម្មណ៍លើការផ្តល់អាទិភាពសម្រាប់ការជ្រើសរើស ដោយផ្អែកលើផលប្រយោជន៍ និងផលវិបាកនៃជម្រើសនីមួយៗ។

**វត្ថុបំណង :**

- ចះ សិស្សកាន់តែយល់ដឹងពីសេចក្តីត្រូវការ ដោយគិតតាមរយៈការធ្វើការសម្រេចចិត្តដោយប្រុងប្រយ័ត្ន
- បះ សិស្សមានសមត្ថភាពក្នុងការជ្រើសរើសចំណុច និងគំនិតអាទិភាព
- ឥះ សិស្សពិចារណាការផ្តល់អាទិភាពលើជម្រើស ឬការជ្រើសរើសក្នុងការសម្រេចចិត្តជាការសំខាន់

**រយៈពេល :** ៣០ នាទី

**សម្ភារ :** ក្រដាស, ខ្មៅដៃ

**វាក្យស័ព្ទ :**

**អាទិភាព :** ការរៀបចំគំនិតយោបល់ទាំងអស់ទៅតាមលំដាប់លំដោយ ដោយផ្អែកទៅលើកាលៈទេសៈជាក់ស្តែង។ (**ឧ.** យោងទៅលើថវិកា សារៈសំខាន់នៃគំរោង ភាពរីករាយ ។ល។)

## ដំណឹកនាំមេរៀន

១. បង្កើតជាក្រុមមានគ្នា ៥-៧ នាក់

២. ឱ្យក្រុមនីមួយៗគិតពីគំនិត៨យ៉ាង ដើម្បីធ្វើសាលារៀនរបស់ពួកគេមានការរីកចំរើន។ បន្ទាប់ពីគេរកបានគំនិតទាំង៨ហើយ ឱ្យពួកគេសរសេរគំនិតនោះតាមលំដាប់លំដោយចាប់ពីសំខាន់បំផុតរហូតដល់មិនសូវសំខាន់។



៣. បន្ទាប់មកឱ្យសិស្សសរសេរគំនិតទាំងនោះឡើងវិញ តាមលំដាប់លំដោយនៃតម្លៃចំណាយពីខ្ពស់ទៅដល់ទាបបំផុត




៤. នៅពេលបញ្ចប់ គ្រូសួរទៅសិស្សក្នុងថ្នាក់

ក. តើអ្នកបានសម្រេចចិត្តដាក់គំនិតទាំងនោះតាមលំដាប់លំដោយរបៀបណាក្នុងលំហាត់នេះ?

ខ. តើសមាជិកគ្រប់គ្នាក្នុងក្រុមអ្នកឯកភាពគ្នាដែរឬទេ?

គ. បើគេមិនយល់ព្រមទេ តើអ្នកឈានដល់ការបញ្ចប់នៃការសម្រេចចិត្តបានយ៉ាងដូចម្ដេច?

ឃ. តើការរៀបលំដាប់ថ្នាក់ គំនិតទាំងនោះជួយឱ្យយើងធ្វើការសម្រេចចិត្តបានយ៉ាងដូចម្ដេច?

ង. តើអ្នកអាចប្រើវិធីសាស្ត្រនោះ ក្នុងការធ្វើការសម្រេចចិត្តចំពោះជីវិតរបស់អ្នកបានដែរឬទេ?

**៥. លំហាត់បន្ថែមបើមានពេលគ្រប់គ្រាន់ :**

ឱ្យសិស្សជ្រើសរើសដៃគូ ប្រសិនបើអាចត្រូវបង្កើតដៃគូជាមួយភេទផ្ទុយគ្នា ។ ប្រាប់ទៅពួកគេថា ពួកគេគឺជាប្ដីប្រពន្ធ និងគ្នា ហើយពួកគេទាំងពីររួមគ្នាមានប្រាក់ចំណូល ៥០ដុល្លារក្នុងមួយខែ ។

ក. ធ្វើបញ្ជីនៃរបៀបត្រូវចំណាយសម្រាប់ខែនីមួយៗ

ខ. ធ្វើតារាងអាទិភាពនៃបញ្ជីដែលអាចទិញបាន

គ្រូឱ្យសិស្ស ៥គូ ចែកចាយចម្លើយរបស់ពួកគេឱ្យទៅក្នុងថ្នាក់ ។ គ្រូសួរទៅដៃគូនីមួយៗនូវសំណួរដូចខាងក្រោម

ក. តើវាស្រួលសម្រេចចិត្តទេ?

ខ. តើអ្នកមានចំណុចដែលមិនយល់ព្រមទេ?

គ. តើអ្នកដោះស្រាយចំណុចមិនយល់ព្រមដោយវិធីណា?

**៦. សន្និដ្ឋានៈ**

នៅពេលជីវិតរបស់យើងចេះតែវិវឌ្ឍន៍ទៅមុខ យើងប្រឈមមុខនឹងជម្រើសកាន់តែច្រើនទៅៗ ។ យើងត្រូវអភិវឌ្ឍជំនាញ និងយុទ្ធវិធីដើម្បីឱ្យយើងអាចធ្វើការសម្រេចចិត្តដែលនឹងនាំមកនូវផលប្រយោជន៍ដ៏ធំធេងបំផុតដោយមិនបណ្ដាលឱ្យមានការប៉ះពាល់ ។ នៅពេលយើងត្រូវធ្វើការសម្រេចចិត្តជាក្រុម ទំនាស់ជាញឹកញាប់អាចកើតបានដោយសារសមាជិកក្រុមមានតម្រូវការខុសៗគ្នា ។ ដោយពិភាក្សាពីផលប្រយោជន៍ និងផលប៉ះពាល់នៃភាពខុសគ្នាផ្នែកគំនិត យើងអាចផ្ដល់អាទិភាពចំពោះគំនិតណាដែលក្រុមយល់ថា មានសារៈសំខាន់បំផុតហើយគួរតែអនុវត្តគំនិតនោះ ។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១២ មេរៀនវាយតម្លៃលើតម្រូវការរបស់ខ្ញុំ នៃកម្មវិធីរបស់ក្រសួង អប់រំយុវជន និងកីឡា*

ជំពូក

៤

# ការសហការគ្នា

# ការសហការជាមួយអ្នកដទៃ

មេរៀននេះ ធ្វើឱ្យសិស្សរកឃើញនូវតម្លៃនៃការដោះស្រាយបញ្ហា ដោយការសហការគ្នាជាជាងធ្វើការដោយឯកឯង ។ ការបង្រៀនពីការសហការធ្វើឱ្យប្រសើរដល់ទំនាក់ទំនងរវាងបុគ្គល និងបុគ្គល នាំឆ្ពោះទៅកាន់ការឯកភាពអារម្មណ៍ក្នុងក្រុម ។ ការនេះបង្កើតបានជាបរិយាកាសមួយដែលមិនបង្កទំនាស់ និងជំរុញនូវជំនាញដោះស្រាយបញ្ហាដ៏ចាំបាច់សម្រាប់ការដោះស្រាយទំនាស់ ។

**វត្ថុបំណង** :

ច: សិស្សយល់ពីអត្ថន័យនៃពាក្យសហការតាមខ្លឹមសារមេរៀន

ឥ: សិស្សមានឧទាហរណ៍ជាក់ស្តែងពីរបៀបសហការជាមួយអ្នកដទៃនៅក្នុងសាលារៀន និងសហគមន៍

ប: សិស្សពេញចិត្តធ្វើការជាក្រុមជាងធ្វើការម្នាក់ឯង

**រយៈពេល** : ៣០ នាទី

**សម្ភារៈ** : រឿង "ឋានសួគ៌ និង ឋាននរក"

### ឋានសួគ៌ និងឋាននរក ~ រឿងប្រពៃណីរបស់ចិន



ប្រជាពលរដ្ឋទូទៅតែងតែនិយមការបន់ស្រន់ ។ គ្រាមួយ នៅក្នុងប្រទេសចិន មានបុរសម្នាក់បានសុំឃើញភាពខុសគ្នារវាងឋានសួគ៌ និងឋាននរកឱ្យបាននៅមុនពេលគាត់ស្លាប់ ។ ថ្ងៃមួយបុរសនោះបានសម្រេចជោគជ័យនូវការបន់ស្រន់របស់គាត់ គឺគាត់បានសុបិន្តឃើញឋាននរក នៅលើតុពោរពេញដោយម្ហូបឈ្ងុយឆ្ងាញ់ ក៏ប៉ុន្តែនរក នៅទីនោះបែរជាកំពុងតែស្រេកឃ្លាន និងមានកំហឹងរៀងៗខ្លួន ។ ពួកគេមានម្ហូបអាហារ ប៉ុន្តែនរកម្នាក់ៗ ត្រូវបានគេបង្ខំឱ្យអង្គុយនៅចំងាយ១ម៉ែត្រពីតុ ហើយប្រើចង្កឹះប្រវែង១ម៉ែត្រដើម្បីចាប់អាហារដាក់ចូលក្នុងមាត់ ។ គាត់ក៏មានការភ្ញាក់ផ្អើលជាខ្លាំងនៅពេលគាត់ទៅឃើញឋានសួគ៌ពីព្រោះអ្វីៗដូចគ្នានឹងឋាននរកដែរ គឺថាមានតុធំៗ

ជាច្រើនពោរពេញដោយអាហារឆ្ងាញ់ៗដូចគ្នា។ ទេវតាទាំងអស់ត្រូវបង្ខំឱ្យអង្គុយឆ្ងាយពីតុចំងាយ១ម៉ែត្រ ហើយប្រើចង្កឹះប្រវែង១ម៉ែត្រដែលគេមិនអាចចាប់អាហារទទួលទានបានដោយខ្លួនឯងដូចនៅឋាននរកបេះបិទ។ ក៏ប៉ុន្តែនៅឋានសួគ៌ទេវតាទាំងនោះបានហូបឆ្អែតគ្រប់គ្រាន់ និងសប្បាយរីករាយ។ តើហេតុអ្វី?

១. គ្រូអានរឿង "**ឋានសួគ៌ និង ឋាននរក**" ខ្លាំងៗឱ្យសិស្សស្តាប់!

២. ឱ្យសិស្សបែរទៅរកអ្នកអង្គុយបន្ទាប់ និងសួរសំណួរដើម្បីពិភាក្សាថា តើមានអ្វីខុសគ្នារវាងឋានសួគ៌ និងឋាននរក។ បន្ទាប់មកទុកពេល៥នាទីឱ្យពួកគេពិចារណាគ្នា ហើយសួរទៅរកចម្លើយពីពួកគេ។

៣. ប្រសិនបើជាសិស្សទាំងអស់នឹកមិនឃើញទេ គ្រូអាចប្រាប់ទៅពួកគេនូវចម្លើយដូចខាងក្រោម ៖

- នៅឋាននរក នរកទាំងអស់ព្យាយាមបញ្ចុកមាត់ខ្លួនឯង
- នៅឋានសួគ៌ ទេវតាបានបញ្ចុកគ្នាទៅវិញទៅមក

៤. ឱ្យសិស្សពិភាក្សាតាមក្រុមនូវសំនួរដូចខាងក្រោម

**ក.** តើអ្នកភ្ញាក់ផ្អើលទេនូវចម្លើយនៃរឿងនេះ? ហេតុអ្វី?

**ខ.** តើជាញឹកញាប់ បញ្ហាត្រូវបានដោះស្រាយដោយសហការគ្នា ឬដោយបុគ្គលនៅក្នុងសហគមន៍របស់អ្នក?

**គ.** គ្រូឱ្យឧទាហរណ៍មួយនៃវិធីដែលប្រជាជនអាចសហការបានច្រើននៅក្នុងសហគមន៍ ( **ចម្លើយចូលរួម:** អាចរាប់បញ្ចូលបោសសំអាតសំរាម ថែរក្សាកូនអ្នកជិតខាង រាយការណ៍អំពីឧក្រិដ្ឋកម្មទៅឱ្យប៉ូលីស ស្រោចដំណាំនៅសាលារៀន ។ល។

## ៦. សន្និដ្ឋាន ៖

នៅក្នុងភាសាអង់គ្លេសមានប្រយោគមួយៈ "**មានដៃកាន់តែច្រើន កាន់តែជួយសម្រួលការងារបានកាន់តែច្រើន**"។ មានន័យថា បើយើងចេះសាមគ្គីគ្នានោះ បន្ទុកការងារនឹងត្រូវបានធូរស្រាល។ បើយើងអាចជួយគ្នានៅក្នុងគ្រួសាររបស់យើង សាលារៀន សហគមន៍ និងនៅក្នុងប្រទេសកម្ពុជា ស្ថានភាពទាំងមូល នឹងត្រូវបានប្រសើរឡើង។ នៅក្នុងភាសាចិនគេនិយាយថា **ឫស្សីមួយដើមមិនអាចធ្វើក្បូនមួយបានទេ**។ បើសិនជាយើងគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន នោះយើងនឹងមិនបានសម្រេចជោគជ័យធំដុំឡើយ។ ការសហការជាមួយអ្នកដទៃនឹងជួយឱ្យប្រទេសជាតិមានការរីកចំរើន។ ចូរសម្លឹងមើល ក្រែងអ្នកអាចរកឃើញនូវមធ្យោបាយមួយ ដើម្បីសហការជាមួយអ្នកដទៃបាននៅក្នុងបច្ចុប្បន្ននេះ។

# ការធ្វើការរួមគ្នា

ការសហការរួមមានប្រតិកម្មពីគ្នាទៅវិញទៅមក និងការប្រាស្រ័យទាក់ទងគ្នារវាងបុគ្គល និងបុគ្គល ។ ក្នុងនាមបុគ្គល យើងមានគំនិតផ្ទាល់ខ្លួន ស្តីពីវិធីដែលធ្វើឱ្យភារកិច្ចអាចត្រូវបានសម្រេចគោលដៅ ។ ដោយសារការធ្វើឱ្យប្រសើរដល់ទំនាក់ទំនងជាក្រុម ប្រតិកម្មពីគ្នាទៅវិញទៅមកដែលយើងមានទាំងអស់គ្នា និងការប្រាស្រ័យទាក់ទងរបស់យើង នោះយើងអាចជៀសវាងបាន ឬអាចដោះស្រាយនូវរាល់ទំនាស់ដែលអាចកើតឡើងក្នុងចំណោមសមាជិកក្រុមមុនពេលទំនាស់នោះឈានទៅរកសភាពធ្ងន់ធ្ងរ ហើយអាចបំផ្លាញភារកិច្ចដែលក្រុមទាំងមូលកំពុងព្យាយាមធ្វើឱ្យសម្រេច ។

**វត្ថុបំណង:**

ច: សិស្សយល់អំពីរបៀបសហការ ការប្រាស្រ័យទាក់ទង និងទំនាក់ទំនងល្អ ដែលធ្វើឱ្យការធ្វើការរួមគ្នាជាមួយអ្នកដទៃបានប្រសើរឡើង

ប: សិស្សប្រាស្រ័យទាក់ទង និងធ្វើការកាន់តែមានប្រសិទ្ធភាពជាមួយអ្នកដទៃនៅពេលមានភារកិច្ចប្រគល់ឱ្យ

ឥ: សិស្សចង់សហការជាមួយអ្នកដទៃនៅពេលគេធ្វើការងារជាក្រុម

**រយៈពេល** : ៣០ នាទី

**សម្ភារ** : ក្រដាស, ខ្មៅដៃ

**ចំណាកនាំបង្រៀន:**

១. ចែកសិស្សក្នុងថ្នាក់ជាក្រុមៗដែលមាន៥-៦នាក់ ។ ក្រុមនីមួយៗគូររូបភាពមួយ ដោយមិនប្រើពាក្យសំដីណាមួយសម្រាប់ការប្រាស្រ័យទាក់ទង ។ ត្រូវមានបទបញ្ជារដូចជា:

ក. សិស្សក្នុងក្រុមមិនអាចសម្រេចចិត្តជាមុនថាត្រូវគូររូបអ្វីនោះទេ

ខ. សិស្សម្នាក់ៗអាចគូរបានតែបន្ទាត់ដែលត្រង់ឡើងលើ ផ្ដេក ឬបញ្ឆិត ខ្សែកោង កន្លះរង្វង់ ឬរង្វង់មូលតែមួយប៉ុណ្ណោះ ( មើលតាមគំនូសនេះ: / — | ∪ ∩ O )

គ. សិស្សម្នាក់ៗត្រូវដាក់វេនគ្នាគូរ

ឃ. សិស្សចាប់ផ្ដើមគូរតាមវេន

ង. គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឱ្យនិយាយ

២. សិស្សទី១ ចាប់ផ្ដើមគូរ នៅពេលគូរចប់សិស្សទី២ ចាប់ផ្ដើមគូរបន្ត ។ សិស្សទី២ សម្រេចចិត្តរួចជាស្រេច ថាតើគួរចាប់ផ្ដើមពីចំណុចថ្មី ឬបន្តរូបពីអ្នកទី១ ។ អ្នកទី៣ ធ្វើបន្តគ្នាហូរហែរ ។

៣. ១៥នាទីក្រោយមកគ្រូសុំឱ្យក្រុមឈប់គូរ ហើយឱ្យបង្ហាញរូបនោះទៅឱ្យសិស្សក្នុងថ្នាក់បានឃើញ។ ទុកពេលឱ្យក្រុមនីមួយៗ ២ ឬ៣នាទី ដើម្បីពិពណ៌នាពីអ្វីដែលបានកើតឡើងនៅពេលក្រុមដំណើរការគូររូបនោះ។

៤. គ្រូសួរសំណួរទាំងនេះទៅសិស្សក្នុងថ្នាក់

**ក.** តើអ្នកសប្បាយចិត្តនឹងគំនូររបស់អ្នកដែរឬទេ?

**ខ.** តើអ្នកបានសហការគ្នាដែរឬទេ? តើបានសហការគ្នាយ៉ាងដូចម្ដេច?

**គ.** តើអ្វីខ្លះជាឧបសគ្គចំពោះការសហការរបស់អ្នក? (**ឧទាហរណ៍:** ការយល់ច្រឡំ គ្មានការប្រាស្រ័យទាក់ទងល្អ)។

**ឃ.** តើមានទំនាស់អ្វីទេក្នុងចំណោមពួកអ្នកនៅពេលគូររូប? ហេតុអ្វី?

**ង.** តើអ្នកដោះស្រាយទំនាស់បានយ៉ាងដូចម្ដេច?

៥. គ្រូសួរសិស្សដើម្បីបំផុសគំនិតពីអ្វីដែលគេគិតថាជាធាតុសំខាន់ៗពេលគេធ្វើការសហការរួមគ្នា? (**ចម្លើយចូលរួម:** ការប្រាស្រ័យទាក់ទងល្អ ទស្សនៈច្បាស់លាស់ ការស្វែងយល់ពីគ្នាបានល្អ ការសហការគ្នា ការព្រមព្រៀងគ្នា ដែលកើតឡើងដោយការសម្របសម្រួល និងភាពជាអ្នកដឹកនាំ)។ គ្រូសរសេរបញ្ជីចម្លើយសិស្សលើក្ដារខៀន

៦. **សន្និដ្ឋាន:**

មិនថាយើងធ្វើកិច្ចការអ្វី ឬរស់នៅកន្លែងណាទេ យើងចាំបាច់ត្រូវធ្វើការជាមួយអ្នកដទៃ។ បើសិនជាយើងមានការប្រាស្រ័យទាក់ទងល្អ និងយល់គ្នាច្បាស់លាស់ មានការឃោគយល់រួមគ្នា ហើយសហប្រតិបត្តិការល្អ យើងអាចមានបទពិសោធន៍ជាវិជ្ជមាន ហើយអាចសម្រេចកិច្ចការបានច្រើន។ បើយើងគិតតែពីតម្រូវការផ្ទាល់ខ្លួន ហើយមិនគិតពីគំនិតយោបល់ និងអារម្មណ៍អ្នកដទៃ យើងអាចងាយបង្កឱ្យមានទំនាស់ ហើយមិនអាចសម្រេចគោលដៅរបស់យើងបានឡើយ។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១២ មេរៀន: ចេះសហការគ្នានៃកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា*

# ការសម្រុះសម្រួល

យើងមិនត្រូវគិតថា មានតែអ្នកដែលមានកិត្តិវប្បធម៌ខ្ពស់ ឬអ្នកនយោបាយទេ ទើបអាចធ្វើជាអ្នកសម្រុះសម្រួលបាន ប៉ុន្តែសិស្សមធ្យមសិក្សា ក៏អាចធ្វើជាអ្នកសម្រុះសម្រួលឱ្យសិស្សគ្នាគេបានដែរ ។ នៅតាមសាលារៀនមួយចំនួននៃប្រទេសខ្លះ សិស្សានុសិស្ស ត្រូវបានគេបណ្តុះបណ្តាលឱ្យក្លាយជាអ្នកសម្រុះសម្រួល ដើម្បីឱ្យពួកគេជួយដោះស្រាយបញ្ហាមួយចំនួនដែលកើតឡើងចំពោះសិស្សដទៃ។ តួនាទីរបស់អ្នកសម្រុះសម្រួល គឺស្តាប់ការនិយាយរបស់ភាគីទាំងសងខាង ហើយជួយពួកគេឱ្យយល់ព្រមទទួលយកដំណោះស្រាយរួមមួយ ។ តួនាទីរបស់ពួកគេមិនមែនសម្រាប់ប្រាប់ឱ្យអ្នកដទៃធ្វើអ្វីដែលគេចង់ធ្វើនោះទេ ប៉ុន្តែគឺជាការជួយផ្តល់នូវវិធីសាស្ត្រសម្រាប់ដោះស្រាយរវាងគូភាគីទំនាស់ពីរនាក់ ។

**វត្ថុបំណង** :

ច: សិស្សយល់អត្ថន័យនៃពាក្យសម្រុះសម្រួល តួនាទី និងបុគ្គលិកលក្ខណៈនៃអ្នកសម្រុះសម្រួល

ប: សិស្សអាចអនុវត្តជំនាញសម្រុះសម្រួលបាន

ឥ: សិស្សដឹងអំពីលទ្ធភាពរបស់គេផ្ទាល់ ដើម្បីធ្វើជាក្រុមសម្រុះសម្រួល

**រយៈពេល** : ៣០ នាទី

**វាក្យស័ព្ទ** :

ការសម្រុះសម្រួល: ដំណើរការដោះស្រាយបញ្ហាដោយភាគីទី៣ ដែលជាភាគីអព្យាក្រឹត

អ្នកសម្រុះសម្រួល: ភាគីទី៣ ដែលអព្យាក្រឹតណាម្នាក់ដែលជួយដោះស្រាយបញ្ហាណាមួយ ឱ្យដល់ភាគីទំនាស់ ២នាក់ ។ ពួកគេមិនធ្វើការសម្រេចចិត្តនៅក្នុងដំណោះស្រាយណាមួយឡើយ ប៉ុន្តែពួកគេជួយឱ្យភាគីទាំងពីរនោះ ពិភាក្សាគ្នារកដំណោះស្រាយ

**លំនាំនៃការបង្រៀន:**

១- គ្រូសួរសំណួរសិស្ស

ក. តើអ្វីជាការសម្រុះសម្រួល?

ខ. តើអ្នកសម្រុះសម្រួលជានរណា?

គ. តើអ្នកសម្រុះសម្រួលមានបុគ្គលិកលក្ខណៈសំខាន់ៗដូចម្តេចខ្លះ? (**ចម្លើយចូលរួម:** អព្យាក្រឹត ពូកែស្តាប់ យល់ពីបញ្ហា មានឆន្ទៈជួយភាគីទាំងពីរដើម្បីរកដំណោះស្រាយ)

ឃ. តើអ្នកអាចរកឃើញមនុស្សណាម្នាក់នៅក្នុងភូមិដែលជាអ្នកសម្រុះសម្រួលទេ? (**ចម្លើយចូលរួម:** ប្រធានភូមិ ជីដូន ព្រះសង្ឃ គ្រូបង្រៀន បងស្រី បងប្រុស)

ង. តើអ្នកគិតថា អ្នកអាចធ្វើជាអ្នកសម្រុះសម្រួលនៅសាលារៀនបានដែរឬទេ?

២. ណែនាំឱ្យសិស្សបានយល់ពីដំណាក់កាលសម្រាប់ការសម្រុះសម្រួលទំនាស់រវាងភាគីទាំងពីរដូចខាងក្រោមៈ

## ជំហាននៃការសម្រុះសម្រួល

**វិន័យៈ**

១. អ្នកសម្រុះសម្រួលប្រាប់ទៅភាគីទាំងពីរ ថាមានវិន័យ ៤ចំនុច ដែលភាគីនីមួយៗត្រូវតែឯកភាព ៖

- មិននិយាយកាត់គ្នា
- គ្មានការវាយដំលើរាងកាយគ្នា
- មិនអនុញ្ញាតិឱ្យហៅឈ្មោះគ្នាដាច់សាច់
- ត្រូវតែស្មោះត្រង់ឱ្យអស់ពីលទ្ធភាព

សួរទៅភាគីទាំងពីរ ប្រសិនបើពួកគេយល់ព្រមចំពោះវិន័យនេះ ។

**ការកំណត់បញ្ហាៈ**

២. ត្រូវផ្តល់ពេលវេលាឱ្យគ្រប់គ្រាន់ដល់ភាគីទាំងពីរដើម្បីឆ្លើយនឹងសំណួរខាងក្រោមនេះ

- តើអ្នកអាចប្រាប់យើងបានទេ ថាមានរឿងអ្វីកើតឡើង?
- តើរឿងទាំងនោះបានធ្វើឱ្យអ្នកមានអារម្មណ៍យ៉ាងដូចម្តេច?

៣. សង្ខេបនូវអ្វីដែលភាគីម្ខាងៗបាននិយាយ ។

**ការឈានទៅទទួលកិច្ចព្រមព្រៀងៈ**

៤. សួរភាគីម្ខាងៗ

- តើអ្នកត្រូវការអ្វីខ្លះ ពីភាគីម្ខាងទៀតដើម្បីដោះស្រាយបញ្ហានេះបាន?
- តើអ្នកអាចធ្វើអ្វីបានខ្លះ ដើម្បីដោះស្រាយបញ្ហានេះ?
- (សួរទៅភាគីម្ខាងទៀតដែលនៅស្តាប់) តើចម្លើយទាំងអស់នេះសមស្របសម្រាប់អ្នកដែរឬទេ?
- តើបញ្ហានេះត្រូវបានដោះស្រាយហើយមែនទេ? (ប្រសិនបើមិនទាន់បានដោះស្រាយទេ ត្រូវត្រលប់ទៅជំហានទី៣ វិញ) ។

៣. គ្រូឱ្យសិស្សបង្កើតក្រុមដែលមានសមាជិកបីនាក់ ហើយឱ្យពួកគេរកនឹកពីទំនាស់ណាមួយដែលពួកគេបានឃើញក្នុងសាលារៀន ។ សិស្សម្នាក់ធ្វើជាអ្នកសម្រុះសម្រួល ហើយសិស្សពីរនាក់ទៀតធ្វើជាគូទំនាស់ ។ អ្នកសម្រុះសម្រួលក្នុងក្រុមនីមួយៗ គួរព្យាយាមប្រើដំណាក់កាលសម្រុះសម្រួលដើម្បីដោះស្រាយបញ្ហា ។

៤. ក្រោយពីអនុវត្តលំហាត់នេះ គ្រូសួរទៅកាន់សិស្ស

ក. នៅក្នុងក្រុមរបស់អ្នកមានលទ្ធភាពដោះស្រាយបញ្ហាមួយនោះបានដែរឬទេ? តើភាគីទាំងពីររកឃើញកិច្ចព្រមព្រៀងគ្នាដែរឬទេ? តើធ្វើជាអ្នកសម្រុះសម្រួលងាយស្រួលដែរឬទេ? ហេតុអ្វីងាយស្រួល? ហេតុអ្វីមិនងាយស្រួល?

ខ. តើអ្នករៀនសូត្របានអ្វីខ្លះពីការធ្វើជាអ្នកសម្រុះសម្រួល? តើអ្នករៀនសូត្របានអ្វីខ្លះអំពីការធ្វើជាភាគីទំនាស់ម្នាក់ៗ? តើការសម្រុះសម្រួលបានជួយភាគីទាំងពីរឱ្យដោះស្រាយទំនាស់ដោយងាយស្រួលឬទេ?

គ. តើការសម្រុះសម្រួលសម្រាប់ដោះស្រាយបញ្ហានៅក្នុងសាលារៀនជាការចាំបាច់ដែរឬទេ? ហេតុអ្វីចាំបាច់? ហេតុអ្វីមិនចាំបាច់?

ឃ. តើអ្នកគិតថា អ្នកអាចធ្វើជាអ្នកសម្រុះសម្រួលបានដែរឬទេ? ហេតុអ្វីអាច? ហេតុអ្វីអត់?

ង. តើជំហាននៃការសម្រុះសម្រួលមានអ្វីខ្លះ?

៥. **សន្និដ្ឋាន :**

ការសម្រុះសម្រួលមានសារៈសំខាន់ណាស់ សម្រាប់ដំណើរការដោះស្រាយបញ្ហា ក៏ដូចជាការសម្រុះសម្រួលទំនាស់ ។ ការសម្រុះសម្រួលអាចយកទៅដោះស្រាយបញ្ហាដែលតូចៗផងដែរ ។ ជួនកាលនៅពេលដែលយើងមានជម្លោះជាមួយមនុស្សម្នាក់ផ្សេងទៀត នោះយើងក៏មិនចេះដឹងអំពីរបៀបដោះស្រាយទំនាស់ដែរ ។ ពេលនោះអ្នកសម្រុះសម្រួលអាចជួយបំភ្លឺយើងឱ្យច្បាស់ដើម្បីគិតពិចារណា និងស្វែងរកដំណោះស្រាយ ។ យើងទាំងអស់គ្នាអាចធ្វើជាអ្នកសម្រុះសម្រួលបាន ជាពិសេសធ្វើអ្នកសម្រុះសម្រួលឱ្យមិត្តភក្តិយើង អ្នកជិតខាងយើង និងសមាជិកក្នុងគ្រួសារយើង ។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១០ មេរៀនៈ ការជួយកែលំអគ្នាជាភាតរៈ នៃកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា*

# ជំពូក

# ៥

# អ្នកកសាងសន្តិភាព និង
# ការបង្កើតទស្សនវិស័យ

# តើនរណាជាអ្នកកសាងសន្តិភាព ក្នុងសហគមន៍របស់យើង?

ជាធម្មតា យើងចាត់ទុកព្រះមហាក្សត្រ មហាក្សត្រិយានី អ្នកតំណាងរាជរដ្ឋាភិបាល ឬមេដឹកនាំសាសនា ថាជាអ្នកកសាងសន្តិភាព។ គំនិតទាំងនេះត្រឹមត្រូវហើយ ប៉ុន្តែយើងក៏នៅមានប្រជាជនសាមញ្ញខ្លះ ដែលជាអ្នកកសាងសន្តិភាពក្នុងសហគមន៍ផងដែរ។ មេរៀននេះ ធ្វើឱ្យសិស្សមានលទ្ធភាពគិតថា អ្នកកសាងសន្តិភាពជាអ្នកនៅក្នុងសហគមន៍ និងសមាជិកគ្រួសាររបស់ពួកគេផ្ទាល់ និងពិចារណាពីលក្ខណៈ និងគុណសម្បត្តិដែលធ្វើឱ្យនរណាម្នាក់ក្លាយជាអ្នកកសាងសន្តិភាព។ គឺជាការលើកទឹកចិត្តអ្នកទាំងនោះផងដែរ ឱ្យយកតួនាទីផ្ទាល់ខ្លួន ទៅធ្វើជាអ្នកកសាងសន្តិភាពក្នុងជីវភាពប្រចាំថ្ងៃ នៅសាលារៀន នៅផ្ទះ ជាមួយមិត្ត និងគ្រួសាររបស់គេ។

**វត្ថុបំណង** :

ចៈ សិស្សយល់បានពីទស្សនៈទាននៃការកសាងសន្តិភាព

ឥៈ សិស្សវាយតម្លៃអំពីបុគ្គលិកលក្ខណៈរបស់ពួកគេផ្ទាល់ហើយដឹងថា តើបុគ្គលិកលក្ខណៈរបស់គេមានផលប៉ះពាល់យ៉ាងណាទៅលើការកសាងសន្តិភាព និងទំនាស់

ឥៈ សិស្សចាត់ទុកការរួមចំណែកផ្ទាល់របស់ពួកគេ ថាជាអ្នកកសាងសន្តិភាពនៅក្នុងសហគមន៍ សាលារៀន

**រយៈពេល** : ៣០ នាទី

**សម្ភារ** : អត្ថបទដកស្រង់ពីសម្តេចព្រះមហាឃោសានន្ទ

> ការកសាងសន្តិភាព មិនត្រូវការគិតពីខ្លួនទេ។ ការមិនគិតពីខ្លួននេះ ត្រូវមានការចាក់ឫសគល់យ៉ាងមុតមាំ។ ដើម្បីកសាងសន្តិភាព ការស្ទាត់ជំនាញសព្វកិច្ចការ និងសហប្រតិបត្តិការជាកត្តាសំខាន់។ មានតិចតួចណាស់ចំពោះការកសាងសន្តិភាពដែលយល់ថា មានតែយើងម្នាក់គត់ដែលស្គាល់ផ្លូវរកសន្តិភាព។
>
> សន្តិភាវករពិតប្រាកដ គឺត្រូវខិតខំអស់ពីកម្លាំងកាយចិត្តដើម្បីតែសន្តិភាពមួយប៉ុណ្ណោះ។ មិនមែនដើម្បីកិត្តិស័ព្ទ សេចក្តីរុងរឿង ឬក៏សូម្បីតែកិត្តិយសឡើយ។ ការខិតខំប្រឹងប្រែងដើម្បីកិត្តិនាម សេចក្តីរុងរឿង និងកិត្តិយស នឹងទៅជាទង្វើដ៏អាក្រក់បំផុតចំពោះការខិតខំរបស់យើង។
>
> *ដកស្រង់ពី "សន្តិភាពមួយជំហានម្តងៗ" របស់មហាឃោសានន្ទ*

ជំពូក ៩

**អ្នកកសាងសន្តិភាព និងការបង្កើតសន្តិវប្បធម៌**

**វាក្យស័ព្ទ :**

**អ្នកកសាងសន្តិភាព:** អ្នកដែលជួយធ្វើឱ្យមានទំនាក់ទំនងល្អប្រសើរ ជួយទប់ស្កាត់ ឬដោះស្រាយទំនាស់ ។ គាត់អាចជាមន្ត្រីនៅស្ថាប័នណាមួយ ឬសមាជិកណាម្នាក់នៃគ្រួសារ ឬសហគមន៍ ។ អ្នកកសាងសន្តិភាពអាចជាមនុស្សទាំងឡាយនៅក្នុងសាលារៀន ។

**ការកសាងសន្តិភាព:** គឺជាដំណើរការដោះស្រាយទំនាស់ និងជួយក្នុងការអភិវឌ្ឍន៍ទំនាក់ទំនងដែលចុះសម្រុងគ្នារវាងអ្នកដែលមានទំនាស់ ។ សន្តិភាពនឹងមិនកើតឡើងដោយឯកឯងទេ ។ យើងត្រូវធ្វើការដើម្បីសន្តិភាព ។ ដូច្នេះ ប្រជាជនទាំងអស់ត្រូវជួយគ្នាក្នុងការបង្កើតឱ្យមានសន្តិភាពនៅគ្រប់សហគមន៍យើង ។

**ដំណើរការមេរៀន:**

១. គ្រូអានអត្ថបទដកស្រង់របស់ព្រះមហាឃោសានន្ទឱ្យសិស្សស្ដាប់ ។ គ្រូត្រូវអានអត្ថបទដកស្រង់នេះ ពីរទៅបីដងបន្ថែមទៀត ដើម្បីឱ្យប្រាកដថា សិស្សទាំងអស់បានយល់ច្បាស់ ។

២. យោងតាមអត្ថបទដកស្រង់របស់ព្រះមហាឃោសានន្ទ តើអ្វីខ្លះជាបុគ្គលិកលក្ខណៈសំខាន់ៗ សម្រាប់អ្នកកសាងសន្តិភាព? សរសេរចម្លើយលើក្ដារខៀន ។ ( **ចម្លើយចូលរួម:** មិនគិតប្រយោជន៍ផ្ទាល់ខ្លួន ការងារជាក្រុម ការសហការគ្នា ការប្រឹងប្រែងដើម្បីសន្តិភាព មិនគិតពីភាពរុងរឿង មិនគិតពីកិត្តិយស និងកេរ្តិ៍ឈ្មោះ) ។

៣. គ្រូបំផុសគំនិតសិស្សក្នុងថ្នាក់នូវបុគ្គលិកលក្ខណៈសំខាន់ៗដែលអ្នកកសាងសន្តិភាពគួរមាន ។ សរសេរចម្លើយសិស្សលើក្ដារខៀន ។ ( **ចម្លើយចូលរួម:** អត់ធ្មត់ ចិត្តល្អ ស្រឡាញ់ចូលចិត្តប្រជាជន ទទួលស្គាល់ភាពផ្សេងៗគ្នារបស់អ្នកដទៃ រួសរាយ រាក់ទាក់ ។ល ។

៤. គ្រូបំផុសគំនិតសិស្សឱ្យរកឈ្មោះអ្នកកសាងសន្តិភាពទាំងអស់ដែលពួកគេស្គាល់ លើកទឹកចិត្តសិស្សឱ្យគិតពីសមាជិកក្នុងសហគមន៍របស់ពួកគេ ដូចជាអ្នកកសាងសន្តិភាពថ្នាក់ជាតិ ។ សរសេរចម្លើយសិស្សលើក្ដារខៀន ។

៥. ស្នើឱ្យសិស្សជ្រើសរើសអ្នកកសាងសន្តិភាពម្នាក់ពីចម្លើយលើក្ដារខៀន (ចម្លើយសំណួរទី៤) ។ ឱ្យសិស្សសរសេរអំពីសកម្មភាពដែលអ្នកកសាងសន្តិភាពនោះបានធ្វើដើម្បីសន្តិភាព និងអ្វីជាលក្ខណៈសម្បត្តិដែលគាត់មាន ។ គ្រូផ្ដល់ឧទាហរណ៍ខាងក្រោមនេះឱ្យសិស្សបានយល់ និងធ្វើតាម:

**ឧទាហរណ៍ :**






៦. គ្រូទុកពេលឱ្យសិស្ស៥នាទីដើម្បីបញ្ចប់លំហាត់ និង៥នាទីទៀតសម្រាប់ចែករំលែកការបំផុសគំនិតរបស់ពួកគេទៅឱ្យក្រុមជិតខាងមើល

៧. គ្រូសួរទៅសិស្សថា

ក. តើអ្នកគិតថា មានអ្នកកសាងសន្តិភាពក្នុងសាលារៀនរបស់យើងដែរឬទេ? ចូរផ្តល់ឧទាហរណ៍អំពីអ្វីជាសកម្មភាពរបស់គាត់ដែលបានធ្វើ ឬតវិយាបទរបស់គាត់ដែលបានប្រព្រឹត្ត ។

ខ. តើខ្លួនអ្នកផ្ទាល់អាចចាត់ទុកថា ជាអ្នកកសាងសន្តិភាពបានដែរឬទេ?

៨. **សន្និដ្ឋាន:**

អ្នកកសាងសន្តិភាពគិតពីអ្នកដទៃច្រើនជាងគិតពីខ្លួនឯង ។ ពួកគេធ្វើការសហការគ្នា ហើយធ្វើការជាមួយអ្នកដទៃដើម្បីនាំសន្តិភាពសម្រាប់សហគមន៍ និងជាតិរបស់គេ ។ នៅកម្ពុជា មានអ្នកកសាងសន្តិភាពផ្សេងៗគ្នា ។ អ្នកទាំងនោះរួមបញ្ចូលទាំង: មេដឹកនាំសាសនា តំណាងរាជរដ្ឋាភិបាល ហើយពិតជារួមទាំងសមាជិកគ្រួសារ និងសហគមន៍របស់យើងផងដែរ ។ យើងទាំងអស់គ្នាអាចជាអ្នកកសាងសន្តិភាពបាន ប្រសិនបើយើងស្ម័គ្រចិត្ត ។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១២ មេរៀន: រង្វាយតម្លៃលើតម្រូវការរបស់ខ្ញុំ ថ្នាក់ទី១១ មេរៀន:ការបង្កើតវប្បធម៌សន្តិភាព និងថ្នាក់ទី១០ មេរៀន: ការជួយកែលំអគ្គាជាភាតរៈនៃកម្មវិធីរបស់ក្រសួងអប់រំយុវជន*

# ទស្សនវិស័យរបស់ខ្ញុំសម្រាប់អនាគតរបស់ខ្ញុំ

នៅពេលមនុស្សមានអារម្មណ៍ថា គេគ្មានអនាគតទេ នោះគេរស់នៅដោយមិនចាំបាច់គិតពីផលវិបាកដែលបណ្តាលឡើងពីទង្វើរបស់ពួកគេនាពេលបច្ចុប្បន្ននេះ ។ បើយើងស្រម័យពីអនាគតកាល នោះវាអាចជួយឱ្យយើងមើលឃើញអ្វីដែលយើងធ្វើនៅថ្ងៃនេះ នឹងមានសារៈសំខាន់សម្រាប់អ្វីដែលយើងចង់ធ្វើនៅថ្ងៃស្អែកដែរ ។ **ឧទាហរណ៍:** បើអ្នកចង់ក្លាយទៅជាគ្រូភាសាអង់គ្លេសនៅពេលអនាគតនោះ នៅពេលបច្ចុប្បន្ននេះអ្នកត្រូវខំរៀនភាសាអង់គ្លេស ។ ប្រសិនបើអ្នកចង់ក្លាយជាវេជ្ជបណ្ឌិតអ្នកត្រូវយកចិត្តទុកដាក់រៀនសូត្រមុខវិជ្ជាវិទ្យាសាស្ត្រ ។ បើអ្នកចង់មានផ្ទះធំមួយ អ្នកត្រូវសន្សំប្រាក់ពីឥឡូវនេះទៅ ។

**វត្ថុបំណង** :

ច: សិស្សយល់ថា ជីវិតរស់នៅរបស់ពួកគេបច្ចុប្បន្ននេះ មានសារៈសំខាន់ណាស់សម្រាប់រៀបចំអនាគតរបស់ពួកគេ

ប: សិស្សដឹងបាននូវរបៀបកសាងទស្សនវិស័យ

ឥ: សិស្សប៉ាន់ប្រមាណសារជាថ្មីអំពីសកម្មភាពបច្ចុប្បន្ន របស់ពួកគេក្នុងក្តីសង្ឃឹម និងក្តីសុបិន្តសម្រាប់អនាគតរបស់ពួកគេ ។

**រយៈពេល** : ៣០ នាទី

**សម្ភារ** : ក្រដាស, ប៊ិច

**ដំណើរការមេរៀន**

១. គ្រូពន្យល់

យើងទាំងអស់គ្នាតែងតែមានសុបិន្តរបស់យើងសម្រាប់ពេលអនាគត ។ សុបន្តិនោះអាចជាទស្សនវិស័យនៃជីវភាពរស់នៅ និងសង្គមរបស់យើងគ្រប់គ្នាដែលអាចកើតមានជារូបរាងនៅពេលអនាគត ។ ទស្សនវិស័យជួយផ្តល់ឱ្យយើងនូវរូបភាពក្នុងខួរក្បាល អំពីអ្វីដែលយើងមានបំណងប្រាថ្នាក្នុងជីវិតយើង ។ ការស្គាល់យ៉ាងច្បាស់ថាគោលបំណងទៅអនាគតរបស់យើងជាអ្វីនោះ នឹងជួយយើងឱ្យអាចរៀបចំការសម្រេចចិត្តរបស់យើង ក៏ដូចជាទំនាក់ទំនង និងសកម្មភាព ។ ធាតុសំខាន់របស់ការកសាងទស្សនវិស័យ មាន:

ក. អ្វីៗសម្រាប់ពេលអនាគត និង

ខ. ផ្អែកតាមបរិបទ ឬភាពជាក់ស្តែងនៃជីវិតរបស់យើង

២. គ្រូឱ្យសិស្សបង្កើតទស្សនវិស័យផ្ទាល់ខ្លួនសម្រាប់ជីវិតរបស់ពួកគេ ។ គ្រូឱ្យសិស្សគូរគំនូរអំពីទស្សនវិស័យដែលគេប្រាថ្នាចង់បាននៅក្នុងរយៈពេល៥ឆ្នាំ ១០ឆ្នាំ និង២០ឆ្នាំខាងមុខទៀត ។ សំណួរមួយចំនួនអាចជួយឱ្យសិស្សដែលមិនអាចរកនឹកឃើញ:

ក. តើអ្នកនឹងរៀបការដែរទេ?

ខ. តើអ្នកនឹងមានកូនដែរទេ?

គ. តើអ្នកនឹងធ្វើការដែរឬទេ?

ឃ. តើអ្នកនឹងធ្វើការប្រភេទអ្វី?

ង. តើអ្នកនឹងធ្វើដំណើរកំសាន្តដែរឬទេ? តើអ្នកនឹងទៅលេងនៅឯណា?

ច. តើអ្នកនឹងធ្វើជំនួញដែរឬទេ? តើធ្វើជំនួញអ្វី?

ឆ. តើអ្នកនឹងចូលរួមពាក់ពន្ធ័ក្នុងនយោបាយ អប់រំ កសិកម្ម សុខាភិបាល ទូរទស្សន៍ដែរឬទេ?

ជ. តើអ្នកនឹងមានផ្ទះមួយខ្នងឬទេ? តើផ្ទះនោះមានរូបរាងយ៉ាងដូចម្តេច?

៣. គ្រូសួររកសិស្សស្ម័គ្រចិត្តដើម្បីចែករំលែករូបភាពរបស់គេទៅឱ្យសិស្សក្នុងថ្នាក់មើល

៤. គ្រូសួរសិស្ស

ក. តើការកំណត់ការកសាងទស្សនវិស័យ ជួយអ្នកឱ្យរៀបចំផែនការសម្រាប់ថ្ងៃអនាគតបានដែរឬទេ?

ខ. តើវាធ្វើការកែប្រែអាទិភាពរបស់អ្នកដែរឬទេ? តាមរបៀបណា?

៥. **សន្និដ្ឋានៈ**

នៅពេលយើងបង្កើតទស្សនវិស័យសម្រាប់ជីវិតយើង វាផ្តល់ឱ្យយើងនូវអ្វីមួយសម្រាប់តម្រង់គោលដៅ និងអ្វីមួយសម្រាប់ធ្វើការឆ្ពោះទៅមុខ។ យើងប្រហែលជាអាចសម្រេចសុបិន្តរបស់យើងបាន ប្រសិនបើយើងកំណត់សុបិន្តនោះ។ បន្ទាប់មកយើងអាចចាប់ផ្តើមគិតពិរៈរកវិធីដែលត្រូវសម្រេចបានសុបិន្តនោះ។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១២ មេរៀនការសម្រេចគោលដៅនៃជីវិត នៃកម្មវិធីរបស់ក្រសួងអប់រំយុវជន និងកីឡា*

**បច្ចុប្បន្ន**



**១០ឆ្នាំក្រោយមក**



# ការកសាងទស្សនវិស័យសម្រាប់សង្គមរបស់យើង

បើយើងព្យាយាមស្រមៃពីសង្គមនាពេលអនាគត យើងនឹងដំណើរការឆ្ពោះទៅរកភាពប្រសើរបាន។ បើសិស្សសុបិន្ត រួមគ្នាពីសង្គមមួយដែលគេទាំងអស់គ្នាចង់បាន នោះពួកគេត្រូវធ្វើការរួមគ្នាដើម្បីសម្រេចក្តីសុបិន្តនោះ។ ទស្សនវិស័យ សម្រាប់ សង្គមមិនគួរត្រឹមតែរាប់បញ្ចូលកត្តាតម្រូវការរាងកាយដូចជា ការកសាងផ្លូវ សាលារៀន ទន្លេ។ល។ ទេ ប៉ុន្តែ គួររាប់បញ្ចូលផងដែរនូវគុណតម្លៃ និងទំនាក់ទំនងប្រជាជននៅក្នុងសង្គមផងដែរ។

**វត្ថុបំណង** :

ចៈ សិស្សកំណត់បានកាន់តែច្បាស់នូវរបៀបដែលពួកគេចង់ឱ្យប្រទេសរបស់គេ ក្លាយទៅជាយ៉ាងដូចម្តេចទៅថ្ងៃអនាគត

បៈ សិស្សចេះរបៀបកសាងទស្សនវិស័យ

ឥៈ សិស្សអាចវាយតម្លៃការចូលរួមរបស់គេ សម្រាប់ជាតិរបស់ពួកគេ

**រយៈពេល** : ៣០នាទី

**សម្ភារ** : រឿង លោកស្រីវ៉ាងហ្គារី

## រឿងលោកស្រីវ៉ាងហ្គារី



លោកស្រី**វ៉ាងហ្គារីម៉ាថៃ** មកពីប្រទេសកែនយ៉ា នៅទ្វីបអាហ្វ្រិក។ នៅខែមិថុនា ឆ្នាំ១៩៧៧ លោកស្រីបានដាំដើមឈើ៧ដើម ដើម្បីជាក្តីចងចាំចំពោះវីរៈជនជាតិកែនយ៉ា។ ដើម្បីសម្រេចតម្រូវការនេះ នាងបានចាប់ផ្តើមចលនាមួយឈ្មោះថា “**ចលនាខ្សែក្រវាត់បៃតង**”។ នៅឆ្នាំ១៩៩២ ចលនានេះមានស្ត្រីចូលរួមជាង៥ម៉ឺននាក់ ហើយបានដាំដើមឈើជាង១០លានដើម និងជួយសង្គ្រោះដីរាប់ពាន់អេគី (រង្វាស់ដីអង់គ្លេស) កុំឱ្យក្រៀមបែកក្រហែង។ សព្វថ្ងៃនេះ ចលនាខ្សែក្រវាត់បៃតងរីកសាយភាយទៅប្រទេសផ្សេងទៀត ដោយមានសមាជិកពាសពេញពិភពលោក ហើយទទួលរង្វាន់បរិស្ថានពីអង្គការសហប្រជាជាតិ។ ចលនាខ្សែក្រវាត់បៃតងនេះ ធ្វើសកម្មភាពក្នុងគោលបំណងដាំដើមឈើយ៉ាងច្រើនបែបនេះ ដើម្បីបញ្ឈប់មិនឱ្យដីប្រេះបែកក្រហែង និងក៏សម្រាប់យកអុសដុតសម្រាប់លំអប្រទេសឱ្យមានពណ៌បៃតងស្រស់ និងរកប្រាក់ចំណូលសម្រាប់សមាជិកផងដែរ។ ពួកគេគាំទ្រ

ថ្នាលបណ្តុះកូនឈើដែលគ្រប់គ្រងដោយស្ត្រីដែលថែទាំ និងលក់កូនឈើសម្រាប់ដាំតាមដីសាធារណៈ និងឯកជនក្នុងប្រទេសកែនយ៉ា ។ ពួកគេដាំដើមឈើដែលបំរើឱ្យផលប្រយោជន៍ជាច្រើន ដូចជាៈ ក្រូច អាវ៉ូកាដូ និងអូលីវ ដែលអាចធ្វើជាអាហារ និងអុសដុតបាន ។ ពួកគេដាំផងដែរ នូវដើមឈើក្នុងស្រុកដូចជា បាវបាប់ ហ្វីគ និងអាកាស្យ៉ា ដែលត្រូវបានបំបាត់ចោលតាំងពីការមកដល់នៃអំណាចអាណានិគម ។

លោកស្រី**វ៉ាងហ្គារី** ដែលបានកើតនៅឆ្នាំ១៩៤០ បានចាប់អារម្មណ៍ជំរុញឱ្យមានការផ្លាស់ប្តូរក្នុងប្រទេសលោកស្រី ។ លោកស្រីជាស្ត្រីកែនយ៉ាទី១ ដែលបានក្លាយជាសាស្ត្រាចារ្យជីវវិទ្យានៅក្នុងប្រទេសកែនយ៉ា ។ លោកស្រីជាម្តាយដែលមានកូន៣នាក់ផងដែរ ។

ទោះបីជាលោកស្រី**វ៉ាងហ្គារី** និងចលនាខ្សែក្រវាត់បៃតង ធ្វើកិច្ចការបានល្អក្នុងការជួយគេរាល់ថ្នាក់ដោយក៏លោកស្រី**វ៉ាងហ្គារី** និយាយថា "អ្នកមិនអាចប្រយុទ្ធដើម្បីបរិស្ថានដោយមិនមានទំនាស់ជាមួយអ្នកមានអំណាចបានទេ" ។ សម្រាប់លោកស្រី ចលនាបរិស្ថានជាផ្នែកមួយនៃចលនាគាំទ្រលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសកែនយ៉ា ។ ចលនានេះជួយប្រជាជនឱ្យទទួលបានការគ្រប់គ្រងឡើងវិញ នូវអ្វីដែលកើតឡើងចំពោះជីវិតរបស់គេ ដើម្បីធានាការចូលរួម ក្នុងការកំណត់ទិសដៅនៃការអភិវឌ្ឍន៍ជាតិ ។

*Extract from Learning to Abolish War - Teaching Toward a Culture of Peace.*

**ចំណើកនាំមេរៀន :**

១. គ្រូអានរឿង "លោកស្រី**វ៉ាងហ្គារី**" ។ គ្រូអានរឿងយឺតៗ និងខ្លាំងៗ ដើម្បីឱ្យសិស្សក្នុងថ្នាក់យល់ពីសាច់រឿងឱ្យបានច្បាស់លាស់ ។

២. គ្រូសួរសិស្សក្នុងថ្នាក់
   - ក. សំណួរសម្រាប់ការផ្ទៀងផ្ទាត់សាច់រឿង
     - ១. តើលោកស្រី **វ៉ាងហ្គារី** ជានរណា?
     - ២. តើគាត់បានធ្វើអ្វីខ្លះ?
   - ខ. សំណួរពិភាក្សា
     - ១. តើអ្នកយល់យ៉ាងដូចម្តេចចំពោះរឿងរបស់លោកស្រី**វ៉ាងហ្គារី** ?
     - ២. តើលោកស្រី **វ៉ាងហ្គារី** មានទស្សនវិស័យដូចម្តេចសម្រាប់ប្រទេសលោកស្រី?

៣. គ្រូពន្យល់សិស្សបន្ថែមថា ទស្សនវិស័យគឺជារូបភាពដែលយើងមាននៅក្នុងការគិតរបស់យើង នូវវិធីដែលចង់ឱ្យសង្គមប្រែក្លាយទៅជាយ៉ាងណាទៅអនាគត ។ ទស្សនវិស័យជួយជំរុញ និងចាត់អាទិភាពដល់យើងនូវអ្វីដែលយើងអាចធ្វើឱ្យប្រសើរឡើងនៅពេលអនាគត ។ ទស្សនវិស័យនឹងជួយបង្កើតការសម្រេចចិត្ត ទំនាក់ទំនង និងសកម្មភាពនៅពេលបច្ចុប្បន្ននេះ ។ កត្តាសំខាន់ៗរបស់ទស្សនវិស័យគឺៈ

- សម្រាប់ពេលអនាគត និង
- ផ្អែកតាមបរិបទជាក់ស្តែង និងការពិតនៃជីវិតយើង

៤. គ្រូឱ្យសិស្សគូរទស្សនវិស័យផ្ទាល់ខ្លួនរបស់គេសម្រាប់ប្រទេសកម្ពុជា។ ក្នុងក្រុមដែលមានសិស្ស ៣-៤នាក់ ពួកគេអាចប្រើប្រាស់រូបសញ្ញាដើម្បីបង្ហាញពីគំនិតខុសគ្នាលើគំនូររបស់ពួកគេ។ សំណួរទាំងនេះ អាចជួយសិស្សឱ្យមានលទ្ធភាពកសាងទស្សនវិស័យបាន ៖

ក. តើបរិស្ថាននឹងមានរូបរាងយ៉ាងដូចម្តេច? តើមានដើមឈើដែរឬទេ? តើទឹកទន្លេស្អាតដែរឬទេ?

ខ. តើប្រជាជនប្រើផ្លូវរបៀបយ៉ាងដូចម្តេចក្នុងការដឹកជញ្ជូន?

គ. តើសាលារៀន និងសាកលវិទ្យាល័យមានបំពាក់សម្ភារយ៉ាងដូចម្តេចខ្លះ?

ឃ. តើមានប្រភេទនៃឱកាសសម្រាប់ស្វែងរកការងារធ្វើឬទេ? តើមានពាណិជ្ជកម្មប្រភេទអ្វីខ្លះ? តើមានល័ក្ខខ័ណ្ឌអ្វីខ្លះសម្រាប់កម្មករ?

ង. តើសហគមន៍មើលទៅមានសណ្ឋានដូចម្តេច? តើមានមន្ទីរពេទ្យដែរទេ? តើមន្ទីរពេទ្យមានសភាពដូចម្តេច?

ច. តើទំនាក់ទំនងប្រភេទណាដែលប្រជាពលរដ្ឋមានរវាងគ្នានឹងគ្នា? តើប្រជាពលរដ្ឋមានអារម្មណ៍សុវត្ថិភាពដែរឬទេ? តើប្រជាពលរដ្ឋមានអារម្មណ៍ល្អដែរឬទេ? ហេតុអ្វី?

៥. ក្រុមនីមួយៗ ពន្យល់ពីរូបភាពស្តីពីទស្សនវិស័យរបស់ពួកគេ ហើយបន្ទាប់មក ព្យួររូបភាពទាំងនោះលើជញ្ជាំងដើម្បីតាំងបង្ហាញ។

៦. គ្រូឱ្យសិស្សសរសេរមួយល្បះស្តីពី របៀបដែលពួកគេម្នាក់ៗ អាចជួយដើម្បីធ្វើឱ្យសម្រេចជោគជ័យក្នុងការកសាងសង្គមដ៏ល្អប្រសើរមួយនៅកម្ពុជា។

៧. **សន្និដ្ឋាន៖**

នៅពេលដែលយើងអភិវឌ្ឍទស្សនវិស័យដ៏សាមញ្ញមួយសម្រាប់សង្គមរបស់យើង នោះវាផ្តល់ឱ្យយើងនូវគោលបំណងមួយចំនួនដើម្បីធ្វើការឆ្ពោះទៅមុខ។ យើងហាក់បីដូចជាសម្រេចនូវក្តីសុបិន្តរបស់យើង ប្រសិនបើយើងបានកំណត់វា។ បន្ទាប់មកយើងអាចចាប់ផ្តើមគិតពីវិធីដែលធ្វើឱ្យយើងសម្រេចបានជោគជ័យ។ យើងទាំងអស់គ្នាមានការទទួលខុសត្រូវក្នុងការកសាងប្រទេសជាតិឱ្យបានកាន់តែប្រសើរឡើង។ ការមានទស្សនវិស័យគឺជាជំហានទីមួយ។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១២ មេរៀនការកំណត់គោលដៅនៃជីវិត នៃកម្មវិធីរបស់ក្រសួងអប់រំយុវជន និងកីឡា*

# ទស្សនវិស័យនៃសន្តិភាពសម្រាប់ពិភពលោកយើង

មេរៀននេះមានបំណងស្វែងរកគំនិតផ្សេងៗគ្នា ស្តីពីសន្តិភាពដែលមនុស្សមានដើម្បីធ្វើឱ្យសិស្សអាចពិចារណាអំពីទស្សនវិស័យរបស់ពួកគេសម្រាប់សន្តិភាព។ អត្ថបទដកស្រង់ខាងក្រោម ត្រូវបានយកចេញពីអ្នកទទួលរង្វាន់ណូបែលសន្តិភាពចំនួន៣នាក់ដែលបរិយាយថា តើសន្តិភាពមានន័យដូចម្តេចសម្រាប់ពួកគេ? ។ អត្ថបទដែលបានជ្រើសរើសទាំងបីនេះបញ្ជាក់ច្បាស់ថា **គ្មានសន្តិភាពទេនៅពេលមានភាពក្រីក្រ ឬការរំលោភបំពាន។**

**វត្ថុបំណង** :

ច: សិស្សដឹងថា សន្តិភាពមិនមែនគ្រាន់តែអវត្តមាននៃសង្គ្រាមតែប៉ុណ្ណោះទេ ប៉ុន្តែសន្តិភាពពាក់ព័ន្ធទៅនឹងការកាត់បន្ថយភាពក្រីក្រ និងការបញ្ចប់ទៅនៃទុក្ខវេទនាថែមទៀតផង

ប: សិស្សនឹងអភិវឌ្ឍនូវជំនាញត្រិះរិះពិចារណាដែលទាក់ទងនឹងសង្គមរបស់ពួកគេ

ឥ: សិស្សមានចិត្តចង់កសាងសន្តិភាពនៅក្នុងពិភពលោក

**រយៈពេល** : ៣០ នាទី

**សម្ភារ** : អត្ថបទដកស្រង់៣ របស់អ្នកទទួលបានរង្វាន់ណូបែលសន្តិភាព

- នៅក្នុងពិភពលោកនេះគ្មានសន្តិសុខពេញលេញទេ ពីព្រោះជាតិនានា បានចូលរួមក្នុងការប្រណាំងប្រជែងសព្វាវុធដ៏ឆ្កួតលីលា ដោយចំណាយយ៉ាងខ្ជះខ្ជាយនូវទឹកប្រាក់រាប់កោដិដុល្លាលើសម្ភារដ៏មហាប្រល័យ នៅពេលដែលមនុស្សរាប់លាននាក់កំពុងតែអត់ឃ្លាន។ គ្រាន់តែមួយផ្នែកតូចនៃថវិកាចំណាយលើវិស័យការពារនេះ ក៏អាចធ្វើឱ្យមានភាពខុសគ្នាក្នុងការដែលអាចឱ្យកូនចៅព្រះជាម្ចាស់បានចម្អែតក្រពះរបស់ពួកគេ បានទទួលការអប់រំ និងត្រូវបានផ្តល់ឱកាសឱ្យពួកគេរស់នៅក្នុងជីវិតមួយរីករាយ។

*ដេសម៉ុនដឺទូទូ - អាហ្វ្រិកខាងត្បូង*[1]

---

*១. ដេសម៉ុនដឺទូទូ (១៩៣១ ត្រូវបានស្គាល់ជាអន្តរជាតិ សម្រាប់ភាពជាអ្នកដឹកនាំរបស់គាត់ក្នុងការតស៊ូអហិង្សា ប្រឆាំងរបបអាប៉ាថេតនៅអាហ្វ្រិកខាងត្បូង។*

- នៅពេលដែលខ្ញុំលើកមនុស្សដែលអត់ឃ្លានម្នាក់នៅតាមផ្លូវថ្នល់ ខ្ញុំឱ្យគាត់នូវបាយមួយចាន នំប៉័ងមួយដុំ គឺខ្ញុំពេញចិត្តណាស់ ព្រោះខ្ញុំបានបំបាត់ភាពអត់ឃ្លាននោះ ។ ប៉ុន្តែមនុស្សម្នាក់ត្រូវបានគេផាត់ចោល ដែលមានអារម្មណ៍ថា គ្មានគេត្រូវការ គ្មានគេស្រឡាញ់ ហើយភ័យខ្លាច មនុស្សម្នាក់ដែលគេផាត់ចោលពីសង្គមដែលភាពក្រីក្រនោះពោរពេញដោយការឈឺចាប់មិនអាចទ្រាំទ្របាន ហើយដែលខ្ញុំគិតថា ពិបាកនឹងទទួលយកបានខ្លាំងណាស់ ។ ដូច្នេះចូរយើងជួបគ្នាជាមួយស្នាមញញឹម ព្រោះស្នាមញញឹមគឺជាការចាប់ផ្តើមនៃក្តីស្រលាញ់ ហើយនៅពេលយើងចាប់ផ្តើមស្រឡាញ់គ្នា ជាធម្មតាគឺយើងតែងតែចង់ធ្វើអ្វីមួយ ។

*អ្នកម្តាយតេរ៉េសា -ឥណ្ឌា*[២]

- សន្តិភាពក្នុងន័យថា អវត្តមានសង្គ្រាម មានគុណតម្លៃតិចតួចណាស់សម្រាប់នរណាម្នាក់ដែលកំពុងតែស្លាប់ដោយអត់ឃ្លាន ឬស្លាប់នឹងភាពត្រជាក់ ។ វានឹងមិនបំបាត់ការឈឺចាប់បណ្តាលមកពីទណ្ឌកម្មដែលដាក់លើអ្នកទោសមនសិការ ។ វាមិនបានលួងលោមអ្នកដែលបាត់បង់អ្នកដែលជាទីស្រលាញ់នៅក្នុងទឹកជំនន់បណ្តាលមកពីការកាប់បំផ្លាញព្រៃឈើ គ្មានការគិតគូរក្នុងប្រទេសជិតខាង ។ សន្តិភាពអាចស្ថិតស្ថេរបាននៅកន្លែងណាដែលមានការគោរពសិទ្ធិមនុស្ស កន្លែងដែលមនុស្សមានអាហារបរិភោគ និងកន្លែងដែលបុគ្គល និងជាតិទាំងមូលមានសេរីភាព ។

*ដាឡៃឡាមា -ទីបេ*[៣]

**ដំណើរការនាំមេរៀន :**

១. គ្រូឱ្យសិស្ស ៣នាក់ អានអត្ថបទដកស្រង់ខាងក្រោមឱ្យសិស្សក្នុងថ្នាក់ស្តាប់:

២. បន្ទាប់ពីអានអត្ថបទដកស្រង់នេះចប់ភ្លាម គ្រូត្រូវពន្យល់ប្រាប់សិស្សថា អ្នកទាំង៣នាក់នោះសុទ្ធតែបានទទួលរង្វាន់ណូបែលសន្តិភាព ។ ពួកគេជាអ្នកកសាងសន្តិភាពដ៏ល្បីឈ្មោះ ។ គ្រូឱ្យសិស្សអានអត្ថបទដកស្រង់ម្តងទៀត ហើយស្នើឱ្យសិស្សស្តាប់ ថាតើសន្តិភាពមានន័យយ៉ាងដូចម្តេចសម្រាប់មនុស្សទាំង៣នាក់នេះ?

*២. អ្នកម្តាយតេរ៉េសា (១៩១០-១៩៩៧) ត្រូវបានគេស្គាល់សម្រាប់ការងាររបស់គាត់ជាមួយអ្នករស់នៅក្នុងតំបន់ក្រីក្ររបស់ឥណ្ឌា ។ គាត់បានកើតនៅម៉ាសេដូនៀនៅទ្វីបអឺរ៉ុប ហើយបានទៅប្រទេសឥណ្ឌា ធ្វើជាគ្រូបង្រៀនម្នាក់ ។ គាត់ត្រូវបានឃើញជុំវិញខ្លួនពោរពេញដោយភាពក្រីក្រ និងភាពអស់សង្ឃឹម ដូច្នេះគាត់បានចេញពីសាលា ដើម្បីទៅជួយដល់អ្នកក្រក្នុងខណៈពេលដែលគាត់រស់នៅក្នុងចំណោមពួកគេ ។ ពីព្រោះតែគាត់ យកចិត្តទុកដាក់ចំពោះអ្នកអត់ឃ្លាន អ្នកឈឺ និងអ្នកស្លាប់ អ្នកដទៃទៀតបានចូលរួមជាមួយគាត់ដោយគាត់ បានបង្កើតអង្គការ ដូនជីមួយដែលបច្ចុប្បន្ននេះ ធ្វើការពាសពេញពិភពលោក ។*

*៣. ដាឡៃឡាម៉ា (១៩៣៥) ត្រូវបានតែងតាំងជាមេដឹកនាំសាសនានៃទីបេក្នុងឆ្នាំ១៩៤០ ។ នៅឆ្នាំ១៩៥៩ ប្រទេសចិនបានគ្រប់គ្រងទីបេ ហើយដាឡៃឡាម៉ាបាននិរទេសទៅប្រទេសឥណ្ឌា ។ ចាប់តាំងពីពេលនោះមកគាត់ធ្វើការដោយគ្មានឡើយហត់ ដើម្បីរំដោះប្រជាជនរបស់គាត់ ។ គាត់ត្រូវបានគេទទួលស្គាល់សម្រាប់ ការប្តេជ្ញាចិត្តចំពោះសិទ្ធិមនុស្ស ភាពអហិង្សា និងសារព្រះពុទ្ធសាសនា សម្រាប់ក្តីស្រលាញ់ និងការអាណិតអាសូររបស់គាត់ ។*

៣. គ្រូបំបែកសិស្សជាក្រុមតូចៗ និងពិភាក្សាសំណួរដូចខាងក្រោម៖

- **ក.** តើជនម្នាក់ៗក្នុងចំណោមមនុស្សទាំងនេះមានទស្សនៈយ៉ាងដូចម្តេចចំពោះសន្តិភាព? (**ចម្លើយចូលរួម៖** ពិភពលោកមួយដែលគ្មានអ្នកអត់ឃ្លាន កន្លែងដែលមិនយកប្រាក់ទៅចំណាយសម្រាប់ទិញអាវុធ ប៉ុន្តែឆ្លើយតប និងតម្រូវការរបស់ប្រជាជន ពិភពលោកដែលគ្មានទុក្ខវេទនា)។
- **ខ.** តើយើងដឹងថា យើងមានសន្តិភាពនៅពេលណា? (**ចម្លើយចូលរួម៖** នៅពេលដែលសិទ្ធិមនុស្សត្រូវបានគេគោរព គ្មាននរណាម្នាក់ត្រូវស្លាប់ដោយសារជម្ងឺ ឬអត់ឃ្លាន គ្មានភាពក្រីក្រ នៅពេលដែលបរិស្ថានត្រូវបានគេការពារ ។ល។)

៤. ឱ្យសិស្សគូររូបមួយដែលឆ្លុះបញ្ចាំងពីទស្សនវិស័យរបស់ពួកគេសម្រាប់សន្តិភាព។

៥. **សន្និដ្ឋាន៖**

សន្តិភាពមានន័យទូលំទូលាយជាងអវត្តមាននៃសង្គ្រាម ព្រោះនៅពេលមនុស្សអត់ឃ្លាន ឈឺចាប់ ត្រូវបានគេកេងយកចំណេញ ឬរំលោភបំពាន នោះពួកគេមិនមែនរស់នៅក្នុងសន្តិភាពទេ។ នៅពេលយើងអាចលុបបំបាត់ភាពឈឺចាប់ចេញពីពិភពលោកបាននោះ ទើបពិភពលោករបស់យើងមានសន្តិភាពពិតប្រាកដ។

*មេរៀននេះស៊ីគ្នាទៅនឹងមេរៀន សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១១ មេរៀន ការបង្កើតវប្បធម៌សន្តិភាពនៃកម្មវិធីរបស់ក្រសួងអប់រំយុវជន និងកីឡា*

ជំពូក

៦

# មេរៀនរូបភាពផ្ទាំងធំរបស់
# អង្គការកាត់បន្ថយអាវុធ
# ជាមូលដ្ឋាន

# រូបភាពផ្ទាំងធំរបស់អង្គការកាត់បន្ថយអាវុធ ជាមូលដ្ឋាន

មេរៀនទាំងនេះគឺជាមេរៀនដែលជាប់ទាក់ទងនឹងរូបភាពផ្ទាំងធំ ដែលផលិតដោយអង្គការកាត់បន្ថយអាវុធ។ សាលារៀនភាគច្រើនគួរតែបានទទួលរូបភាពផ្ទាំងធំទាំងនេះ ហើយព្យួររូបភាពទាំងនេះនៅលើជញ្ជាំង។ ប្រសិនបើពួកគេមិនអាចរករូបភាពផ្ទាំងធំទាំងនេះពីសាលាបាន នោះពួកគេអាចស្នើសុំរូបភាពទាំងនេះពី៖

**អង្គការកាត់បន្ថយអាវុធ**

ផ្ទះលេខ ៥៥ មហាវិថីព្រះសុធារស សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា

អ៊ីម៉ែល: E-mail: wgwr@online.com.kh

ទូរស័ព្ទ: (៨៥៥-២៣)២២២ ៤៦២

វែបសាយ: Website: www.wgwr.org

រូបភាពផ្ទាំងធំនីមួយៗកំណត់ផ្នែកផ្សេងៗ នៃសហគមន៍ខណៈដែលពួកគេមានទំនាក់ទំនង និងការដកហូតអាវុធនៅក្នុងប្រទេសកម្ពុជា ផ្នែកទាំងនោះរួមមាន: រូបភាពសាធារណៈជន កងកម្លាំងប្រដាប់អាវុធ យុវជន និងសន្តិភាព និងការអប់រំសហគមន៍។ មេរៀនទាំងនេះមានបំណងជួយឱ្យសិស្សកាន់តែយល់ស៊ីជំរៅទៅលើអត្ថន័យរបស់រូបភាពផ្ទាំងធំ ហើយពួកគេអាចជួយផ្សព្វផ្សាយអត្ថន័យខ្លឹមសារនៃរូបភាពផ្ទាំងធំអំពីតម្រូវការដកហូតអាវុធធុនតូច និងធុនស្រាលនៅកម្ពុជា។

មេរៀនទី១: សហគមន៍

មេរៀនទី២: កងកម្លាំងប្រដាប់អាវុធ

មេរៀនទី៣: សាធារណៈជន

មេរៀនទី៤: យុវជន

# សហគមន៍

រូបភាពដែលបង្ហាញពីប្រជាជនពីរនាក់ប្ដីប្រពន្ធភ្ញាក់រលឹកយកអាវុធមកប្រគល់ជូនអាជ្ញាធរមានសមត្ថកិច្ចដោយមានរូបភាពស្ដីពីក្ដីស្រមៃចង់បានការរស់នៅក្នុងភូមិរបស់គាត់មានសន្តិសុខ និងសុវត្ថិភាពល្អប្រសើរ ប្រជាពលរដ្ឋមានសិទ្ធិសេរីភាពក្នុងការរស់នៅ និងប្រកបមុខរបរផ្សេងៗដោយគ្មានការភ័យខ្លាច។

**វត្ថុបំណង** :

ច. សិស្សយល់អំពីការរក្សាអាវុធជាតិផ្ទុះជាកម្មសិទ្ធិ បង្កឱ្យមានគ្រោះថ្នាក់ដល់អានាគតរបស់ពួកគេ

ប. សិស្សដឹងថា អាវុធជាតិផ្ទុះខុសច្បាប់ ត្រូវយកទៅប្រគល់ជូនអាជ្ញាធរមានសមត្ថកិច្ច

ឥ. សិស្សពិចារណាថា ការយកអាវុធជាតិផ្ទុះខុសច្បាប់ដែលមាននៅតាមផ្ទះរបស់ពួកគេ ទៅប្រគល់ជូនអាជ្ញាធរមានសមត្ថកិច្ច ជាជំហានទី១ សំដៅធ្វើឱ្យសុវត្ថិភាពក្នុងភូមិកាន់តែប្រសើរជាងមុន

**រយៈពេល** : ១៥នាទី

**សម្ភារ** : រូបភាពផ្ទាំងធំស្ដីពីសហគមន៍




**ចំណងជើងនៃផ្ទាំងរូបភាព:** ការភ្ញាក់រលឹកប្រគល់អាវុធជូនរដ្ឋអំណាច គឺគ្មានទោសពៃរ៍ ប៉ុន្តែនឹងត្រូវបានលើកទឹកចិត្ត

**ដំណើរការនាំមេរៀនៈ**

១. គ្រូបង្ហាញរូបភាពដល់សិស្ស ដើម្បីឱ្យពួកគេបានពិនិត្យពិចារណាពីរបីនាទី

២. គ្រូសួរសិស្សៈ

ក. តើប្អូនឃើញមានរូបអ្វីខ្លះ នៅលើផ្ទាំងរូបភាពធំនេះ?

ខ. បន្ទាប់ពីការប្រគល់អាវុធ តើសហគមន៍មានការរីកចម្រើនដូចម្ដេចខ្លះ?

**៣. សន្និដ្ឋានៈ**

ប្រសិនបើយើងយកអាវុធជាតិផ្ទុះខុសច្បាប់ចេញពីក្នុងសហគមន៍របស់យើង នោះអនាគតនឹងមានការរីកចម្រើនល្អប្រសើរឡើងផ្នែកសន្តិសុខ ការអប់រំ ទ្រព្យសម្បត្តិ ។ល។ ប្រសិនបើយើងដឹងថា នរណាម្នាក់មានអាវុធខុសច្បាប់ នោះយើងគួរតែប្ដេជ្ញាលើកទឹកចិត្តឱ្យគេយកអាវុធទាំងនោះ ទៅប្រគល់ជូនអាជ្ញាធរមានសមត្ថកិច្ច។ មនុស្សដែលយើងទុកចិត្តណាម្នាក់ ត្រូវបានទំនាក់ទំនងដើម្បីចាត់ចែងក្នុងការប្រគល់អាវុធនេះ ។

# កងកម្លាំងប្រដាប់អាវុធ

ផ្ទាំងរូបភាពនេះ បង្ហាញអំពីមធ្យោបាយត្រឹមត្រូវសម្រាប់ឱ្យកងកំលាំងប្រដាប់អាវុធប្រើប្រាស់អាវុធជាតិផ្ទុះ ។ នៅក្នុងរូបភាពផ្នែកខាងឆ្វេង បង្ហាញពីសកម្មភាពប៉ូលីសកំពុងត្រួតពិនិត្យរកមើលអាវុធខុសច្បាប់ ពីអ្នកបើកបរទោចក្រយានយន្ត ។ នេះគឺជាតួនាទីដ៏ត្រឹមត្រូវរបស់កងកម្លាំងប្រដាប់អាវុធ ។ នៅផ្នែកខាងស្តាំនៃរូបភាពនេះបង្ហាញថា ចប់វេនការងារកងកម្លាំងប្រដាប់អាវុធ (ប៉ូលីស និងតម្រួតយោធា) ត្រូវតែយកអាវុធទៅប្រគល់ជូនអង្គភាពវិញ ។ វាគឺជាអំពើខុសច្បាប់សម្រាប់កងកម្លាំងប្រដាប់អាវុធណាដែលយកអាវុធទៅផ្ទះ ឬទុកវាជាកម្មសិទ្ធិនៅក្រៅម៉ោងធ្វើការ ។

**វត្ថុបំណង** :

ច. សិស្សយល់អំពីតួនាទីដ៏ត្រឹមត្រូវរបស់កងកម្លាំងប្រដាប់អាវុធ

ប. សិស្សយល់អំពីច្បាប់អាវុធដែលពាក់ព័ន្ធជាមួយកងកម្លាំងប្រដាប់អាវុធ

ឥ. សិស្សដឹងថា កងកម្លាំងប្រដាប់អាវុធគ្មានសិទ្ធិប្រើប្រាស់អាវុធជាតិផ្ទុះទេ ពេលដែលគ្មានភារកិច្ច

**រយៈពេល** : ១៥ នាទី

**សម្ភារ** : រូបភាពផ្ទាំងធំ ស្តីពីកងកម្លាំងប្រដាប់អាវុធ




**ចំណងជើងផ្ទាំងរូបភាព:** ចប់បេសកកម្មអាវុធត្រូវតែប្រគល់ទៅអង្គភាពវិញ
**ចំណងជើងផ្ទាំងរូបភាព:** ជនណាដែលប្រើប្រាស់អាវុធខុសច្បាប់ត្រូវផ្តន្ទាទោសនៅចំពោះមុខច្បាប់

**ដំណើរការនៃមេរៀន :**

១. គ្រូបង្ហាញរូបភាពដល់សិស្ស ដើម្បីឱ្យពួកគេបានពិចារណាពីរ បីនាទី

២. គ្រូសួរសិស្សនូវសំណួរដូចខាងក្រោម៖

ក. តើប្អូនពិនិត្យឃើញមានរូបអ្វីខ្លះ នៅក្នុងផ្ទាំងរូបភាពនេះ?

ខ. នៅក្នុងរូបភាពផ្នែកខាងឆ្វេង តើពួកគេកំពុងធ្វើអ្វី? ( **ចម្លើយចូលរួម៖** កងកម្លាំងប្រដាប់អាវុធកំពុងតែអនុវត្តតួនាទីក្នុងការត្រួតពិនិត្យអាវុធខុសច្បាប់ពីអ្នកបើកយានយន្ត)

គ. នៅក្នុងរូបភាពផ្នែកខាងស្តាំ តើពួកគេកំពុងធ្វើអ្វី? ( **ចម្លើយចូលរួម៖** នៅចុងម៉ោងធ្វើការ ប៉ូលីស យោធា តម្រួតយោធា កំពុងតែប្រគល់អាវុធរបស់ពួកគេជូនអង្គភាពវិញ ។ អាវុធនីមួយៗ គឺត្រូវបានចុះបញ្ជីយ៉ាងត្រឹមត្រូវ និងរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព ។ កងកម្លាំងប្រដាប់អាវុធដែលគោរពច្បាប់ មិនត្រូវយកអាវុធ ចេញទៅខាងក្រៅនៅពេលចប់ម៉ោងធ្វើការទេ) ។

ឃ. ប្រសិនបើប្អូនឃើញកងកម្លាំងប្រដាប់អាវុធស្ពាយអាវុធនៅក្នុងផ្សារ តើនេះជាទង្វើស្របច្បាប់ ឬខុសច្បាប់? ( **ចម្លើយចូលរួម៖** ខុសច្បាប់បើពួកគេគ្មានភារកិច្ច)

ង. ប្រសិនបើប្អូនឃើញនរណាម្នាក់មានអាវុធខុសច្បាប់ តើប្អូនអាចធ្វើអ្វីបានខ្លះ? ( **ចម្លើយចូលរួម៖** អ្នកអាចរាយការណ៍ពីឧបត្ថិហេតុនេះជូនប៉ូលីស ឬផ្តល់ដំណឹងនេះទៅអង្គការក្រៅរដ្ឋាភិបាលដើម្បីយកអាវុធអានាមិកនេះប្រគល់ជូនអាជ្ញាធរដើម្បីស៊ើបអង្កេតតទៅទៀត ។

៣. **សន្និដ្ឋាន :**

អនុក្រិតលេខ៣៨ចែងថា៖ សមាជិកនៃកងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យយកអាវុធទៅរក្សាទុក ឬប្រើប្រាស់នៅក្រៅម៉ោងធ្វើការ ( ក្រៅបេសកកម្ម) ។ ប្រសិនបើមានសកម្មភាពខុសច្បាប់បានកើតឡើងពួកគេត្រូវរាយការណ៍ទៅអង្គការក្រៅរដ្ឋាភិបាល ដូចជា អង្គការកាត់បន្ថយអាវុធ ឬរាយការណ៍ផ្ទាល់ទៅអាជ្ញាធរប៉ូលីស ។

# សាធារណៈជន

ផ្ទាំងរូបភាពនេះ បង្ហាញពីមនុស្សមួយក្រុមប្លែកៗចំរុះគ្នាដែលរួមមានៈ យោធា ព្រះសង្ឃ និងដូនជី ប្រជាជនអ៊ីស្លាម ឆ្មប យុវជន និងមនុស្សចាស់ បុរស និងស្ត្រី កម្មករសំណង់ អាចារ្យ ប្រជាជនដើមមកពីភូមិភាគនិរតី ។ល។ ពួកគេទាំងអស់ កំពុងឈរក្រោមនិមិត្តសញ្ញាសន្តិភាព គឺរូបព្រាបមួយ ។

**វត្ថុបំណង** :

ច. សិស្សយល់ដឹងថា សន្តិភាពអាចត្រូវបានសម្រេចជោគជ័យ ទោះបីជាយើងមានភាពខុសគ្នាក៏ដោយ

ប. សិស្សអនុវត្តភាពផ្សេងៗជាផ្នែកសំខាន់មួយនៅក្នុងជីវភាពរស់នៅរបស់ពួកគេ

ឥ. សិស្សគោរព និងសម្តែងសេចក្តីអបអរដល់ភាពផ្សេងៗគ្នានៅក្នុងប្រទេស

**រយៈពេល** : ១៥ នាទី

**សម្ភារ** : ផ្ទាំងរូបភាពសាធារណៈជន



**ចំណងជើងរូបភាព :** យើងចង់រស់នៅក្នុងសង្គម សន្តិភាព គ្មានហិង្សា និងគ្មានការប្រើប្រាស់អាវុធខុសច្បាប់ ។

**ដំណើរការនាំមេរៀន ៖**

១. គ្រូបង្ហាញផ្ទាំងរូបភាព ដល់សិស្សដើម្បីឱ្យពួកគេបានពិនិត្យពិចារណា ពីរ ឬបីនាទី

២. គ្រូសួរទៅសិស្សនូវសំណួរដូចខាងក្រោម៖

ក. តើប្អូនបានឃើញអ្វីខ្លះក្នុងផ្ទាំងរូបភាពនេះ? (**ចម្លើយចូលរួម៖** មនុស្សផ្សេងៗគ្នាមួយក្រុមគេគិតថា ពួកគេគឺជា ប្រជាជនកម្ពុជា ហើយរស់នៅក្នុងសន្តិភាព)

ខ. មនុស្សទាំងអស់នៅក្នុងផ្ទាំងរូបភាពនេះមានទឹកមុខដូចម្តេចខ្លះ? (**ចម្លើយចូលរួម៖** ពួកគេសប្បាយចិត្តមានទឹកមុខរីករាយ)

គ. ហេតុអ្វីបានជាគេមានទឹកមុខរីករាយ? (**ចម្លើយចូលរួម៖** ពួកគេរស់នៅក្នុងសន្តិភាពដែលមានរូបព្រាបជានិមិត្តសញ្ញា)

៣. គ្រូពន្យល់សិស្សថា នៅក្នុងប្រទេសកម្ពុជាយើង គឺមានជាតិសាសន៍ផ្សេងៗគ្នា ។ យើងមានបុរស និងស្ត្រី កុមារ និងមនុស្សចាស់ ជាតិពន្ធុខុសគ្នាយ៉ាងច្រើន (ខ្មែរ ចិន វៀតណាម ខ្មែរអ៊ិស្លាម ខ្មែរលើ) វិជ្ជាជីវៈផ្សេងៗជាច្រើន (ឆ្មប យោធា អ្នកនយោបាយ) ។ យើងត្រូវការរស់នៅជាមួយគ្នានៅលើទឹកដី និងសហគមន៍តែមួយ ។

៤. គ្រូបំបែកសិស្សជាក្រុមដែលមានគ្នា៥-៦នាក់ ។ ក្រុមនីមួយៗត្រូវតែពិចារណាលើសំណួរ៖ តើយើងអាចរស់នៅជាមួយគ្នាដោយសន្តិភាពនៅកម្ពុជាដោយវិធីណា? ១៥នាទីក្រោយមកក្រុមនីមួយៗត្រូវឡើងបង្ហាញគំនិតរបស់ពួកគេនៅក្នុងថ្នាក់ទាំងមូល ។

៥. **សន្និដ្ឋាន៖**

ទោះបីថា យើងទាំងអស់គ្នាជាប្រជាជនកម្ពុជាមែន ប៉ុន្តែយើងមានភាពផ្សេងៗដោយឡែកពីគ្នាទាំងអស់ ។ ក្នុងចំណោមពួកយើង អ្នកខ្លះជាយោធា ខ្លះជាឆ្មប ខ្លះជាគ្រូបង្រៀន ខ្លះជាអ្នកនយោបាយ ។ ពួកយើងខ្លះជាកុមារ ខ្លះជាមនុស្សចាស់ ខ្លះជាបុរស ខ្លះជាស្ត្រី ។ ពួកយើងខ្លះជាជនជាតិចិន វៀតណាម ខ្មែរអ៊ិស្លាម ។ នៅក្នុងប្រទេសកម្ពុជាក៏មានភាពផ្សេងៗគ្នានៃសាសនាផងដែរ ស្ទើរតែទាំងអស់គ្នាជាពុទ្ធសាសនិកជន ប៉ុន្តែយើងក៏មានសាសនាជាប្រពៃណីផ្សេងទៀត ដូចជា គ្រិស្តបរិស័ទ មូស្លីម និងក្រុមអ្នកកាន់សាសនាចិន វៀតណាម ។ ហេតុដូច្នេះហើយ យើងទាំងអស់គ្នាគោរព ដើរតាមព្រះមហាក្សត្រ រស់នៅក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលតែមួយ និងគោរពទង់ជាតិតែមួយដូចគ្នា ។ យើងជាប្រជាជនកម្ពុជា ហើយយើងទាំងអស់គ្នាចង់រស់នៅក្នុងសន្តិភាពជាមួយគ្នា ។

# យុវជន

ផ្ទាំងរូបភាពបានបង្ហាញពីយុវជន ជាមួយនិងលទ្ធភាពជម្រើសពីរសម្រាប់អនាគតរបស់គេ។ នៅផ្នែកខាងឆ្វេងខ្លួននៃយុវជននេះបង្ហាញថា ប្រសិនបើគាត់ស្រលាញ់ការសិក្សា គ្មានការពាក់ព័ន្ធ និងការប្រើប្រាស់អាវុធ នោះគាត់អាចមានជីវិតរស់នៅជាគ្រួសារដ៏សប្បាយរីករាយមួយនៅពេលអនាគត និងមានការងារល្អ។ នៅផ្នែកខាងស្តាំ បង្ហាញពីយុវជនកាន់អាវុធជាច្រើន។ ជាផលវិបាក គឺគាត់នឹងត្រូវតែស្លាប់ ហើយមិត្តភក្តិរបស់គាត់នឹងត្រូវជាប់គុក។

**វត្ថុបំណង** :

ច. សិស្សពិចារណាអំពីជម្រើសក្នុងជីវិតរបស់គេគឺ មួយការសិក្សា មួយទៀតការកាន់អាវុធ

ប. សិស្សអាចពិចារណាត្រឹមត្រូវ អំពីជម្រើសនៅក្នុងជីវិតរបស់គេ

ឥ. សិស្សមិនត្រឹមតែត្រូវបានញុំាងឱ្យបោះបង់អាវុធចោល ដោយសារយល់ដឹងផលប៉ះពាល់នៃអាវុធជាតិផ្ទុះ ប៉ុន្តែគេជួយឱ្យអ្នកដទៃទៀតធ្វើដូចគេដែរ

**រយៈពេល** : ១៥ នាទី

**សម្ភារ** : រូបភាពផ្ទាំងធំស្តីពីយុវជនវ័យក្មេងដែលដៃម្ខាងកាន់សៀវភៅ និងដៃម្ខាងទៀតកាន់អាវុធ



**ចំណងជើងនៃផ្ទាំងរូបភាព:** តើផ្លូវណាមួយដែលអ្នកត្រូវ ជ្រើសរើសដើម្បីអនាគតល្អ?
**ចំណងជើងនៅផ្ទាំងរូបភាពខាងក្រោម:** ធ្វើល្អបានផលល្អ ដាំស្រូវទទួលផលស្រូវ
បើអ្នកជាប់ពន្ធនាគារ តើវាផ្តល់ផលវិបាកដល់អ្នកណាខ្លះទៀត?

**ដំណើរការមេរៀន:**

១. គ្រូបង្ហាញផ្ទាំងរូបភាពដល់សិស្ស ដើម្បីឱ្យពួកគេបានពិនិត្យពិចារណាពីរ ឬបីនាទី

២. គ្រូសួរទៅសិស្សនូវសំណួរ:

ក. តើប្អូនបានឃើញអ្វីខ្លះក្នុងផ្ទាំងរូបភាពនេះ?

ខ. តើរូបភាពខាងស្តាំមានអត្ថន័យដូចម្តេច?

គ. តើរូបភាពខាងឆ្វេងមានអត្ថន័យដូចម្តេច?

ឃ. តើប្អូនត្រូវជ្រើសរើសផ្លូវមួយណាដើម្បីអនាគតល្អ?

ង. តើប្អូនត្រូវការអនាគតបែបណា?

៣. **សន្និដ្ឋាន :**

យើងមានជម្រើសក្នុងជីវិតរបស់យើង ហើយអ្វីដែលជាជម្រើសរបស់យើងនោះ យើងត្រូវតែពិចារណាអំពីផលវិបាកនៃជម្រើសនីមួយៗ ។ ប្រសិនបើយើងយកជម្រើសជាការសិក្សា យើងអាចរំពឹងទុកថា នឹងមានគ្រួសារជីវិករាយ និងមានការងារល្អនាពេលអនាគត ។ ប្រសិនបើយើងយកជម្រើសកាន់អាវុធ និងប្រើប្រាស់អាវុធទាំងនោះទៅប្រឆាំងនឹងអ្នកដទៃ នោះយើងអាចទទួលការឈឺចាប់នៅពេលខាងមុខបាត់បង់អ្នកដែលយើងស្រលាញ់ ហើយក៏អាចបណ្តាលឱ្យជាប់គុក ឬក៏ស្លាប់ខ្លួនផងដែរ ។

## ផ្នែកទី ២

# ឯកសារណែនាំវិធីបញ្ជ្រាប
# ខ្លឹមសារការអប់រំសន្តិភាព
# និងដកហូតអាវុធ

# កំណត់យុទ្ធវិធីបង្រៀន
# (បញ្ជ្រាបការអប់រំសន្តិភាព និងដកហូតអាវុធ)

## ក. សញ្ញាណទូទៅ:

វិធីសាស្ត្របង្រៀននៅមធ្យមសិក្សាទុតិយភូមិ មានអត្ថន័យយ៉ាងសំខាន់ទាំងផ្នែកទ្រឹស្តី ទាំងផ្នែកអនុវត្ត ។ វិធីសាស្ត្របង្រៀនទាមទារនូវគោលបំណងមួយច្បាស់លាស់ ។ បើគ្មានគោលបំណង គឺប្រាកដជាគ្មានសកម្មភាពសិស្ស ។ ប្រសិនបើគេមិនបានគិតទៅដល់គោលដៅទេ គឺមានន័យថា វិធីសាស្ត្រដែលគេបានកំណត់ទុកមិនត្រឹមត្រូវ ឬការអនុវត្តន៍មិនបានល្អ ។ គ្រប់វិធីសាស្ត្របង្រៀន ទាមទារនូវការកំណត់គោលបំណងទុកជាមុន ហើយត្រៀមសកម្មភាពឱ្យបានសមស្រប ត្រៀមមធ្យោបាយចាំបាច់ៗសម្រាប់ប្រើប្រាស់ និងសម្រេចឱ្យបានដល់គោលដៅនោះ ។

វិធីបង្រៀនទាំងអស់សុទ្ធតែមានលក្ខណៈពិសេសដោយឡែករបស់ខ្លួន ។ ក្នុងការអប់រំសិស្សជាកម្មវត្ថុ និងប្រធាននៃការអប់រំ ហេតុនេះវិធីបង្រៀនទាំងអស់គឺជាល្បិច ជាបែបនៃការធ្វើសកម្មភាពរបស់គ្រូ និងសិស្សក្រោមការដឹកនាំរបស់គ្រូក្នុងគោលបំណងទទួលយកចំណេះដឹង បំណិន ឥរិយាបថ និងសតិអារម្មណ៍ ដែលជាមូលដ្ឋាននៃការអភិវឌ្ឍន៍ធនធានមនុស្សពេញលេញប្រកបដោយគុណភាព ។

## ខ. វិធីបញ្ជ្រាបការអប់រំសន្តិភាព និងដកហូតអាវុធ

ជាបឋមយើងត្រូវដឹងថា កាលណាគេនិយាយអំពីវិធីបញ្ជ្រាប គេត្រូវគិតដល់ការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្សដែលជាទិដ្ឋភាពនៃលំនាំតែមួយ ហើយដែលមិនអាចកាត់ផ្តាច់ចេញពីគ្នាបាន ។

ក្នុងលំនាំនេះ គ្រូដើរតួជាអ្នកដឹកនាំ អ្នកសម្របសម្រួល ឯសិស្សជាអ្នកធ្វើសកម្មភាពដោយម្ចាស់ការ ។ គ្រប់មុខវិជ្ជានៅសាលាមធ្យមសិក្សាចំណេះទូទៅ ត្រូវគោរពក្រឹត្យក្រមដែលគ្រប់គ្រងលំនាំនៃការបង្រៀនដែលហៅថា "**គោលការណ៍បង្រៀន**" ។

ផ្អែកលើគោលការណ៍ទាំងនេះ លោកគ្រូ-អ្នកគ្រូ អាចបញ្ជ្រាបការអប់រំសន្តិភាព និងដកហូតអាវុធចូលក្នុងមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា នូវវិធីនិងល្បិចបង្រៀនតាមលក្ខណៈពិសេសរបស់ខ្លួន ។

ចំណែកឯសិល្បៈក្នុងការបង្រៀនរបស់គ្រូ និងការចូលរួមរបស់សិស្សក្នុងការត្រិះរិះពិចារណា ស្វែងយល់ខ្លឹមសារបញ្ជ្រាប គឺជាផ្នែកសំខាន់នៃលំនាំបង្រៀន តាមរយៈវិធីសាស្ត្រប្រកបដោយការត្រិះរិះពិចារណា តាមគោលការណ៍ច្បាស់លាស់ ។ គ្រូអាចជួយសិស្សឱ្យទទួលបានចំណេះដឹង បំណិន ឥរិយាបថ ដែលអាចយកទៅប្រើប្រាស់បានក្នុងជីវភាពជាក់ស្តែង ។

ផ្អែកលើមូលដ្ឋានដូចបានរៀបរាប់ខាងលើ គេចែកវិធីបញ្ជ្រាបការអប់រំសន្តិភាព និងដកហូតអាវុធ តាមដំណើកនាំមេរៀនទូទៅគឺ៖

- ពិពណ៌នារូបភាព (សង្កេត)
- អាន (អានស្ងាត់)
  - អានដើម្បីដកស្រង់ចំណុចសំខាន់ៗរបស់អត្ថបទ
  - អានដើម្បីវិភាគខ្លឹមសារ
- សំណួរ និងចម្លើយ
  - សិស្សឆ្លើយសំណួរដែលគ្រូសួរក្រោយពីគេអានអត្ថបទរួច
- សកម្មភាពក្រុម
  - សិស្សពិភាក្សារកចម្លើយ និងវិភាគរកហេតុផលតាមបញ្ហាដែលគ្រូដាក់ឱ្យ
- វាយតម្លៃ

ការអប់រំសន្តិភាព និងដកហូតអាវុធ ពុំមានខ្នាតគំរូសម្រាប់វាយតម្លៃលទ្ធផលសិក្សាឱ្យមានភាពសុក្រឹតនៅក្នុងការអប់រំមេរៀននេះទេ ប៉ុន្តែបម្រែបម្រួល និងផ្លាស់ប្តូរឥរិយាបថរបស់សិស្ស គឺជាជោគជ័យនៃការអប់រំ ។ ដូច្នេះការធ្វើតេស្តវាយតម្លៃនៅដំណាក់កាលចុងក្រោយរបស់សិស្ស ទោះក្នុងសាលារៀនក្តី ក្នុងគ្រួសារក្តី និងសហគមន៍ក្តី គឺត្រង់សិស្សបានបង្ហាញឱ្យឃើញនូវចរិតលក្ខណៈដូចខាងក្រោម៖

- មានស្មារតីភ្ញាក់រលឹក
- មានស្វ័យវិន័យ
- មានសេចក្តីសុចរិតទៀងត្រង់
- មានការគោរព និងទំនួលខុសត្រូវ
- មានសហប្រតិបត្តិការ

# ការប្រើប្រាស់ឯកសារ ការអប់រំសន្តិភាព និងដកហូតអាវុធ

## ១. បញ្ញត្តិទូទៅ:

មេរៀនការអប់រំសន្តិភាព និងដកហូតអាវុធ និងកិច្ចតែងការបង្រៀន : ជាបឋមគ្រូត្រូវកំណត់ឱ្យបានច្បាស់ថា មេរៀនការអប់រំសន្តិភាព និងដកហូតអាវុធ ក៏ដូចជាមេរៀនមុខវិជ្ជាផ្សេងទៀតដែរ វាមិនមែនជាកិច្ចតែងការបង្រៀនទេ មេរៀនទាំងនេះជាទ្រឹស្តីមួយ ដែលត្រូវបានរៀបចំឡើងសម្រាប់ឱ្យគ្រូប្រើប្រាស់ និងទុកជាមូលដ្ឋានសម្រាប់រៀបចំកិច្ចតែងការបង្រៀន ។

ជាទូទៅមេរៀននីមួយៗតែងបង្កប់នូវខ្លឹមសារបីប្រភេទជាមូលដ្ឋានគឺ:

- **ចំណេះដឹង:** គឺជាផ្នែកទ្រឹស្តីដែលគ្រូត្រូវរកឱ្យឃើញ ផ្តល់ដល់សិស្សឱ្យបានសមស្រប ដើម្បីងាយយល់មេរៀនបញ្ច្រាបពេលបង្រៀន គ្រូគប្បីបកស្រាយពន្យល់ទស្សនៈទាននីមួយៗឱ្យបានច្បាស់លាស់ដោយផ្សារភ្ជាប់ទៅនិងឧទាហរណ៍ឱ្យបានច្រើន ។ ក្នុងករណីសិស្សពុំបានយល់ពីទស្សនៈទានច្បាស់លាស់ទេ ការបង្រៀនប្រាកដជាពុំបានលទ្ធផលល្អឡើយ ។
- **បំណិន:** គឺជាការយកចំណេះដឹងទៅប្រើប្រាស់នៅក្នុងជីវភាពជាក់ស្តែង ។ ជាធម្មតាបំណិនបានមកពីការអនុវត្តន៍សកម្មភាពជាប្រចាំក្នុងជីវភាពរស់នៅ ។ ជាទូទៅការអនុវត្តន៍សកម្មភាពដោយងងឹតងងុលខ្វះចំណេះដឹង ពុំនាំមកនូវប្រសិទ្ធភាពឡើយ ។ ហេតុនេះរាល់ការបង្រៀន គ្រូចាំបាច់ត្រូវផ្សារភ្ជាប់ចំណេះដឹងទៅនឹងជីវភាពជាក់ស្តែងឱ្យបានសមស្រប ពោលគឺគ្រូត្រូវកំណត់ឱ្យបានត្រឹមត្រូវថាតើចំណេះដឹងក្នុងមេរៀនដែលបានបង្រៀនរួចហើយនេះ អាចយកទៅប្រើប្រាស់ក្នុងជីវភាពជាក់ស្តែង ជាពិសេសផ្សារភ្ជាប់ទៅនឹងខ្លឹមសារមេរៀនបានយ៉ាងដូចម្តេច?
- **ឥរិយាបថ:** គឺជាកត្តាសំខាន់សម្រាប់ធ្វើឱ្យមនុស្សក្លាយជាមនុស្សពិតប្រាកដ ។ ចំណេះដឹង និងបំណិនជាអាវុធមុខពីរ ហេតុនេះគ្រប់មេរៀនគ្រូត្រូវរកឱ្យឃើញនូវចំណុចវិជ្ជមាន ដើម្បីអប់រំឥរិយាបថសិស្សឱ្យបានល្អ ។

## ២. លំនាំនៃការបញ្ច្រាបៈ

ការបញ្ច្រាបមាននូវរូបភាពប្លែកៗដែលគ្រូអាចជ្រើសរើសយកមកប្រើប្រាស់តាមលទ្ធភាពជាក់ស្តែង ។ ប៉ុន្តែដើម្បីធានាប្រសិទ្ធភាព និងងាយអនុវត្តក្នុងការបញ្ច្រាបមេរៀនការអប់រំសន្តិភាព និងដកហូតអាវុធ ។ គ្រូគប្បីពិចារណាទៅលើគោលការណ៍សំខាន់ៗដូចខាងក្រោមៈ

២.១. **ការកំណត់វត្ថុបំណង:** ក្នុងកិច្ចតែងការបង្រៀនត្រូវតែកំណត់វត្ថុបំណងឱ្យច្បាស់

- តើបញ្ច្រាបអំពីអ្វី? ចង់ឱ្យសិស្សចេះអ្វី?
- តើបណ្ដុះបំណិនអ្វីខ្លះដល់សិស្ស? តើគេអាចយកទៅប្រើប្រាស់ក្នុងជីវភាពរស់នៅបានដូចម្ដេច?
- ពេលបញ្ច្រាបចប់ តើសិស្សទទួលបានអ្វីខ្លះ? តើមានការប្រែប្រួលឥរិយាបថដែរឬទេ?

២.២. **ការកំណត់សម្ភារឧបទេ្ទស:**

តើគ្រូប្រើសម្ភារអ្វីខ្លះ? (គ្រូ-សិស្ស)

២.៣. **ការកំណត់ខ្លឹមសារ:**

ដើម្បីឱ្យសិស្សងាយស្រួលទទួលបានចំណេះដឹងសំខាន់ៗ មេរៀនគប្បី :

- ពន្យល់ទស្សនៈទានសំខាន់ៗ និងពាក្យបច្ចេកទេស ឬពាក្យពិបាកៗក្នុងមេរៀន ។ បើសិស្សមិនយល់ទស្សនៈទាន ការអប់រំសន្តិភាព និងដកហូតអាវុធទេ គេពុំអាចយល់មេរៀនបានដោយស្រួលដែរ ។ ហេតុនេះរាល់ពេលបញ្ច្រាបត្រូវតែធ្វើឱ្យសិស្សយល់ច្បាស់ពីទស្សនៈទាននីមួយៗ ។
- បកស្រាយខ្លឹមសារមេរៀន មេរៀនខ្លះមានខ្លឹមសារស្មុគស្មាញពិបាកយល់ ។ ហេតុនេះក្នុងការបញ្ច្រាបគ្រូត្រូវកំណត់ខ្លឹមសារឱ្យបាន ហើយត្រូវជ្រើសរើសវិធីឱ្យបានសមស្រប ដើម្បីឱ្យសិស្សទទួលយកខ្លឹមសារនោះបាន ។ ម្យ៉ាងទៀតក្នុងការបញ្ច្រាបខ្លឹមសារ គ្រូគប្បីកំណត់ឱ្យបានច្បាស់ពីសកម្មភាពដែលគ្រូ និងសិស្សត្រូវអនុវត្តដើម្បីយល់មេរៀនបាន ។

២.៤. **វិធីបញ្ច្រាប:**

តើគ្រូប្រើមធ្យោបាយអ្វីខ្លះដើម្បីផ្ទេរខ្លឹមសារមេរៀនដល់សិស្ស? ប្រការនេះ អាស្រ័យដោយខ្លឹមសារមេរៀន និងកំរិតចំណេះដឹងជាក់ស្ដែងរបស់សិស្សក្នុងថ្នាក់ ប៉ុន្តែការបញ្ច្រាបដែលមានប្រសិទ្ធភាព គឺការជំរុញសិស្ស ឱ្យចេះរៀន និងស្វែងយល់មេរៀនដោយខ្លួនឯងតាមរយៈ ការធ្វើស្វ័យសិក្សា ការរៀនតាមក្រុម (តូច ធំ ដៃគូ...) ក្រោមការណែនាំតម្រង់ទិសពីគ្រូដែលបច្ចុប្បន្នយើងនិយមហៅថា "គោលវិធីសិស្សមជ្ឈមណ្ឌល" ។

## ៣. របៀបរៀបចំកិច្ចតែងការបង្រៀន:

ដូចយើងបានដឹងរួចមកហើយថា ការរៀបចំកិច្ចតែងការបង្រៀនមេរៀន តែងតែមានពីរដំណាក់កាល គឺដំណាក់កាលត្រៀមគំនិត និងដំណាក់កាលសរសេរ ។

៣.១. **ដំណាក់កាលត្រៀមគំនិត:**

ដំណាក់កាលត្រៀមមានន័យថា ការត្រៀមគំនិតសំខាន់ៗ និងវិភាគស្ថានភាព មុនចាប់ផ្ដើមសរសេរកិច្ចតែងការបង្រៀន ។ តើក្នុងដំណាក់កាលនេះគ្រូត្រូវធ្វើដូចម្ដេចខ្លះ? មុនពេលចាប់ផ្ដើមសរសេរគ្រូចាំបាច់ត្រួតពិនិត្យ និងវិភាគបញ្ហាសំខាន់ៗមួយចំនួនដូចខាងក្រោម:

- ពិនិត្យកម្មវិធីសីលធម៌-ពលរដ្ឋវិជ្ជា តើថ្ងៃនេះបញ្ជ្រាបមេរៀនអ្វី?
- វិភាគរយៈពេលបង្រៀន

តើក្នុងកាលវិភាគប្រចាំសប្តាហ៍ ត្រូវបង្រៀនសីលធម៌-ពលរដ្ឋវិជ្ជា ប៉ុន្មានម៉ោង? តាមកម្មវិធីកំណត់ តើមេរៀននេះត្រូវបញ្ជ្រាបប៉ុន្មាននាទី?។ បន្ទាប់មកត្រូវប្រៀបធៀបខ្លឹមសារ និងរយៈពេលកំណត់ តើអាចបញ្ជ្រាបចប់ដែរឬទេ? តើគួររៀបកិច្ចតែងការបង្រៀនដូចម្តេចដែរ ទើបអាចបញ្ជ្រាបឱ្យបានសមស្រប?

- វិភាគវត្ថុបំណង តើយើងចង់បានអ្វីខ្លះ? តើត្រូវធ្វើដូចម្តេចដើម្បីឱ្យបានដល់វត្ថុបំណងនេះ?
- វិភាគស្ថានភាពសិស្ស ពោលគឺសមត្ថភាពមានស្រាប់របស់សិស្ស តើក្នុងមេរៀននេះអ្វីខ្លះដែលលំបាកចំពោះគេ ឬដែលគេមិនទាន់ចេះ? តើត្រូវធ្វើដូចម្តេចដើម្បីឱ្យគេយល់បានដោយងាយ?
- វិភាគខ្លឹមសារមេរៀន តើក្នុងមេរៀននេះមានខ្លឹមសារសារៈសំខាន់ៗអ្វីខ្លះដែលត្រូវផ្តល់ឱ្យសិស្ស? ចំណេះដឹង បំណិន និងឥរិយាបថ។
- សម្ភារឧបទ្ទេស ដើម្បីធានាប្រសិទ្ធភាពក្នុងការបញ្ជ្រាប តើត្រូវមានសម្ភារអ្វីខ្លះ? គ្រូត្រូវមានអ្វី? សិស្សត្រូវមានអ្វី?
- កំណត់សកម្មភាពដែលត្រូវអនុវត្តនៅពេលដឹកនាំមេរៀន តើគ្រូត្រូវធ្វើសកម្មភាពអ្វីខ្លះ? សិស្សត្រូវធ្វើអ្វីខ្លះដែរ?
- កំណត់កិច្ចការផ្ទះ តើគ្រូគួរដាក់កិច្ចការផ្ទះដូចម្តេចខ្លះដែរ?
- វង្វាយតម្លៃគឺ:
  - ការត្រៀមសំណួរសំរាប់វាយតម្លៃការយល់ដឹងរបស់សិស្ស
  - ការត្រៀមរូបភាពវាយតម្លៃ (ផ្ទាល់មាត់ ឬសរសេរ)

### ៣.២ ដំណាក់កាលសរសេរកិច្ចតែងការបង្រៀនៈ

ដំណាក់កាលសរសេរ គឺការយកគំនិតដែលបានត្រៀមទុកនៅដំណាក់ត្រៀម មករៀបចំសរសេរជាលំអិតច្បាស់លាស់ជាក់ស្តែងតាមខ្លឹមសារមេរៀន។

គំនិតនីមួយៗត្រូវវិភាគឱ្យល្អិតល្អន់ដោយផ្សារភ្ជាប់នឹងខ្លឹមសារមេរៀន។ ការយកគំនិតនេះមករៀបចំកិច្ចតែងការបង្រៀន គ្រូត្រូវរៀបចំជាបីខ្ទង់ ដើម្បីងាយស្រួលប្រើប្រាស់នៅពេលបង្រៀន។ ប្រការដែលគ្រូត្រូវអនុវត្តជាចាំបាច់នោះគឺក្នុងកិច្ចតែងការបង្រៀន ក៏ដូចជាក្នុងលំនាំបង្រៀនត្រូវមាន៥ជំហានជាដាច់ខាត ក៏ប៉ុន្តែដោយសារមេរៀនយើងនេះជាមេរៀនបញ្ជ្រាប ដូច្នេះគ្រូត្រូវតែចាប់ពីជំហានទី៣ បានហើយ។

# លំនាំកិច្ចតែងការបង្រៀន

## សេចក្ដីផ្ដើមៈ

គំនិតសំខាន់ៗសម្រាប់តែងកិច្ចតែងការបង្រៀនមានដូចទៅៈ

- ការកំណត់វត្ថុបំណងឱ្យសិស្សបានជាក់លាក់
- កំណត់ខ្លឹមសារមេរៀនសម្រាប់បញ្ជ្រាបឱ្យសិស្សបានសមស្របតាមរយៈពេលដែលបានកំណត់ (៣០នាទី)
- កំណត់សម្ភារបង្រៀនឱ្យបានសមស្របតាមខ្លឹមសារមេរៀនសម្រាប់បញ្ជ្រាប
- កំណត់រយៈពេលសម្រាប់សកម្មភាពនីមួយៗឱ្យបានសមស្រប
- ការរៀបចំសកម្មភាពតាមលំដាប់លំដោយ ហើយអាចសម្រេចបាននូវវត្ថុបំណងមេរៀន
- សកម្មភាពបញ្ជ្រាបត្រូវឆ្លើយតបនឹងវត្ថុបំណងមេរៀន
- សកម្មភាពបញ្ជ្រាបបម្រើឱ្យវិធីបង្រៀនបែបសិស្សមជ្ឈមណ្ឌល
- សំណួរត្រូវច្បាស់លាស់ និងត្រឹមត្រូវ
- ខ្លឹមសារបញ្ជ្រាបត្រូវផ្អែកទៅលើឯកសារអប់រំសន្តិភាព និងដកហូតអាវុធ ជាមូលដ្ឋាន

## ១. វត្ថុបំណងៈ

ការកំណត់វត្ថុបំណងមេរៀនត្រូវជាក់លាក់ៈ

- វត្ថុបំណងចំណេះដឹងៈ
  - ទស្សនៈទាន ទ្រឹស្ដី.......
  - កិរិយាស័ព្ទប្រើៈ ពណ៌នា រៀបរាប់ ប្រាប់........
- វត្ថុបំណងបំណិនៈ
  - អនុវត្ត ប្រតិបត្តិ
  - កិរិយាស័ព្ទប្រើៈ កំណត់ វិភាគ ពន្យល់........
- វត្ថុបំណងឥរិយាបថៈ
  - ការប្រែប្រួលស្មារតី សញ្ចេតនា
  - កិរិយាស័ព្ទប្រើៈ ចូលចិត្ត ស្រលាញ់ ទម្លាប់........

## ២. ខ្លឹមសារមេរៀនសម្រាប់បញ្ជ្រាបៈ

សរសេរចំណងជើង ឬចំណងជើងរងដែលត្រូវបញ្ជ្រាប ។

## ៣. សម្ភារឧបទេស:

- សៀវភៅ: ទំព័រ........... ឆ្នាំបោះពុម្ព..............
- សម្ភារបន្ថែម: រូបភាពផ្សេងៗ

## ៤. ដំណើរការបង្រៀន

- មេរៀនបញ្ច្រាប (ផ្ដើមមេរៀន)
  - បំផុសបញ្ហាដើម្បីទាញទៅរកមេរៀនបញ្ច្រាប (គ្រូ-សិស្ស)
  - សិក្សាលើរូបភាព (គ្រូ-សិស្ស)
  - សំណួរបំផុស (គ្រូ)

  **ក. ខ្លឹមសារ**

  → សរសេរចំណងជើង និងខ្លឹមសារសំខាន់ៗនៃមេរៀនបញ្ច្រាប

  **ខ. សកម្មភាពគ្រូ**

  សរសេរពីសកម្មភាពផ្សេងៗដែលគ្រូត្រូវធ្វើដូចជា:

  → បង្ហាញរូបភាព ចោទសួរ ដាក់បញ្ហា

  **គ. សកម្មភាពសិស្ស**

  → សិស្សរកចម្លើយ ពិភាក្សា ឡើងរាយការណ៍...........

- ពង្រឹងចំណេះដឹង (វាយតម្លៃ)

  **ក. ខ្លឹមសារ**

  → សង្ខេបចំណុចសំខាន់ៗ

  → សំណួរ សំដែងតួ ល្បែងប្រកួត

  **ខ. សកម្មភាពគ្រូ**

  → ដាក់សំណួរប្រធានបទ

  → រៀបចំសកម្មភាព សំដែងតួ ល្បែងប្រកួត

  → រៀបចំសកម្មភាព បុគ្គល ក្រុមតូច

- កិច្ចការផ្ទះ

  **ក. ខ្លឹមសារ**

  → សរសេរលំហាត់ ឬសំណួរដែលត្រូវដាក់ឱ្យសិស្ស

  **ខ. សកម្មភាព:**

  → គ្រូផ្ដាំផ្ញើ

  **គ. សកម្មភាពសិស្ស:**

  → សិស្សស្ដាប់ការណែនាំរបស់គ្រូ និងកត់ត្រា។

មេរៀនគំរូៈ

# ការយល់ឃើញខុសៗគ្នារបស់យើង

**១. វត្ថុបំណងមេរៀនៈ**

ចំណេះដឹងៈ សិស្សប្រាប់បានពីការយល់ឃើញខុសៗគ្នារបស់មនុស្សឱ្យបានត្រឹមត្រូវតាមរយៈខ្លឹមសារមេរៀន

បំណិនៈ សិស្សរើកញែកពីការយល់ឃើញខុសៗគ្នារបស់មនុស្សឱ្យបានត្រឹមត្រូវតាមរយៈពិភាក្សា

ឥរិយាបថៈ សិស្សគោរពគំនិតរបស់អ្នកដទៃជៀសវាងទំនាស់ឱ្យបាន

**២. រយៈពេល** : ៣០នាទី

**៣. សម្ភារ** : សៀវភៅការអប់រំសន្តិភាព និងដកហូតអាវុធបោះពុម្ពឆ្នាំ ២០០៤ ទំព័រ...........

**៤- ខ្លឹមសារមេរៀនៈ** រឿងបក្សីពីរក្បាល

- អប់រំមនុស្សម្នាក់ៗឱ្យយល់ពីគំនិតខុសៗគ្នាតាមបទពិសោធន៍រៀងៗខ្លួន
- អប់រំមនុស្សម្នាក់ៗឱ្យចេះពិចារណានូវអ្វីដែលខ្លួនបាន និងកំពុងឃើញសម្រាប់បច្ចុប្បន្ន និងទៅអនាគត
- មុននឹងអ្នកជឿអ្នកដទៃត្រូវចាប់ផ្តើមជឿលើខ្លួនឯងសិន
- ការអប់រំមនុស្សម្នាក់ៗឱ្យចេះសម្របខ្លួនទៅតាមស្ថានភាពជាក់ស្តែង

## ៥. ដំណើរការនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| | **ជំហានទី៣ (១៥នាទី)** | |
| • បង្ហាញរូបភាព | • រូបភាព | • សង្កេតរូបភាព |
| • ចូរប្អូនអានអត្ថបទ | • អត្ថបទទំព័រ........ | • សិស្សអានស្ងាត់ |
| • តើប្អូនបានឃើញរូបភាពអ្វីខ្លះ? | • បក្សី | • ខ្ញុំបានឃើញបក្សីពីរក្បាល |
| • ហេតុអ្វីបានជាបក្សីមិនសប្បាយចិត្ត | • ពាក្យមិនសមរម្យ | • ព្រោះបក្សីទាំងពីរប្រើពាក្យមិនសមរម្យដាក់គ្នា |
| • តើបក្សីទាំងពីររកឃើញអ្វី? | • បញ្ឈប់ទំនាស់ | • បក្សីទាំងពីររកឃើញចំនុចស្របគ្នា ដើម្បីជៀសវាងទំនាស់ ។ |
| • តើបក្សីឆ្លើយតបគ្នាយ៉ាងដូម្ដេច ដើម្បីជៀសវាងមិនជល់គ្នា? | • ឆ្លើយស្របគ្នា | • បក្សីទី១ព្រមជឿបក្សីទី២ រួចបក្សីទី២ ក៏ជឿលើបក្សីទី១ដែរ ។ |
| | **ជំហានទី៤ (១០នាទី)** | |
| • តើយើងអាចរៀនសូត្រអ្វីខ្លះពីរឿងនេះ? | • យល់ឃើញគំនិតខុសៗគ្នា ចេះសម្របខ្លួនជាមួយគ្នា | • យើងអាចយល់ឃើញផ្សេងៗគ្នា តាមបទពិសោធ រៀងៗខ្លួន ដើម្បីសម្របខ្លួនជៀសវាងទំនាស់ ។ |
| • តើអ្នកធ្លាប់មានទំនាស់ជាមួយនរណាមួយពីព្រោះតែមានគំនិតខុសគ្នាពីបញ្ហាមួយដែរឬទេ? | • មានទំនាស់ជាមួយគ្នា ពីព្រោះយល់ផ្សេងពីគ្នា | • ខ្ញុំធ្លាប់មានទំនាស់ជាមួយមិត្តដែរ ព្រោះមានគំនិតខុសគ្នា |
| • តើអ្នកដោះស្រាយវាយ៉ាងដូចម្ដេច? | • យល់ស្របតាមគំនិតរបស់មិត្តភក្តិ ជៀសវាងទំនាស់ | • យើងត្រូវដោះស្រាយវិធីសម្របខ្លួន ដើម្បីជៀសវាងទំនាស់ |
| • តើយើងអាចដោះស្រាយទំនាស់ដោយសារទស្សនៈខុសគ្នាបានយ៉ាងដូចម្ដេច? | • ស្វែងយល់គំនិតគ្នា ទៅវិញទៅមក | • យើងត្រូវស្វែងយល់គំនិតគ្នាទៅវិញទៅមក មុននឹងបង្កទំនាស់ |
| | **ជំហានទី៥** | |
| • **គ្រូផ្ដាំផ្ញើ:** ចូរប្អូនអានអត្ថបទមេរៀនបន្ត ។ | • អត្ថបទទំព័រ......... | • សិស្សកត់ត្រា |

# ឯកសារយោង:


Ahmed, A. and Gray, V., *Exiled Leader*, The Story of the 14th Dalai Lama, The Faith in Action Series, 1997.

Bonn International Center for Conversion (BICC), *Tackling Small Arms and Light Weapons,* A Practical Guide for Collection and Destruction, Program on Security and Development (SAND), February, 2000.

Fisher et al, Responding to Conflict, *Working With Conflict, Skills and Strategies for Action*, Zed Books, New York, 2000.

Hague Appeal for Peace, *Teaching Toward a Culture of Peace* Learning to Abolish War   A Peace Education Resource Packet, Hague Agenda for Peace and Justice for the 21st Century, New York, 2002.

Hague Appeal for Peace, *Time to Abolish War*, a youth agenda for peace and justice, New York, January 2000.

Hiroshima Institute For Peace Education, *A Standard Curriculum For Peace Education*, Hiroshima Japan, Aug,1, 1980.

Kreidler, William J., ESR Education for Social Responsibility, A Curriculum and Teacher's Guideline, *Conflict Resolution in Middle School*, USA, 1994-97.

Kreidler, W.J and Furlong, L., *Adventures in Peacemaking*, Educators for Social Responsibility, USA, 1995.

Kreidler, William J., *Teaching, Conflict Resolution through Children's Literature*, Scholastic U.S.A, 1992.

Lesley, *Creating Peaceable Schools*, Summer Institute 2002.

Maha Ghosananda, *Step by Step*, Translated by Choun Nath, Japan Sotoshu Relief Committee (JSRC), June 15, 1993.

Operation Respect, Don't Laugh at Me, *Teachers Guide Grade* 2-5 Creating Ridicule- Free Classroom, Peter Yarrow Productions and Educators for Social Responsibility, New York, 2000.

Operation Respect, Don't Laugh at Me, *Teachers Guide Grade* 6-8 Creating Ridicule- Free Classroom, Peter Yarrow Productions and Educators for Social Responsibility, New York, 2000.

Roop, Peter and Connie; *Life and Times of Martin Luther King Jr.*,1998.

Royal Government of Cambodia, Ministry of Education Youth and Sports (MoEY&S), Society Study,   *Morality and Citizenship*, Grade 10, student book part 2,   PP2001

Royal Government of Cambodia, The Ministry of Education Youth and Sports (MoEY&S), Society Study,   *Morality and Citizenship,* Grade 10, teacher book part 2,   PP2001

Royal Government of Cambodia, The Ministry of Education Youth and Sports (MoEY&S), Society Study, *Morality and Citizenship,* Grade 11, teacher book part 2, PP2000

Royal Government of Cambodia, The Ministry of Education Youth and Sports (MoEY&S), Society Study, *Morality and Citizenship,* Grade 11, student book part 2, PP2000

Royal Government of Cambodia, The Ministry of Education Youth and Sports (MoEY&S), Society Study, *Morality and Citizenship,* Grade 12, teacher book part 2, PP2000

Royal Government of Cambodia, The Ministry of Education Youth and Sports (MoEY&S), Society Study, *Morality and Citizenship,* Grade 12, student book part 2, PP2001

UNESCO and UNICEF, *Living Values: An Educational Program, Values Activities for Children Ages 3-7,* New York, June 2000.

UNESCO and UNICEF, *Living Values: An Educational Program, Values Activities for Children Ages 8-14,* New York, June 2000.

UNESCO and UNICEF, *Living Values: An Educational Program, Values Activities for Children Ages 8-14,* New York, June 2000 – Khmer Version.

UNESCO, *Peace Box Children's Appeal,* ASP net, Paris, 1997.

UNESCO, *Peace Guide for Teacher Book,* ASP net, Paris, 1997.

UNICEF, *Education for Conflict Resolution*, 1997.

World Vision-Cambodia and MCC, Child Labour Project-Stung Mean Chey, *Children's Club Manual,* in the cooperation between World Vision – Cambodia and MCC, Module 1.

World Vision-Cambodia and MCC, Child Labour Project-Stung Mean Chey, *Children's Club Manual,* in the cooperation between World Vision – Cambodia and MCC, Module 2.

WVI-C Battambang, *Building Bridges for Peace*, A Christmas Gift from the Voc-Rehab staff to their colleagues and friends, Cambodia, October, 1996.

Yem Sam Oeun and Catella, R., "*I Live in Fear* ", Consequences of Small Arms and Light Weapons on Women and Children in Cambodia, Working Group for Weapon Reduction, Phnom Penh, Cambodia, June 2001.

York S., *Roots and Wings,* Affirming Culture in Early Childhood Programs, New York, 1991.

ការអប់រំសន្តិភាព និង ដកហូតអាវុធ

សម្រាប់មធ្យមសិក្សាទុតិយភូមិនៅកម្ពុជា

អង្គការកាត់បន្ថយអាវុធ (WGWR)

**Working Group for Weapons Reduction**

Hague Appeal for Peace

UN Department for Disarmament Affairs